២០២២

NGO-CEDAW

# របាយការណ៍ពិនិត្យតាមដានការអនុវត្ត អនុសញ្ញា ស៊ីដ

# សម្រាប់ប្រទេសកម្ពុជា

# សេចក្តីថ្លែងអំណរគុណ

របាយការណ៍នេះត្រូវបានរៀបចំចងក្រងឡើងដោយគណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ (NGO-CEDAW) ដោយសហការជាមួយ អង្គការសង្គមស៊ីវិលជាសមាជិក និងដៃគូរបស់ខ្លួន ក៏ដូចជាសម្ព័ន្ធអង្គការសង្គមស៊ីវិលផ្សេងទៀតនៅកម្ពុជា ដែលមានសណ្តានចិត្តជួយផ្តល់ជាធាតុចូល និងដំបូន្មានជាបច្ចេកទេសផ្សេងៗ។

NGO-CEDAW សូមថ្លែងអំណរគុណយ៉ាងជ្រាលដល់ការរួមចំណែករបស់ អង្គការអាក់សិនអេតកម្ពុជា អង្គការបន្ទាយស្រី អង្គការកម្ពុជាដើម្បីសុខភាព និងការអប់រំសហគមន៍ (CHEC) អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ (CWCC) គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល) អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា (GADC) អង្គការ Hear Us អង្គការក្លាហាន អង្គការ Micro Rainbow អន្តរជាតិ អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល (NEP) អង្គការថែទាំសុខភាពគ្រួសារកម្ពុជា (RHAC) មជ្ឈមណ្ឌលសាមគ្គីភាព (Solidarity Center) វិទ្យាស្ថាន STEP Academy អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស (LICADHO) មជ្ឈមណ្ឌលព័ត៌មានស្ត្រី (WMC) និងអង្គការនារីដើម្បីសន្តិភាព (WPM) ។

របាយការណ៍នេះបានទទួលការគាំទ្រថវិកាសប្បុរសធម៌ពីអង្គការ Bread for the World
អង្គការ DanChurchAid Cambodia អង្គការ Heinrich Böll Stiftung Cambodia
និង UNTrustFund ។ ទស្សនៈ និងខ្លឹមសារនានានៅក្នុងការបោះពុម្ពផ្សាយរបាយការណ៍នេះ
មិនឆ្លុះបញ្ចាំងនូវការយល់ឃើញរបស់អង្គការនានាដែលផ្តល់មូលនិធិនោះទេ ។

គាំទ្រដោយ

# មាតិកា


**១. អំពើហិង្សាផ្អែកលើយេនឌ័រ**

១.១ ស្ថិតិស្តីពីអំពើហិង្សាផ្អែកលើយេនឌ័រសម្រាប់ឆ្នាំ២០២២
១.២ អំពើជួញដូរមនុស្ស
១.៣ ការបៀតបៀន និងការរំលោភបំពានតាមអនឡាញ
១.៤ លទ្ធភាពស្វែងរកយុត្តិធម៌ និងការប្រើប្រាស់មិនត្រឹមត្រូវនូវយន្តការដោះស្រាយក្រៅប្រព័ន្ធតុលាការ (ADR) នៅក្នុងករណីអំពើហិង្សាផ្អែកលើយេនឌ័រ
១.៥ ឃាតកម្មដោយដៃគូស្និទ្ធស្នាល
១.៦ អំពើហិង្សា និងការបៀតបៀនលើស្ត្រីកម្មករនិយោជិត
អំពើហិង្សាផ្អែកលើយេនឌ័រទៅលើក្រុមជនងាយរងគ្រោះ

**២. ស្ត្រី និងក្មេងស្រីជនជាតិដើម និងជនជាតិភាគតិច**

២.១ លទ្ធភាពទទួលបានការអប់រំ និងសេវាសុខភាពបន្តពូជ
២.២ បទពិសោធន៍នៃការរើសអើង
២.៣ កង្វះក្តីសង្ឃឹមទទួលបានការអប់រំបានខ្ពស់

**៣. ពលកម្មការងារ**

៣.១ លទ្ធភាពទទួលបានចំណេះដឹងដែលឆ្លើយតបនឹងយេនឌ័រ
៣.២ ផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុមកលើស្ត្រីជាកម្មករនិយោជិក

**៤. ការអប់រំ**

៤.១ លទ្ធភាពទទួលបានចំណេះដឹងដែលឆ្លើយតបនឹងយេនឌ័រ
៤.២ ការរើសអើងយេនឌ័រ និងឧបសគ្គចំពោះការអប់រំ
៤.៣ អត្រាបោះបង់ចោលការសិក្សារបស់សិស្ស
៤.៤ អនុសាសន៍សម្រាប់ការអប់រំ

**៥. ស្ត្រីក្នុងភាពជាអ្នកដឹកនាំ**

៥.១ ស្ត្រីក្នុងកិច្ចការនយោបាយ និងសាធារណៈ
៥.២ ស្ត្រីក្នុងវិស័យសារព័ត៌មាន

**៦. ការពពោះជំនួស**

**៧. លទ្ធភាពទទួលបានការថែទាំសុខភាព**

៧.១ លទ្ធភាពទទួលបានការថែទាំសុខភាពក្នុងចំណោមពលករចំណាកស្រុកដែលត្រូវបានបញ្ជូនត្រលប់មកវិញ
៧.២ លទ្ធភាពទទួលបានការថែទាំសុខភាពរួមសម្រាប់ជនរងគ្រោះពីអំពើហិង្សាផ្អែកលើយេនឌ័រ

# ទិដ្ឋភាពទូទៅក្នុងឆ្នាំ២០២២

ឆ្នាំ២០២២ នៅតែបន្តកើតមានទូវបញ្ហាប្រឈមជាច្រើន ដែលគណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ (NGO-CEDAW) និងដៃគូរបស់ខ្លួនបានចងក្រងជាឯកសារនៅក្នុងរបាយការណ៍ពិនិត្យតាមដានមុនៗ។ នៅក្នុងកំឡុងពេលនេះផងដែរ ក៏ឃើញមានការកើនឡើងគួរឱ្យព្រួយបារម្ភនូវការបង្ក្រាបលើក្រុមសកម្មសន្តិវិធីដែលដឹកនាំដោយស្ត្រី ជាករណីដែលលេចធ្លោបំផុតដែលនៅសេសសល់ទាក់ទងនឹងកាស៊ីណូ ណាហ្គា វើលដ៏ ដែលរងការចោទប្រកាន់ថា បានបណ្តេញចេញពីការងារដោយមិនមានសមាមាត្រចំពោះស្ត្រីមានផ្ទៃពោះ និងស្ត្រីបំបៅដោះកូន ក៏ដូចជាសមាជិកសហជីពជាស្ត្រីផងដែរ (ផ្នែកទី ១.៦; ៣.១)។

ការស្រាវជ្រាវថ្មីបានធ្វើឡើងដោយលើកយកបញ្ហាមួយចំនួន ចេញពីរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ សង្គមស៊ីវិល និងប្រភពគ្រឹះស្ថានសិក្សាស្រាវជ្រាវផ្សេងទៀត។ ជាក់ស្តែង អង្គការសិទ្ធិស្ត្រីក្នុងស្រុកមួយដែលមានឈ្មោះថា អង្គការនារីដើម្បីសន្តិភាព បានបោះពុម្ពផ្សាយឯកសារស្រាវជ្រាវមួយស្តីអំពីបញ្ហាប្រឈមផ្នែកសិទ្ធិមនុស្ស ដែលស្ត្រី និងកុមារីជនជាតិដើម និងជនជាតិភាគតិចនៅក្នុងប្រទេសកម្ពុជាកំពុងជួបប្រទះ (ផ្នែកទី ២)។ ឯកសារស្រាវជ្រាវនេះបានលើកឡើងពីបញ្ហាបន្ទាន់ទាក់ទងនឹងជនមិនមានសញ្ជាតិ ដែលបង្ហាញថារដ្ឋមានការដោះស្រាយមិនគ្រប់គ្រាន់លើបញ្ហានេះ បើទោះបីជាមានការអំពាវនាវពីគណៈកម្មាធិការនៃអង្គការសហប្រជាជាតិ ទទួលបន្ទុកអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ (គណៈកម្មាធិការស៊ី-ដ) ឱ្យផ្តល់អាទិភាពលើការសម្របសម្រួលលទ្ធភាពទទួលបានឯកសារសម្គាល់អត្តសញ្ញាណ និងការចុះសំបុត្រកំណើតក្តី។

ទន្ទឹមនឹងនេះ អ្នកសារព័ត៌មានក៏បានចុះផ្សាយនូវភស្តុតាងសំខាន់ៗថ្មីៗទាក់ទងនឹងការរំលោភសិទ្ធិស្ត្រីនៅឆ្នាំ២០២២ ផងដែរ។ ជាក់ស្តែង ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យនៅកម្ពុជាបានស៊ើបអង្កេតពីហេតុប៉ះពាល់នៃការកើនឡើងគួរឱ្យព្រួយបារម្ភនៃការឆបោក និងទាសភាពសម័យទំនើបនៅក្នុងប្រទេសកម្ពុជា (ផ្នែកទី ១.២) ចំណែកឯសារព័ត៌មានផ្សេងទៀត បានបន្តចុះផ្សាយអំពីស្ត្រីដែលបន្តរងផលប៉ះពាល់ដោយការបង្ក្រាបលើករណីពពោះជំនួស ពីសំណាក់រដ្ឋាភិបាលកម្ពុជាក្នុងកំឡុងចុងទសវត្សរ៍ឆ្នាំ២០១០ (ផ្នែកទី ៦)។

ទោះបីជាវិធានការបិទខ្ទប់ត្រូវបានដកចេញក្តី ប៉ុន្តែ ការធ្លាក់ចុះផ្នែកសេដ្ឋកិច្ចដោយសារតែជំងឺរាតត្បាតបានបន្តកើតមានពេញឆ្នាំ២០២២ គួបផ្សំនឹងភស្តុតាងថ្មីៗគួរឱ្យភ្ញាក់ផ្អើល ដែលបង្ហាញពីផលប៉ះពាល់នាពេលបច្ចុប្បន្នអំពីការប្រែប្រួលអាកាសធាតុលើស្ត្រីកម្មករកាត់ដេរ (ផ្នែកទី ៣.២)។ ចុងក្រោយ ការបោះឆ្នោតឃុំ សង្កាត់កាលពីពាក់កណ្តាលឆ្នាំ មិនបានជួយឱ្យចំនួនក្រុមប្រឹក្សាជាស្ត្រីកើនឡើងបាន ០.២% បន្ថែមទៀតឡើយ ធៀបនឹងអាណត្តិមុនក្នុងឆ្នាំ២០១៧ (ផ្នែកទី ៥)។

របាយការណ៍នេះជាសេចក្តីសង្ខេបអំពីកង្វល់ និងព្រឹត្តិការណ៍សំខាន់ៗដែលបានកើតឡើងក្នុងឆ្នាំ២០២២។ របាយការណ៍នេះមិនបានលើកឡើងគ្រប់ជ្រុងជ្រោយនៃបញ្ហាទាំងអស់ដែលស្ត្រី កុមារី និងជនមិនកំណត់អត្តសញ្ញាណភេទនៅក្នុងប្រទេសកម្ពុជាកំពុងតែជួបប្រទះនោះទេ ប៉ុន្តែរបាយការណ៍នេះផ្តោតទៅលើបញ្ហាដែលថ្មី ឬជាបញ្ហាដែលមានការព្រួយបារម្ភខ្លាំងនៅក្នុងឆ្នាំ២០២២។

# ១. អំពើហិង្សាផ្អែកលើយេនឌ័រ

អំពើហិង្សាផ្អែកលើយេនឌ័រ (GBV) គឺជាពាក្យដែលមានន័យទូលំទូលាយ ដែលរាប់បញ្ចូលទាំងការរំលោភសេពសន្ថវៈ និងការរំលោភបំពានផ្លូវភេទ ការបៀតបៀនផ្លូវភេទ (នៅក្នុងពិភពការងារ សាលារៀន និងកន្លែងសាធារណៈ) អំពើហិង្សាក្នុងគ្រួសារ (រួមទាំងការរំលោភបំពានលើកុមារ ការរំលោភបំពានលើសមាជិកគ្រួសារ និងអំពើហិង្សាលើដៃគូស្និទ្ធស្នាល) ការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ និងអំពើហិង្សាដែលប្រព្រឹត្តដោយរដ្ឋ។ កុមារី និងស្ត្រីជាច្រើន រួមទាំងបុគ្គលដែលជាជនមិនកំណត់អត្តសញ្ញាណភេទ និងអ្នកប្តូរភេទនៅកម្ពុជា មិនត្រឹមតែទទួលរងនូវអំពើហិង្សាផ្អែកលើយេនឌ័រក្នុងទម្រង់ផ្សេងៗប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងប្រឈមនឹងឧបសគ្គធំៗក្នុងការទទួលបានសេវានានា និងយុត្តិធម៌ មិនថាតាមរយៈប្រព័ន្ធយុត្តិធម៌ផ្លូវការ ឬយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនោះឡើយ។

## ១.១. ស្ថិតិស្តីពីអំពើហិង្សាផ្អែកលើយេនឌ័រសម្រាប់ឆ្នាំ២០២២

អត្ថបទព័ត៌មានចុះផ្សាយកាលពីខែកញ្ញាឆ្នាំ២០២២ [១] បានដកស្រង់សម្តីរបស់រដ្ឋលេខាធិការក្រសួងកិច្ចការនារី ដែលមានប្រសាសន៍ថា កាលពីឆ្នាំមុនកម្រិតអំពើហិង្សាលើស្ត្រីនៅតែមានកម្រិតថេរដដែល។ គាត់បានកត់សម្គាល់ថា មានករណីចំនួន ២,៥៥៣ ដែល ក្រសួងកិច្ចការនារី បានសហការជាមួយក្រសួងយុត្តិធម៌ នគរបាល និងមន្ត្រីផ្សេងទៀត “ធ្វើអន្តរាគមន៍តាមផ្លូវច្បាប់ដើម្បីលើកកម្ពស់” ជីវិតរបស់ស្ត្រី។ ទោះជាយ៉ាងនេះក្តី ព័ត៌មានដែលបានផ្តល់មកនេះ មិនមានភាពច្បាស់លាស់ទេថា តើករណីទាំងនោះត្រូវបានដោះស្រាយដោយរបៀបណា (ការចាប់ខ្លួន ករណីដែលបញ្ជូនទៅតុលាការ ឬករណីដែលបានបង្វែរពីប្រព័ន្ធតុលាការផ្លូវការ ទៅរកដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅថ្នាក់មូលដ្ឋានវិញ)។

យោងតាមរបាយការណ៍អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា (CDHS) ឆ្នាំ២០២១-២០២២ [២] អត្រាប្រេវ៉ាឡង់ពេញមួយជីវិតនៃអំពើហិង្សាលើដៃគូស្និទ្ធស្នាល (IPV) លើផ្លូវកាយ ផ្លូវភេទ ឬផ្លូវអារម្មណ៍ (IPV) ពីសំណាក់ដៃគូបច្ចុប្បន្ន ឬអតីត គឺមាន ២២%។ ទន្ទឹមនឹងនេះ មាន ២៤.៤% ដែលបានរាយការណ៍ថា ដៃគូមានឥរិយាបថត្រួតត្រាលើរូបគេ ដូចជា ការរឹតត្បិតលើទំនាក់ទំនងរបស់ខ្លួនជាមួយគ្រួសារ ឬមិត្តភក្តិស្រីៗ។ ទោះជាយ៉ាងណា ហាក់មានការថយចុះនូវអត្រាប្រេវ៉ាឡង់នៃអំពើហិង្សារាងកាយលើស្ត្រីនៅកម្ពុជា ពី ២០% ក្នុងឆ្នាំ២០១៤ មកត្រឹម ១០% នៅឆ្នាំ២០២២ សម្រាប់អំពើហិង្សាអាយុ ចាប់ពី ១៥ ឆ្នាំឡើងទៅ។ អំពើហិង្សាទាំងនេះភាគច្រើន ប្រព្រឹត្តដោយដៃគូស្និទ្ធស្នាលបច្ចុប្បន្ន ឬអតីត។ និន្នាការផ្សេងទៀតនៅតែជារឿងគួរឱ្យបារម្ភខ្លាំងដដែល។ ជាក់ស្តែង លទ្ធផលនៃការអង្កេតបានបង្ហាញថា “ស្ត្រីដែលបានឆ្លងកាត់អំពើហិង្សាផ្លូវកាយ ឬផ្លូវភេទ មាន ៥៣% ដែលមិនបានស្វែងរកជំនួយ ឬប្រាប់នរណាម្នាក់អំពីអំពើហិង្សានោះទេ” ហើយ “ស្ត្រីដែលឆ្លងកាត់អំពើហិង្សាផ្លូវកាយ ឬផ្លូវភេទដែលប្រព្រឹត្តដោយប្តី/ដៃគូស្និទ្ធស្នាលបច្ចុប្បន្ន ឬប្តី/ដៃគូស្និទ្ធស្នាលចុងក្រោយបំផុត មាន ៤៣% ដែលបានទទួលរងនូវរបួសស្នាម”។

អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ (CWCC) ជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលផ្តល់សេវា និងមណ្ឌលស្នាក់នៅសុវត្ថិភាពសម្រាប់ជនរងគ្រោះពីអំពើហិង្សាផ្អែកលើយេនឌ័រ បានរាយការណ៍ថា កាលពីខែឧសភា ឆ្នាំ២០២២ "អំពើហិង្សាលើស្ត្រីនៅកម្ពុជាមិនមានការថយចុះទេក្នុងរយៈពេលពីរឆ្នាំកន្លងមកនេះ ជាក់ស្តែងអំពើហិង្សានេះមានការកើនឡើងជារៀងរាល់ថ្ងៃ។" [៣] យោងតាមកំណត់ត្រារបស់អង្គការ CWCC ក្នុងឆ្នាំ២០២២ មានអំពើហិង្សាចំនួន ៤៤២ ករណី ដែលក្នុងនោះអង្គការបានផ្តល់ជំនួយផ្នែកច្បាប់ដល់ស្ត្រីរងគ្រោះពីអំពើហិង្សានៅក្នុងខេត្តចំនួនបួនដែលអង្គការធ្វើការជាមួយ។ កំណត់ត្រាករណីអំពើហិង្សាប្រភេទនេះដែលអង្គការទទួលបានកាលពីឆ្នាំមុនមានចំនួន ៤១០ ករណី។

| ករណីអំពើហិង្សាផ្អែកលើយេនឌ័រ (CWCC) | ភ្នំពេញ | បន្ទាយមានជ័យ | សៀមរាប | កំពង់ធំ | សរុប |
|---|---|---|---|---|---|
| អំពើហិង្សាក្នុងគ្រួសារ | ៤៦ | ៣៥ | ៩៤ | ៧០ | ២៤៥ |
| ការរំលោភបំពានផ្លូវភេទ | ១១ | ៣៦ | ៤៧ | ៩ | ១០៣ |
| អំពើជួញដូរ | ៩៣ | ១ | ០ | ០ | ៩៤ |
| សរុប | ១៥០ | ៧២ | ១៤១ | ៧៩ | ៤៤១ |

ស្រដៀងគ្នានេះដែរ អង្គការកម្ពុជាដើម្បីសុខភាព និងការអប់រំសហគមន៍ (CHEC) ជាអង្គការក្នុងស្រុក ដែលផ្តល់ការអប់រំសហគមន៍ និងលើកកម្ពស់ការយល់ដឹងដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រីកុមារ និងអ្នកស្រលាញ់ភេទដូចគ្នា (LGBT) បានកត់ត្រាករណីអំពើហិង្សាក្នុងគ្រួសារចំនួន ៨៣៣ ករណី ក្នុងឆ្នាំ២០២២ ធៀបនឹង ៥៥៧ ករណីក្នុងឆ្នាំ២០២១។ ទោះបីជាទិន្នន័យនេះត្រូវបានកំណត់ត្រឹមតួលេខដែលផ្តល់ដោយអង្គការចំនួនពីរក្តី ប៉ុន្តែការកើនឡើងនូវចំនួនករណីដែលទទួលបាននេះបង្ហាញថាអំពើហិង្សាផ្អែកលើយេនឌ័រនៅតែបន្តជាបញ្ហាបន្ទាន់ក្រោយផ្ទុះជំងឺរាតត្បាត។

នៅឆ្នាំ២០២២ អង្គការ CHEC ក៏បានបញ្ចប់ការសិក្សាមួយស្តីពីផលប៉ះពាល់ពាក់ព័ន្ធនឹងអំពើហិង្សាផ្អែកលើយេនឌ័រ នៅពេលបិទខ្ទប់ក្នុងសម័យផ្ទុះរោគរាតត្បាត និងវិធានការរក្សាគម្លាតសង្គម។ [៤] ក្នុងចំណោមជនរងគ្រោះដោយអំពើហិង្សាផ្អែកលើយេនឌ័រដែលបានសម្ភាសន៍ក្នុងការសិក្សានេះ មានប្រហែលពីរភាគបី (៦៨%) បានរាយការណ៍ករណីរបស់ខ្លួនទៅអាជ្ញាធរមូលដ្ឋាន។ ក្នុងចំណោមជនរងគ្រោះដែលសម្រេចមិនរាយការណ៍ពីករណីរបស់ខ្លួននោះ គេបានផ្តល់ហេតុផលសម្រាប់ការសម្រេចចិត្តបែបនេះ ដែលហេតុផលទាំងនោះរួមមាន ការមិនចង់ទម្លាយប្រាប់ពីបទពិសោធន៍នៃអំពើហិង្សាចំពោះខ្លួន (៨៩%) ខ្លាចជនល្មើស (២៧%) និងចង់ជៀសវាងកុំឱ្យមានការឆ្លងមេរោគកូវីដ-១៩ (១៦%)។

អង្គការអាក់សិនអេតកម្ពុជា (AAC) បានពិនិត្យតាមដានប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុកចំនួនប្រាំដែលរាយការណ៍អំពីករណីអំពើហិង្សាលើស្ត្រីចំនួន ១១៩ ករណីក្នុងឆ្នាំ២០២២។ ករណីដែលបានរាយការណ៍មានចាប់ពីការបៀតបៀនផ្លូវភេទ អំពើហិង្សាលើដៃគូស្និទ្ធស្នាល (IPV) ការប្រទូសកេរ្តិ៍ខ្មាស់ ការរំលោភសេពសន្ថវៈ និងឃាតកម្ម។ គោលបំណងនៃការពិនិត្យតាមដានគឺដើម្បីកំណត់ថាតើការរាយការណ៍ពីស្ថាប័នព័ត៌មានទាំងនេះ អនុលោមតាមក្រមប្រតិបត្តិប្រព័ន្ធផ្សព្វផ្សាយសម្រាប់ការរាយការណ៍អំពីអំពើហិង្សាលើស្ត្រីដែលត្រូវបានសម្រេចជាប្រកាសរួមរវាង ក្រសួងកិច្ចការនារី និងក្រសួងព័ត៌មានក្នុងឆ្នាំ ២០១៧។

តាមរយៈរបាយការណ៍ពិនិត្យតាមដាននេះ គឺពុំមានស្ថាប័នព័ត៌មានណាមួយត្រូវបានរកឃើញថាអនុលោមតាមក្រមប្រតិបត្តិប្រព័ន្ធផ្សព្វផ្សាយ សម្រាប់ការរាយការណ៍ព័ត៌មានអំពើហិង្សាលើស្ត្រី បានពេញលេញឡើយ។ បញ្ហាកើតមានញឹកញាប់បំផុតរួមមានការបញ្ចេញអត្តសញ្ញាណជនរងគ្រោះ/អ្នករស់រានមានជីវិតរួមទាំងឈ្មោះ និងអាសយដ្ឋានរបស់ពួកគេ ការស្តីបន្ទោសជនរងគ្រោះ/អ្នករស់រានមានជីវិត និងក្រុមគ្រួសាររបស់ពួកគេ ធ្វើការសន្និដ្ឋានអំពីករណីទាំងនោះ និង “លេងសើច” ជុំវិញអង្គហេតុនៃករណីទាំងនោះ។

ចុងក្រោយ អង្គការសិទ្ធិមនុស្សលីកាដូ បានស៊ើបអង្កេតករណីសិទ្ធិស្ត្រីថ្មីៗសរុបចំនួន ៩៣ ករណី និងករណីសិទ្ធិកុមារថ្មីៗចំនួន ១៤៤ ករណី ពាក់ព័ន្ធនឹងការរំលោភសិទ្ធិកុមារីទូទាំង ១២ ខេត្ត និងក្រុងភ្នំពេញក្នុងឆ្នាំ២០២២។ ភាគច្រើននៃករណីដែលប្រព្រឹត្តមកលើស្ត្រីពេញវ័យ គឺអំពើហិង្សាក្នុងគ្រួសារ (៥៥ ករណី) និងការរំលោភសេពសន្ថវៈ ឬការប៉ុនប៉ងរំលោភសេពសន្ថវៈ (៣៣ ករណី) ខណៈដែលករណីភាគច្រើនដែលប្រព្រឹត្តលើក្មេងស្រី គឺការរំលោភសេពសន្ថវៈ ឬការប៉ុនប៉ងរំលោភសេពសន្ថវៈ (១២១ ករណី)។ ក្នុងចំណោមករណីទាំងនេះ ប្រហែលពាក់កណ្តាលនៃការរំលោភសិទ្ធិកុមារី គឺប្រព្រឹត្តឡើងដោយសមាជិកគ្រួសារ ហើយជាងពាក់កណ្តាលនៃការរំលោភសិទ្ធិស្ត្រីត្រូវបានប្រព្រឹត្តដោយដៃគូស្និទ្ធស្នាលបច្ចុប្បន្ន ឬអតីតដៃគូស្និទ្ធស្នាលរបស់ពួកគេ។

ករណីដែលចងក្រងដោយអង្គការទាំងនេះមិនបង្ហាញពីអត្រាប្រេវ៉ាឡង់សរុប ឬចរិតលក្ខណៈនៃអំពើហិង្សាផ្អែកលើយេនឌ័រនៅកម្ពុជានោះទេ ដោយសារតែមានឧបសគ្គនៃការរាយការណ៍អំពីអំពើហិង្សាក៏ដូចជាសមត្ថភាពនៅមានកម្រិតរបស់អង្គការសង្គមស៊ីវិលក្នុងការធ្វើការលើករណីថ្មីៗ និងទីតាំងថ្មីៗ។ ទោះជាបែបនេះក្តី ករណីទាំងនេះបានបង្ហាញថា អំពើហិង្សាផ្អែកលើយេនឌ័រកើតមានជាទូទៅ ហើយជារឿយៗស្ត្រី និងកុមារីនៅតែជួបប្រទះឧបសគ្គធំៗក្នុងការទទួលបានយុត្តិធម៌តាមរយៈប្រព័ន្ធច្បាប់។

## ១.២. អំពើជួញដូរមនុស្ស

ក្នុងឆ្នាំ២០២២ គេសង្កេតឃើញមានការកើនឡើងបន្ថែមទៀតនូវអំពើជួញដូរមនុស្សនិងវិបត្តិទាសភាពសម័យទំនើបនៅកម្ពុជា។ ជនរងគ្រោះភាគច្រើនមកពីសាធារណរដ្ឋប្រជាមានិតចិន វៀតណាម និងបណ្តាប្រទេសផ្សេងទៀតទូទាំងអាស៊ីអាគ្នេយ៍ ត្រូវបានបោកបញ្ឆោតឱ្យធ្វើដំណើរមកប្រទេសកម្ពុជា ដោយមានការសន្យាថានឹងទទួលបានការងារដែលមានប្រាក់ខែខ្ពស់ ប៉ុន្តែបែរជាត្រូវជាប់ឃុំនៅតំបន់ដែលមានព័ទ្ធដោយបន្ទាលួស ហើយត្រូវបានបង្ខំឱ្យធ្វើការច្រើនម៉ោង ដោយធ្វើការងារបោកប្រាស់តាមអនឡាញ។

នៅខែសីហា ឆ្នាំ២០២២ លោក វិធិត ម៉ាន់ថាផន (Vitit Muntabhorn) អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា បានចុះផ្សាយសេចក្តីថ្លែងការបញ្ចប់បេសកកម្មរបស់លោក[៥] ដោយមានវគ្គមួយនោះ លោកបានរៀបរាប់អំពីជនរងគ្រោះនៃអំពើជួញដូរនៅកម្ពុជាថាដូចជា "រស់នៅក្នុងឋាននរក"។ លោក បានកំណត់សម្គាល់ថា ជនរងគ្រោះពីការឆបោក ត្រូវបានបង្ខំឱ្យឆបោកអ្នកផ្សេងទៀត ហើយប្រសិនបើ "អ្នកឆបោកបរាជ័យក្នុងការផ្តល់លទ្ធផលល្អ ឬបដិសេធមិនគោរពតាមបញ្ជា បុគ្គលនោះអាចត្រូវបានធ្វើទារុណកម្ម ឬចាក់សោនៅក្នុងទីតាំងនានាដែលព័ទ្ធទៅដោយបន្លាលួស និងរបងដែកដើម្បីការពារកុំឱ្យមានការរត់គេចខ្លួន"។ [៦]

ចាប់តាំងពីវិបត្តិនេះបានលេចឡើងកាលពីចុងទសវត្សរ៍ ២០១០ ហើយអំឡុងពេលដែលវិបត្តិនេះកើនឡើងក្នុងកំឡុងពេលផ្ទុះជំងឺរាតត្បាត រដ្ឋាភិបាល និងអាជ្ញាធរកម្ពុជាបានរងការរិះគន់ថា មើលស្រាលស្ថានភាព និងមិនចាត់វិធានការ ដោយក្នុងនោះមានរបាយការណ៍មួយចំនួនបានចុះផ្សាយថាអាជ្ញាធរថែមទាំងបានឱ្យដំណឹងមុនដល់ក្រុមជនឆបោកទាំងនោះអំពីការឆ្មក់បង្ក្រាបផងដែរ។ [៧]

នៅខែកក្កដា ឆ្នាំ២០២២ ក្រោយមានការចេញព័ត៌មានញឹកញាប់ដោយសារព័ត៌មានឯករាជ្យ និងការអំពាវនាវពីសំណាក់បណ្តាញស្ម័គ្រចិត្ត និងអង្គការសង្គមស៊ីវិល របាយការណ៍ស្តីពីការជួញដូរមនុស្សដោយក្រសួងការបរទេសសហរដ្ឋអាមេរិកបានទម្លាក់ចំណាត់ថ្នាក់កម្ពុជានៅ កម្រិតទី ៣ ដែលជាចំណាត់ថ្នាក់ទាបបំផុត។ [៨] របាយការណ៍នោះបានបញ្ជាក់ថា៖

*"រដ្ឋាភិបាលកម្ពុជាមិនបានបំពេញតាមបទដ្ឋានអប្បបរមាឱ្យបានពេញលេញ ស្តីពីការលុបបំបាត់អំពើជួញដូរមនុស្ស ហើយក៏ពុំមានការប្រឹងប្រែងឱ្យបានមុតមាំក្នុងការលុបបំបាត់នោះដែរ ....អំពើពុករលួយបន្តរារាំងដល់ប្រតិបត្តិការអនុវត្តច្បាប់ជារួម ការទទួលខុសត្រូវរបស់ជនល្មើស និងការផ្តល់សេវាដល់ជនរងគ្រោះ[PO1] ។ អាជ្ញាធរ មិនស៊ើបអង្កេត ហើយក៏មិនបានដាក់ឱ្យមន្ត្រីណាទទួលខុសត្រូវចំពោះការជាប់ពាក់ព័ន្ធនឹងការរួមគំនិតដែលមានការរាយការណ៍ជាច្រើន ហើយទុកចិត្តបាន ជាពិសេស ម្ចាស់អាជីវកម្មដែលគ្មានគុណធម៌ ដែលនាំមនុស្សប្រុសស្រី និងកុមាររាប់ពាន់នាក់នៅទូទាំងប្រទេសឱ្យធ្លាក់ចូលក្នុងអំពើជួញដូរមនុស្សនៅតាមទីតាំងកម្សាន្ត ឡូតូ និងប្រតិបត្តិការបោកប្រាស់តាមអនឡាញ។*

*ដូច្នេះ មន្ត្រីបរាជ័យក្នុងការចាត់វិធានការជាមុន ក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះពីអំពើជួញដូរក្នុងចំណោមប្រជាជនដែលងាយរងគ្រោះខ្លាំងទាំងនេះ។ រដ្ឋាភិបាលមិនបានផ្តល់សេវាគាំពារគ្រប់គ្រាន់សម្រាប់ជនរងគ្រោះក្នុងប្រទេស ឬក្រៅប្រទេស ហើយពឹងផ្អែកលើសលុបលើម្ចាស់ជំនួយបរទេស និងអង្គការមិនមែនរដ្ឋាភិបាលដើម្បីផ្តល់សេវាថែទាំដែលគេត្រូវការច្រើន"។*

បន្ទាប់ពីការទទ្លាក់ចំណាត់ថ្នាក់នេះមក មានប្រតិបត្តិការឆ្មក់បង្ក្រាបទ្រង់ទ្រាយធំជាហូរហែបានកើតមាននៅចុងឆ្នាំ២០២២ រាប់បញ្ចូលទាំងសណ្ឋាគារល្បីៗនៅកណ្តាលរាជធានីភ្នំពេញដែលបិទទ្វារអំឡុងពេលផ្ទុះជំងឺរាតត្បាត។ ទោះជាយ៉ាងណា មានការទទួលស្គាល់យ៉ាងទូលំទូលាយថា ការចាត់ទូវសកម្មភាពជាប់លាប់ មានធនធានគ្រប់គ្រាន់ និងជាបន្ទាន់នោះគឺជាការចាំបាច់ក្នុងការប្រយុទ្ធប្រឆាំងដាច់ខាតចំពោះបញ្ហានេះ ហើយទប់ស្កាត់ប្រតិបត្តិការខុសច្បាប់ទាំងនេះ កុំឱ្យផ្លាស់ទីតាំងទៅកន្លែងផ្សេងទៀតនៅក្នុងប្រទេស។ [៩]

របាយការណ៍ទាំងនេះបង្ហាញថា មានជនរងគ្រោះរហូតដល់ទៅ ១០% ជាស្ត្រី ដោយជនរងគ្រោះមួយចំនួនត្រូវបានបង្ខំឱ្យផ្តល់ "សេវាផ្លូវភេទនៅទីតាំងទាំងនោះ ឬបង្ខំឱ្យថតសម្តែងវីដេអូអាសអាភាសចូលទៅក្នុងប្រព័ន្ធវីដេអូកាមេរ៉ា" [១០]ទន្ទឹមពេលដែលបញ្ហាទាសភាពនៅតាមប្រព័ន្ធអ៊ិនធឺណិតចេះតែបន្តកើតមាន ក្តីបារម្ភពីអំពើជួញដូរមនុស្សផ្សេងទៀតក៏នៅតែកើតមានផងដែរ។ របាយការណ៍របស់ក្រសួងការបរទេសសហរដ្ឋអាមេរិក បានផ្តល់ជាអនុសាសន៍ថាឱ្យរដ្ឋាភិបាល "បង្កើន ឬចាប់ផ្តើមធ្វើអធិការកិច្ចការងារ ដោយពុំមានការប្រកាសមុនសម្រាប់វិជ្ជាជីវៈការងារដែលមានភាពងាយរងគ្រោះខ្ពស់ ជាពិសេសនៅតាមឡតដ្ឋ ទីតាំងកម្សាន្ត ការដ្ឋានសំណង់ និងចម្ការនានា ដោយផ្តោតលើការកំណត់រកបញ្ហាចំណងបំណុល និងការដាក់ឱ្យម្ចាស់អាជីវកម្មទទួលខុសត្រូវនៅចំពោះមុខច្បាប់"។ បញ្ហាផ្សេងទៀតដែលបានចង្អុលបង្ហាញនៅក្នុងរបាយការណ៍នេះគឺបង្ហាញថា ស្ត្រីមកពីជនបទដែលធ្វើដំណើរទៅកាន់សាធារណរដ្ឋប្រជាមានិតចិន ក្រោមហេតុផលរៀបអាពាហ៍ពិពាហ៍ជាមួយនឹងបុរសជនជាតិចិន។ ក្រោយមកស្ត្រីទាំងនេះ "ជំពាក់បំណុលមេខ្យល់ដែលជួយសម្របសម្រួលប្រតិបត្តិការនេះរាប់ពាន់ដុល្លារ ហើយបុរសទាំងនោះបង្ខំឱ្យស្ត្រីមួយចំនួនធ្វើការនៅតាមរោងចក្រ ឬកេងប្រវ័ញ្ចលើពួកគេឱ្យជួញដូរផ្លូវភេទដើម្បីសងបំណុល"។

ការជួញដូរស្ត្រីអោយធ្លាក់ចូលទៅក្នុងសេវាកម្មផ្លូវភេទដោយបង្ខំនៅក្នុងប្រទេសកម្ពុជាក៏នៅតែជាបញ្ហាដែរ។ យោងតាមរបាយការណ៍របស់ក្រសួងការបរទេសនេះក៏បានឱ្យដឹងដែរថា "ស្ត្រី និងក្មេងស្រីកម្ពុជា និងជនជាតិភាគតិចវៀតណាម ធ្វើចំណាកស្រុកពីជនបទមកទីក្រុង និងតំបន់ទេសចរណ៍នានាជាទីដែលក្រុមឧក្រិដ្ឋជនកេងប្រវ័ញ្ចពួកគេក្នុងការជួញដូរផ្លូវភេទនៅតាមកន្លែងរកស៊ីផ្លូវភេទ និងជាញឹកញាប់ គឺនៅតាមទីតាំងបម្រើសេវាផ្លូវភេទសម្ងាត់ ដូចជាបៀរហ្គាឌិន ហាងម៉ាស្សា ហាងកែសម្ផស្សទីតាំងខារ៉ាអូខេ កន្លែងលក់រាយ និងតាមទីតាំងនានាដែលមិនមែនជាកន្លែងពាណិជ្ជកម្ម។ ទោះជាបែបនេះក្តី គួរកត់សម្គាល់ថា មិនមែនគ្រប់ស្ត្រីទាំងអស់នៅក្នុងទីកន្លែងទាំងនេះត្រូវបានជួញដូរនោះទេ។ អ្នកខ្លះជាអ្នករកស៊ីផ្លូវភេទដោយយល់ព្រមស្ម័គ្រចិត្តផ្តល់សេវា។ ស្ត្រីទាំងនេះ រួមទាំងស្ត្រីប្តូរភេទផងដែរ គួរតែទទួលបានសិទ្ធិការងារប្រសើរជាងមុន និងលក្ខខណ្ឌការងារប្រកបដោយសុវត្ថិភាព ដែលចំណុចទាំងនេះអាចត្រូវបានពង្រឹងតាមរយៈការលុបចោលទោសព្រហ្មទណ្ឌចំពោះការងារផ្តល់សេវាផ្លូវភេទ។

## ១.៣. ការបៀតបៀន និងការរំលោភបំពានតាមអនឡាញ

ឆ្នាំ ២០២២ នាំមកនូវក្តីបារម្ភបន្ថែមទៀតជុំវិញបញ្ហាបៀតបៀនក្នុងមជ្ឈដ្ឋានអ៊ិនធឺណិត ជាពិសេសមកលើកុមារ ហើយរបាយការណ៍ថ្មីមួយដែលមានចំណងជើងថា៖ "គ្រោះថ្នាក់ប្រភេទថ្មីនៅកម្ពុជា" ដោយអង្គការ ECPAT, អាំងទែរប៉ូល និងអង្គការយូនីសេហ្វកម្ពុជា បានរកឃើញថា ក្នុងចំណោមកុមារ ១០ នាក់ មានជាង ១ នាក់ ដែលទទួលរងការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទតាមអនឡាញ។ [១១] របាយការណ៍នេះបានបញ្ជាក់ថា "ក្នុងមួយឆ្នាំកន្លងទៅ មាន ១១% នៃអ្នកប្រើប្រាស់អ៊ិនធឺណិត ដែលមានអាយុចាប់ពី ១២ ទៅ ១៧ ឆ្នាំ នៅក្នុងប្រទេសកម្ពុជា បានទទួលរងការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទតាមអនឡាញ ដែលក្នុងនោះរួមមានការគំរាមឱ្យកុមារចូលរួមក្នុងសកម្មភាពផ្លូវភេទ ចែករំលែករូបភាពអាសអាភាសដោយពុំមានការអនុញ្ញាត ឬបង្ខំឱ្យពួកគេចូលរួមក្នុងសកម្មភាពផ្លូវភេទដោយសន្យាថាផ្តល់លុយកាក់ ឬអំណោយផ្សេងៗ"។

“ធៀបនឹងចំនួនប្រជាជនជាអ្នកប្រើប្រាស់អ៊ិនធឺណែតនៅកម្ពុជា [ការសិក្សា] តំណាងឱ្យកុមារប្រមាណ ១៦០,០០០ នាក់ ដែលទទួលរងការរំលោភបំពានតាមអនឡាញទូទាំងប្រទេស។ មានកុមារតិចតួចណាស់ដែលរាយការណ៍ផ្លូវការណ៍ពីករណីទាំងនេះ ហើយឧបសគ្គចម្បងគឺថា កុមារភាគច្រើនបំផុតមិនដឹងថាតើត្រូវរាយការណ៍តាមវិធីណា ឬថាតើពួកគេគួរនិយាយជាមួយអ្នកណានោះទេ។

នៅក្នុងទិន្នន័យនៃការសិក្សាបានរកឃើញថា ការបៀតបៀន និងការរំលោភបំពានតាមអនឡាញជាញឹកញាប់ត្រូវបានរាយការណ៍ដោយក្មេងប្រុសច្រើនជាងក្មេងស្រី ប៉ុន្តែរបាយការណ៍ទៅតាមបណ្តាញទូរស័ព្ទទាន់ហេតុការណ៍ (ឯកសារស្តីពីការរំលោភបំពានផ្លូវភេទកុមារ) ពីឆ្នាំ២០១៧-២០១៩ ទាក់ទងនឹងក្មេងស្រី (៣៨%) ច្រើនជាងក្មេងប្រុស (២៧%)។ “ក្នុងចំណោមកុមារពេញវ័យ [ជាថ្មីម្តងទៀត] ក្មេងស្រីតំណាងឱ្យចំនួនលើសលុបរហូតដល់ទៅ ៧៧% នៃការរាយការណ៍”។

ថ្វីដ្បិតតែមានភាពចាំបាច់ដែលត្រូវមានច្បាប់ និងបទប្បញ្ញត្តិ ដើម្បីពិនិត្យតាមដាន និងដោះស្រាយឱ្យបានចំៗ និងមានប្រសិទ្ធភាពចំពោះការបៀតបៀនតាមអនឡាញ ប៉ុន្តែ ក្រុមហ៊ុនបណ្តាញសង្គម គួរតែពិចារណាពីតួនាទី និងទំនួលខុសត្រូវរបស់ខ្លួន និងចាត់វិធានការដើម្បីធានាសុវត្ថិភាពអ្នកប្រើប្រាស់ទូទាំងពិភពលោក។ ឧទាហរណ៍ ដូចដែលអ្នកឯកទេសផ្នែកសុវត្ថិភាពអនឡាញម្នាក់បានប្រាប់សារព័ត៌មានក្នុងស្រុក វីអូឌី (VoD) ថា យន្តការរាយការណ៍របស់ Facebook ពុំមានប្រសិទ្ធភាពឡើយក្នុងចំណោមអ្នកប្រើប្រាស់កម្ពុជា ដោយសារតែឧបសគ្គផ្នែកភាសាដែលរារាំងដល់ការសម្របសម្រួលមាតិកាឱ្យមានប្រសិទ្ធភាព។ [១២]

នៅខែតុលា ឆ្នាំ២០២២ ដោយមានក្តីបារម្ភ ចំពោះការបៀតបៀនផ្លូវភេទតាមអនឡាញដែលកើនឡើងខ្ពស់ក្នុងចំណោមកុមារ និងភាពខ្វះចន្លោះនៃច្បាប់ និងបទប្បញ្ញត្តិបច្ចុប្បន្ន អង្គការសង្គមស៊ីវិល បានជំរុញ ឱ្យមានការដាក់ទោសទណ្ឌធ្ងន់ធ្ងរជាងមុនសម្រាប់ករណីបៀតបៀនផ្លូវភេទតាមអនឡាញ។ [១៣, ១៤]

ជាចុងក្រោយ នៅក្នុងខែសីហា ឆ្នាំ២០២២ អង្គការសិទ្ធិមនុស្សលីកាដូ បានចងក្រងជាឯកសារពីរបៀបដែលបណ្តាញផ្តល់កម្ចីតាមអនឡាញ កំពុង “ផ្តោតគោលដៅលើស្ត្រីកម្ពុជាតាម Facebook និង Telegram ដោយដាក់អន្ទាក់ឱ្យពួកគេជាប់បំណុលកាន់តែច្រើនឡើង ហើយបានគំរាមកំហែងពួកគេ ដោយប្រើប្រាស់រូបថត និងវីដេអូអាក្រាតកាយ”។ [១៥] អង្គការលីកាដូ បានបញ្ជាក់ថា ក្រុមហ៊ុនបណ្តាញសង្គម និងអាជ្ញាធរកម្ពុជា បានបរាជ័យក្នុងការចាត់វិធានការ ដោយបានអនុញ្ញាតឱ្យក្រុមហុតឈាមជនរងគ្រោះនេះកេងប្រវ័ញ្ចលើស្ត្រីនានាដោយនិទណ្ឌភាព។

នៅមុននោះមួយឆ្នាំ អង្គការលីកាដូផ្តល់សេវាដល់ស្ត្រីចំនួនបីរូបដែលបានទទួលរងការបៀតបៀនពីអ្នកផ្តល់កម្ចីក្រៅផ្លូវការតាមអនឡាញ។ ស្ត្រីម្នាក់ៗសុទ្ធតែបានជួបប្រទះស្រដៀងៗគ្នា ដោយដំបូងឡើយស្ត្រីទាំងនោះបានខ្ចីប្រាក់សរុបត្រឹម ៥០ ដុល្លារដើម្បីទូទាត់ការចំណាយប្រចាំថ្ងៃ ឬថ្លៃថ្នាំសង្កូវពី

បណ្ដាក្រុមដែលបានផ្សាយពាណិជ្ជកម្មលើ Facebook ប៉ុន្តែនៅពេលដែលពួកគេត្រូវការប្រាក់កម្ចីបន្ថែម ក្រុមនោះ ដំបូងឡើយ បានទាមទារឱ្យពួកគេផ្ញើរូបថតស្រាតរបស់ខ្លួន។ បន្ទាប់មក អ្នកផ្ដល់កម្ចីបានគំរាម និងជំរិតទាប្រាក់ពីស្ត្រីទាំងនោះ ដោយបានគំរាមថា នឹងបញ្ចេញផ្សាយរូបថតទាំងនោះ ហើយបានទូរស័ព្ទរករឿងស្ត្រីទាំងនោះ ក្រុមគ្រួសារ និងមិត្តរួមការងាររបស់ពួកគេ។

តាមការបញ្ជាក់ពីអង្គការលីកាដូ ក្រុមមនុស្សគោលដៅដែលទទួលរងការយាយីទាំងនេះមានពាក់ព័ន្ធនឹងអំពើហិង្សាផ្អែកលើយេនឌ័រ។ ពួកគេធ្វើការកេងប្រវ័ញ្ចដោយផ្ដោតគោលដៅទៅលើស្ត្រី ហើយបង្កឱ្យមានផលប៉ះពាល់ផ្លូវចិត្ត និងសេដ្ឋកិច្ចថែមទៀតផង។ ជាងនេះទៅទៀត ទាំងការជំរិតទារប្រាក់ និងការគំរាម គឺជារឿងខុសច្បាប់ផ្អែកតាមក្រមព្រហ្មទណ្ឌរបស់ប្រទេសកម្ពុជា ហើយស្ត្រីទាំងបីនាក់បានដាក់ពាក្យបណ្ដឹងជាផ្លូវការដោយផ្ដល់ភស្ដុតាងយ៉ាងទូលំទូលាយ។ គិតមកត្រឹមខែសីហា ឆ្នាំ ២០០២ នេះ នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យានៃក្រសួងមហាផ្ទៃ នៅពុំទាន់បាននាំនរណាម្នាក់ឱ្យមកទទួលខុសត្រូវនៅឡើយទេ ។ ទោះបីជាកម្មវិធីទូរស័ព្ទចល័តដែលគេប្រើដើម្បីផ្ដោតគោលដៅមកលើស្ត្រីទាំងនោះលែងឃើញមានវត្តមានហើយក៏ដោយ ប៉ុន្តែក្រុមផ្ដល់កម្ចីអនឡាញនៅតែបន្តផ្ដោតលើគោលដៅ នឹងបៀតបៀនលើប្រជាពលរដ្ឋកម្ពុជាតាម Facebook និង Telegram ស្រដៀងគ្នានឹងករណីមុនៗដែរ។ ស្ត្រីម្នាក់ដែលបានរងការបៀតបៀនពីអ្នកផ្ដល់កម្ចីអនឡាញ បានបញ្ជាក់ប្រាប់ទៅអង្គការ លីកាដូថា ករណីបែបនេះគួរត្រូវបានចាត់ការជាបន្ទាន់ ដោយផ្ដល់យុត្តិធម៌ពេញលេញសម្រាប់ស្ត្រីរងគ្រោះ៖ “ខ្ញុំសូមស្នើឱ្យនាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យាជួយពន្លឿនពាក្យបណ្ដឹងរបស់ខ្ញុំ និងពាក្យបណ្ដឹងរបស់ជនរងគ្រោះផ្សេងទៀត”។

## ១.៤. លទ្ធភាពស្វែងរកយុត្តិធម៌ និងការប្រើប្រាស់មិនត្រឹមត្រូវនូវយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (ADR) នៅក្នុងករណីអំពើហិង្សាផ្អែកលើយេនឌ័រ

ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (ADR) ត្រូវបានប្រើប្រាស់ជាមធ្យោបាយដោះស្រាយករណីអំពើហិង្សាក្នុងគ្រួសារនៅក្នុងប្រទេសកម្ពុជាជាយូរមកហើយនៅក្រៅប្រព័ន្ធតុលាការផ្លូវការ បើទោះបីជាការអនុវត្តនេះទទួលរងការរិះគន់ពីគណៈកម្មាធិការស៊ី-ដ ក៏ដូចជាអ្នកតស៊ូមតិសិទ្ធិស្ត្រីក្នុងប៉ុន្មានឆ្នាំថ្មីៗនេះក៏ដោយ។ [១៦] នៅក្នុងខែមករា ឆ្នាំ២០២២ រដ្ឋបាលខេត្តកំពង់ឆ្នាំងបានធ្វើសន្និសីទសារព័ត៌មានមួយដែលបង្ហាញថាអាជ្ញាធរបានទទួលករណីចំនួន ៧១៦ ករណី រួមទាំងករណីអំពើហិង្សាក្នុងគ្រួសារកាលពីឆ្នាំកន្លងទៅផងដែរ។[១៧] ក្នុងចំណោម ៧១៦ ករណីនេះ មាន ៥៨៩ ករណី ត្រូវបានគេរាយការណ៍ថាបានដោះស្រាយដោយប្រើនូវវិធីដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការចំនួនពីរផ្សេងគ្នា។

ប្រធានក្រុមប្រឹក្សាខេត្តបានរាយការណ៍ថា បានអនុវត្តយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការដោយខ្លួនឯងតាមរយៈការរៀបចំកិច្ចប្រជុំជាសាធារណៈដើម្បីដោះស្រាយវិវាទមួយចំនួន។ ទោះជាយ៉ាងណាក៏ដោយក៏ក្នុងករណីភាគច្រើន អភិបាលខេត្តកំពង់ឆ្នាំង និងប្រធានក្រុមប្រឹក្សាខេត្តបានចុះទៅដល់ផ្ទះប្រជាពលរដ្ឋដើម្បីជួបជាមួយក្រុមគ្រួសារប្រជាពលរដ្ឋដែលជាប់ពាក់ព័ន្ធក្នុងជម្លោះតែម្តង។ ការធ្វើដូច្នេះគឺស្រដៀងគ្នាទៅនឹងទម្លាប់អនុវត្តពីមុនមក ដែលគេប្រើពាក្យថា “សម្រុះសម្រួល” ដែលជាញឹកញាប់ត្រូវបានបកប្រែខុសជាភាសាអង់គ្លេសថា “សន្ទានកម្ម”/សម្រុះសម្រួល (Mediation) ហើយជារឿយៗត្រូវបានប្រើប្រាស់ខុសទាំងអត្ថន័យ និងការអនុវត្ត។ [18] ការអនុវត្តបច្ចុប្បន្ន ជាពិសេស

ចំពោះដៃគូស្និទ្ធស្នាល (IPV) វិធីសាស្ត្រដែលយកមកប្រើប្រាស់ស្ទើរតែទាំងស្រុងនោះគឺ ការផ្សះផ្សា និង/ឬអាជ្ញាកណ្តាល ក្នុងករណីរំលោភសិទ្ធិស្ត្រី ដែលចាំបាច់ត្រូវតែមានការកែទម្រង់ជាបន្ទាន់។

ជាការល្អដែលប្រធានក្រុមប្រឹក្សាខេត្តទទួលស្គាល់ថា វាជារឿងសំខាន់ដែលករណីផ្សេងៗពាក់ព័ន្ធនឹងការរំលោភបំពានលើស្ត្រី និងកុមារ មិនត្រូវបានបង្វែរទៅរកការដោះស្រាយតាមសន្ទានកម្ម/សម្រុះសម្រួល ការផ្សះផ្សា ឬវិធីផ្សេងទៀតនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ប៉ុន្តែផ្ទុយមកវិញ ត្រូវបានដោះស្រាយតាមផ្លូវច្បាប់ដែលផ្តល់ការគាំទ្រ និងយុត្តិធម៌សម្រាប់ជនរងគ្រោះ។ គាត់បានបញ្ជាក់ថា គាត់បានបញ្ជូនករណីដូចគ្នានេះចំនួន ៦ ទៅតុលាការ ព្រោះករណីទាំងនោះជារឿងព្រហ្មទណ្ឌ។

ទោះយ៉ាងណា គេនៅមិនទាន់ដឹងច្បាស់នៅឡើយទេថា តើសំណុំរឿងដែលបានដោះស្រាយរួចទាំងនេះមានចំនួនប៉ុន្មានករណីដែលអាចជាប់ពាក់ព័ន្ធនឹងអំពើហិង្សាក្នុងគ្រួសារ ហើយដែលគួរតែត្រូវបានបញ្ជូនទៅតុលាការ។ ដូចគ្នានេះដែរ គេមិនច្បាស់ទេថាតើករណីអំពើហិង្សាក្នុងគ្រួសារណាខ្លះដែលប្រើយន្តការដោះស្រាយក្រៅប្រព័ន្ធតុលាការ ដែលត្រូវបាន "ដោះស្រាយរួច" ក្នុងទីសាធារណៈ។ បើដូច្នេះមែន ការធ្វើដូចនេះនឹងនាំឲ្យមានការបន្ទទម្លាប់អនុវត្តដែល NGO-CEDAW ធ្លាប់បានលើកឡើងតាំងពីមុនមកថាមិនសមស្រប និងមិនបានផ្តល់នូវដំណោះស្រាយឲ្យឆ្លើយតបដោយផ្តោតលើយេនឌ័រ និងការរៀបចំដោយយកជនរងគ្រោះជាគោលនោះទេ ។ ការណ៍នេះដូចគ្នាទៅនឹងករណីដែលអភិបាលខេត្តពោធិ៍សាត់កាលពីឆ្នាំ ២០២០ បានផ្សះផ្សាគូស្វាមីភរិយាមួយគូនៅក្នុងវេទិកាសាធារណៈឱ្យបន្តស្ថិតនៅក្នុងចំណងអាពាហ៍ពិពាហ៍របស់ខ្លួនដដែល បើទោះបីជាភាគីខាងស្រី និងម្តាយរបស់នាងបានរាយការណ៍ថា ប្តីរបស់ខ្លួនបានប្រើហិង្សាលើរូបរាងកាយរបស់នាង ហើយនាងមានបំណងចង់លែងលះក៏ដោយ។ [១៩]

ករណីអំពើហិង្សាក្នុងគ្រួសារទាំងអស់គួរតែត្រូវបានដោះស្រាយតាមផ្លូវច្បាប់ដែលផ្តល់ការគាំទ្រ និងយុត្តិធម៌សម្រាប់ជនរងគ្រោះ។ នេះជារឿងសំខាន់ខ្លាំងណាស់ ពីព្រោះក្នុងការអនុវត្តជាក់ស្តែង "សន្ទានកម្ម" សម្រុះសម្រួល ដែលធ្វើឡើងរវាងគូស្វាមីភរិយានៅក្នុងប្រទេសកម្ពុជា ជាញឹកញាប់គឺប្រៀបបាននឹងការផ្សះផ្សា ៖ ភាពខុសគ្នារវាងចំណុចទាំងនេះគឺមានសារៈសំខាន់ ដោយហេតុថា "សន្ទានកម្ម" សម្រុះសម្រួល មានគោលបំណងផ្តល់ផ្លូវឆ្ពោះទៅមុខ ដែលទទួលការពេញចិត្តសម្រាប់ភាគីទាំងពីរ ចំណែកឯ "ការផ្សះផ្សា" ធ្វើឡើងក្នុងគោលបំណងជំរុញឱ្យគូស្វាមីភរិយាបន្តស្ថិតក្នុងចំណងអាពាហ៍ពិពាហ៍។

នៅខែកក្កដា ឆ្នាំ២០២១ ក្រុមការងារបច្ចេកទេសឆ្លើយតបលើអំពើហិង្សាផ្អែកលើយេនឌ័រ (TWG-GBV) បានបោះឆ្នោតអនុម័តគោលការណ៍ណែនាំ ស្តីពីការកម្រិតការប្រើប្រាស់ការសម្រុះសម្រួលឆ្លើយតបចំពោះអំពើហិង្សាលើស្ត្រី (គោលការណ៍ណែនាំ)។ គោលការណ៍ណែនាំនេះ បានណែនាំមិនឱ្យអាជ្ញាធរមូលដ្ឋាន រួមទាំងមន្ត្រីនគរបាលផង ធ្វើការផ្សះផ្សា ឬធ្វើជាអាជ្ញាកណ្តាល ចំពោះទម្រង់ណាមួយនៃអំពើហិង្សាលើស្ត្រីនោះឡើយ។ ទោះបីជាយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការក្នុងទម្រង់ជាការសម្រុះសម្រួល ត្រូវបានអនុញ្ញាតជាលក្ខណៈបច្ចេកទេស នៅក្នុងគោលការណ៍ណែនាំនេះក្តី ប៉ុន្តែគោលការណ៍ណែនាំទាំងនេះតម្រូវឱ្យមានស្តង់ដារសីលធម៌តឹងរ៉ឹង រួមទាំងការត្រួតពិនិត្យសុវត្ថិភាពម្តងហើយម្តងទៀតដោយមិនអនុញ្ញាតឱ្យមានការធ្វើការសម្រុះសម្រួលណាមួយឡើយ ករណីដែលអាចធ្វើទៅបានលុះត្រាណាតែមានការអនុញ្ញាតពីច្បាប់ដែលមានស្រាប់ប៉ុណ្ណោះ

ហើយថែមទាំងសមស្របផងដែរទៅតាមបទដ្ឋាន និងនីតិវិធីសិទ្ធិមនុស្ស។ ក្នុងស្ថានភាពណាមួយដែលស្ត្រី ឬកុមារមានហានិភ័យអាចរងអំពើហិង្សា ត្រូវធ្វើការបញ្ឈប់នូវយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ហើយធ្វើការចេញដីកាការពារ និង/ឬសេចក្តីសម្រេចរដ្ឋបាល ដើម្បីទប់ស្កាត់អំពើហិង្សា រួចបញ្ជូនសំណុំរឿងនេះទៅតុលាការ និងអ្នកផ្តល់សេវាសមស្របផ្សេងៗទៀតដល់ ជនរងគ្រោះ។

នៅឆ្នាំ២០២២ ក្រសួងកិច្ចការនារី ក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃបានចាប់ផ្តើមព្រៀង ប្រកាសអន្តរក្រសួង (បទប្បញ្ញត្តិ) ហើយបានប្រកាសជាសាធារណៈអំពីផែនការរបស់ខ្លួនក្នុងការផ្សព្វផ្សាយ និងអនុវត្តគោលការណ៍ណែនាំស្តីពីការសម្រុះសម្រួល។ រដ្ឋាភិបាលក៏ត្រូវធានាថា មានមូលនិធិដែលចេញថវិកាជាតិត្រូវបានលៃទុកសម្រាប់ការផ្សព្វផ្សាយ និងការអនុវត្ត ប្រកាស និងគោលការណ៍ណែនាំនានាឱ្យមានប្រសិទ្ធភាព ដើម្បីបញ្ចប់នូវការអនុវត្តខុសក្រមសីលធម៌នៅក្នុងសហគមន៍។

ជារឿងសំខាន់ដែលត្រូវកត់សម្គាល់ថា គោលការណ៍ណែនាំស្តីពីការសម្រុះសម្រួលដែលអនុម័តនោះគ្រាន់តែជាវិធានការបណ្តោះអាសន្ននៃការលើកកម្ពស់សុវត្ថិភាពរបស់ស្ត្រីនៅក្នុងបរិបទច្បាប់នាពេលបច្ចុប្បន្នប៉ុណ្ណោះ។ ការអនុវត្តគោលការណ៍ណែនាំទាំងនោះនឹងមានការលំបាកក្នុងបរិបទដែលខ្វះខាតហេដ្ឋារចនាសម្ព័ន្ធផ្លូវច្បាប់ និងរូបវ័ន្ត ដើម្បីធានាបាននូវការអនុវត្តដែលផ្តោតលើជនរងគ្រោះ និងលទ្ធភាពដែលអាចប្រើប្រាស់ប្រព័ន្ធតុលាការបានជាសកល។ គោលការណ៍ណែនាំទាំងនេះ មិនមែនប្រើប្រាស់ដើម្បីជំនួសអោយការធ្វើវិសោធនកម្ម និងកែលម្អច្បាប់នានាឡើងវិញនោះទេ ដូចជាការធ្វើបច្ចុប្បន្នភាពលើក្រមព្រហ្មទណ្ឌ និងច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ដើម្បីអោយមានភាពអនុលោមតាមស្តង់ដារអន្តរជាតិនោះទេ។ គោលការណ៍ណែនាំទាំងនេះក៏មិនមែនសម្រាប់ប្រើប្រាស់ជំនួសអោយការកាត់ទោសលើសំណុំរឿងព្រហ្មទណ្ឌនោះទេ ហើយក៏មិនអាចពង្រីកលទ្ធភាពក្នុងការប្រើប្រាស់ប្រព័ន្ធផ្លូវច្បាប់នោះដែរ ដូច្នេះ យន្តការសម្រុះសម្រួលគឺមិនមែនជាជម្រើសសម្រាប់ការអនុវត្តតែមួយមុខនោះទេ។

គួរឱ្យកត់សម្គាល់ថា បរិបទបច្ចុប្បន្នគឺជាបរិបទមួយ ដែលអាជ្ញាធរមូលដ្ឋាន រួមទាំងមន្ត្រីនគរបាលផងមានទម្លាប់យូរមកហើយក្នុងការប្រើប្រាស់វិធីផ្សះផ្សា គួបផ្សំជាមួយនឹងវិធីជាអាជ្ញាកណ្តាលក្នុងការដោះស្រាយវិវាទក្នុងគ្រួសារគ្រប់ប្រភេទ រួមទាំងអំពើហិង្សាលើស្ត្រី ដើម្បី “ការការពារភាពសុខដុម រមនា” នៅក្នុងសហគមន៍ ដែលជារឿយៗ នាំឱ្យបាត់បង់សិទ្ធិ និងស្វ័យភាពរបស់ស្ត្រី។

នៅខែតុលា ឆ្នាំ២០២២ ក្រសួងយុត្តិធម៌ក៏បានប្រកាសអំពីផែនការបង្កើតអង្គភាពអ្នកជំនាញសម្រុះសម្រួល ដើម្បីដោះស្រាយវិវាទក្រៅតុលាការដោយផ្តោតលើសំណុំរឿងរដ្ឋប្បវេណី និងបទលហុ។ [២០] តាមការរាយការណ៍ ក្រុមការងាររបស់ក្រសួងកំពុងរៀបចំសេចក្តីព្រាងគោលនយោបាយ ច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងៗ ដោយធ្វើឡើងដោយអង្គភាពនេះ ហើយគ្រោងថានឹងចាប់ផ្តើមបើកដំណើរការជាផ្លូវការនៅឆ្នាំ២០២៤។ គោលបំណងនៃការបង្កើតអង្គភាពនេះគឺដើម្បីលើកកម្ពស់លទ្ធភាពទទួលបានសេវាសម្រុះសម្រួល ដោយក្នុងនោះរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ លោក កើត រិទ្ធ មានប្រសាសន៍ថា ការធ្វើដូចនេះនឹង “នាំសេវាយុត្តិធម៌កាន់តែជិតប្រជាពលរដ្ឋរស់នៅជនបទ... កាត់បន្ថយសំណុំរឿងកកស្ទះនៅក្នុងតុលាការ ផ្តល់ភាពសុខដុមរមនាកាន់តែខ្លាំងជាងមុនក្នុងចំណោមក្រុមគ្រួសារខ្មែរ ដែលក្នុងនោះភាគីជម្លោះ ទទួលបានដំណោះស្រាយឈ្នះឈ្នះ»។

គោលបំណងទាំងនេះជារឿងគួរឱ្យសរសើរ ប៉ុន្តែគួរតែមានការបញ្ជាក់ឱ្យបានច្បាស់លាស់ទាំងនៅក្នុងគោលនយោបាយ និងការអនុវត្តជាក់ស្តែងថា "ជម្លោះគ្រួសារ" ដែលអង្គភាពនេះគ្រោងនឹងដោះស្រាយមិនរាប់បញ្ចូលករណីអំពើហិង្សាក្នុងគ្រួសារ ដែលត្រូវបានរាយការណ៍នោះទេ។ [២១]

ជាងនេះទៅទៀត ចំពោះករណីរំលោភសេពសន្ថវៈមិនត្រូវមានការផ្សះផ្សា ឬសម្រុះសម្រួលនោះទេ ប៉ុន្តែទម្លាប់អនុវត្តបែបនេះបានបន្តកើតមាននៅតាមតំបន់ជាច្រើននៅក្នុងប្រទេសក្នុងឆ្នាំ២០២២ ដូចមានបង្ហាញក្នុងករណីមួយនៅក្នុង ផ្នែក ១.៧.៣ នៃរបាយការណ៍នេះ (ករណីស្ត្រីមានពិការភាព)។ ទន្ទឹមនឹងនេះ អង្គការលីកាដូ ក៏បានរកឃើញភស្តុតាងនៃការអនុវត្តបែបនេះក្នុងករណីនានាដែលអង្គការលីកាដូ បានស៊ើបអង្កេតក្នុងឆ្នាំ ២០២២ នេះដែរ។

ករណីអំពើហិង្សាផ្លូវភេទត្រូវបានបន្តដោះស្រាយតាមរយៈការទូទាត់សំណងក្រៅប្រព័ន្ធតុលាការដោយមានការសម្របសម្រួលដោយអាជ្ញាធរ រួមទាំងមន្ត្រីនគរបាល ដែលបន្ទាប់មកគឺជាអ្នកធានាថាដំណើរការកាត់ទោសព្រហ្មទណ្ឌត្រូវបានទម្លាក់ចោល ឬបញ្ចប់។ ជាងនេះទៅទៀត ក្នុងករណីរំលោភសេពសន្ថវៈមួយចំនួនតូច ប៉ុន្តែគួរឱ្យព្រួយបារម្ភនោះ ក្មេងស្រីត្រូវបានសម្របសម្រួលអោយរៀបការជាមួយជនល្មើសដោយពុំទទួលបានយុត្តិធម៌ទាល់តែសោះ។

អង្គការលីកាដូ បានធ្វើការចងក្រងឯកសារដែលបង្ហាញថា លក្ខខណ្ឌតម្រូវសម្រាប់ទទួលបានការធ្វើកោសល្យវិច្ច័យ និងភស្តុតាងផ្នែកវេជ្ជសាស្ត្រនោះ គឺមិនមានភាពស៊ីសង្វាក់គ្នាឡើយនៅទូទាំងបណ្តាខេត្តនានាក្នុងឆ្នាំ ២០២២ ហើយជាហានិភ័យដែលរារាំងស្ត្រី និងក្មេងស្រីមិនឱ្យទទួលបានភស្តុតាងទាំងនោះ។ ជាញឹកញាប់ តុលាការ ដាក់បន្ទុកលើសលប់លើភស្តុតាងកោសល្យវិច្ច័យនៅក្នុងសំណុំរឿងអំពើហិង្សាផ្លូវភេទ ហើយបើគ្មានភស្តុតាងទាំងនោះទេ អាចមានការពិបាកក្នុងការទទួលបានយុត្តិធម៌។ ប៉ុន្តែនៅតាមបណ្តាខេត្តជាច្រើន ការពិនិត្យកោសល្យវិច្ច័យត្រូវបានគេរាយការណ៍ថា អាចដំណើរការទៅបាន លុះត្រាតែមានការយល់ព្រម ឬមានវត្តមានមន្ត្រីនគរបាល ឬអាជ្ញាធរផ្សេងទៀត។ ការធ្វើដូច្នេះ អាចជាការរារាំងស្ត្រី និងក្មេងស្រីមិនឱ្យទទួលបានភស្តុតាងទៅតាមឆន្ទានុសិទ្ធិរបស់អាជ្ញាធរឡើយ។

## ១.៥. ឃាតកម្មដោយដៃគូស្និទ្ធស្នាល

ក្នុងអំឡុងឆ្នាំ២០២២ អង្គការលីកាដូបានស៊ើបអង្កេតករណីឃាតកម្មលើស្ត្រីចំនួន ១១ នាក់ ដោយដៃគូស្និទ្ធស្នាលបច្ចុប្បន្ន ឬអតីតដៃគូស្និទ្ធស្នាល។ នៅក្នុងរបាយការណ៍ដែលបានចេញផ្សាយក្នុងខែមីនា ឆ្នាំ២០២៣ អង្គការលីកាដូ បានពិនិត្យលើករណីឃាតកម្មចំនួន ២៦ ករណី ដែលប្រព្រឹត្តដោយដៃគូស្និទ្ធស្នាលចន្លោះពីខែមករា ឆ្នាំ ២០២០ ដល់ខែមិថុនា ឆ្នាំ ២០២២។[២២] យ៉ាងហោចណាស់ពាក់កណ្តាលនៃស្ត្រីដែលត្រូវបានសម្លាប់ គឺបានជួបប្រទះអំពើហិង្សាលើរាងកាយពីមុនមក ប៉ុន្តែនៅក្នុងរបាយការណ៍នេះក៏បានរកឃើញថាដែរថា ផ្នត់គំនិតយេនឌ័រចាក់ឫស និងការខ្វះទំនុកចិត្តលើអាជ្ញាធរនៅតែរារាំងស្ត្រីមិនឱ្យស្វែងរកជំនួយ។ ដំបូងឡើយ អង្គការលីកាដូ បានចងក្រងជាឯកសារសម្រាប់ករណីទាំង ២៦ នេះ បន្ទាប់ពីស្ត្រីទាំងនោះបានស្លាប់ ហើយព័ត៌មានអំពីបទពិសោធន៍នៃការឆ្លងកាត់អំពើហិង្សាកាលពីមុន និងអំពើហិង្សាប្រភេទផ្សេងទៀតដែលពួកគេជួបប្រទះ មិនអាចរកបានទេក្នុងករណីមួយចំនួន។

ឧបសគ្គសង្គម ផ្លូវច្បាប់ និងហិរញ្ញវត្ថុ សម្រាប់ការលែងលះ និងការចែកផ្លូវគ្នា និងទំនោរក្នុងការផ្តល់ការផ្សះផ្សាចំពោះករណីអំពើហិង្សាក្នុងគ្រួសារ បានធ្វើឱ្យស្ត្រីមួយចំនួនមិនអាចចាកចេញពីដៃគូហិង្សាបានឡើយ។ ក្នុងករណីជាច្រើន អាជ្ញាធរបានដឹងពីអំពើហិង្សាដែលកំពុងកើតឡើង ប៉ុន្តែពួកគាត់អាចថាមិនអើពើ ឬព្យាយាមផ្សះផ្សាគូស្វាមីភរិយាទាំងនោះ។ នៅក្នុងករណីទាំងនេះ ភាពបរាជ័យរបស់អាជ្ញាធរក្នុងការសម្របសម្រួលឱ្យមានការលែងលះ សម្របសម្រួលដល់ការដាក់ពាក្យបណ្តឹងព្រហ្មទណ្ឌ ឬផ្តល់ការគាំពារផ្សេងៗ ជាហេតុធ្វើឱ្យស្ត្រីទាំងនោះស្លាប់បាត់បង់ជីវិត។ ក្នុងករណីទាំងអស់នេះ ផលប៉ះពាល់លើកុមារក៏មានភាពធ្ងន់ធ្ងរផងដែរ ក្នុងនោះ មិនមែនត្រឹមតែកុមារ ៥ នាក់ត្រូវបានសម្លាប់ប៉ុណ្ណោះទេ ប៉ុន្តែយ៉ាងហោចណាស់កុមារ ៨ នាក់បានមើលឃើញឃាតកម្មផងដែរ។

## ១.៦. អំពើហិង្សា និងការបៀតបៀនលើស្ត្រីកម្មករនិយោជិត

អំពើហិង្សាផ្អែកលើយេនឌ័រនៅកន្លែងធ្វើការបានបន្តកើតមាននៅឆ្នាំ ២០២២។ អង្គការលីកាដូបានសម្ភាសន៍ស្ត្រីអ្នកដឹកនាំសហជីព និងសកម្មជនសិទ្ធិការងារចំនួនប្រាំមួយរូបក្នុងខែតុលា ឆ្នាំ ២០២២ ដែលតំណាងឱ្យកម្មកររោងចក្រ ស្ត្រីបម្រើសេវាផ្លូវភេទ បុគ្គលិកសេវាកម្មអាហារ បុគ្គលិកកាស៊ីណូ គ្រូបង្រៀន អ្នកបើកម៉ូតូកង់បី អ្នកធ្វើការងារតាមផ្ទះ និងការងារផ្សេងទៀត។ ទោះបីជាពួកគេតំណាងឱ្យវិស័យផ្សេងៗគ្នាក៏ដោយ ប៉ុន្តែសកម្មជនទីមួយៗបានរាយការណ៍ថា សមាជិករបស់ខ្លួនប្រឈមនឹងការបៀតបៀនផ្លូវភេទ ឬទម្រង់ផ្សេងទៀតនៃអំពើហិង្សាផ្អែកលើយេនឌ័រនៅកន្លែងធ្វើការ ពីសំណាក់អាជ្ញាធរ និងនិយោជក ដែលញឹកញាប់មិនបានចាត់វិធានការ ហើយទុកឱ្យអំពើហិង្សាបន្តកើតមានដោយនិទណ្ឌភាព។[២៣]

លើសពីនេះទៀត ចាប់ពីចុងឆ្នាំ ២០២១ និងពេញមួយឆ្នាំ ២០២២ អំពើហិង្សាដែលគាំទ្រដោយរដ្ឋ និងការបៀតបៀនលើស្ត្រីជានិយោជិត និងសកម្មជនសិទ្ធិការងារបានកើនឡើងកាន់តែខ្លាំង។ ករណីលេចធ្លោបំផុតគឺការបង្ក្រាបកូដកម្មសន្តិវិធីដែលដឹកនាំដោយស្ត្រី ប្រឆាំងនឹងកាស៊ីណូណាហ្គាវើលដ៍ (Naga World)។ នៅឆ្នាំ២០២១ កាស៊ីណូនេះ បានបញ្ឈប់កម្មកររបស់ខ្លួនជាច្រើននាក់ ដែលប៉ះពាល់ដោយមិនស្មើភាពគ្នាលើស្ត្រីមានផ្ទៃពោះ ស្ត្រីបំបៅដោះកូន និងសមាជិកសហជីពជាស្ត្រី។ អំពើហិង្សា និងការបំភិតបំភ័យដល់ស្ត្រីកម្មករនិយោជិត ក៏ដូចជាការឃុំខ្លួន/ដាក់ពន្ធនាគារដោយបំពានលើស្ត្រីជាអ្នកការពារសិទ្ធិមនុស្ស មានរៀបរាប់លម្អិតនៅក្នុងផ្នែក ៣.១ នៃរបាយការណ៍នេះ។ ទោះជាយ៉ាងណា បញ្ហានេះក៏សំខាន់ក្នុងការលើកឡើងនៅត្រង់ចំណុចនេះដោយហេតុថាចរិកលក្ខណៈនៃការយាយីលើយេនឌ័របែបនេះ ក៏គួរទទួលស្គាល់ថាជាអំពើហិង្សាផ្អែកលើយេនឌ័រផងដែរ ៖

*"អាជ្ញាធរបានរុញ និងអូសក្រុមបាតុករ ហើយត្រូវបានចោទប្រកាន់ពីបទបៀតបៀនផ្លូវភេទ។ សាលាក្រុងបានស្តីបន្ទោសក្រុមបាតុករ ដោយនិយាយថា ពួកគេកំពុងសម្តែង ហើយអាកប្បកិរិយារបស់ពួកគេ "មិនស័ក្តិសមជាស្ត្រីខ្មែរ"។[២៤]*

អង្គការផ្នែកសុខភាពក្នុងស្រុកមួយ គឺអង្គការថែទាំសុខភាពគ្រួសារកម្ពុជា (អង្គការ រ៉ាក់) ក៏បានធ្វើការស្រាវជ្រាវលើការបៀតបៀនមកលើស្ត្រីកម្មករនិយោជិតនៅឆ្នាំ២០២២ ផងដែរ ដោយបានចេញផ្សាយការសិក្សាមួយក្រោមចំណងជើងថា "ការបៀតបៀន និងអំពើហិង្សាលើស្ត្រីនៅកន្លែងធ្វើការៈ ការវិភាគស្ថានភាពនៃការបៀតបៀនផ្លូវភេទលើស្ត្រីកម្មកររោងចក្រកាត់ដេរនៅឆ្នាំ២០២២"។ [២៥] ការសម្ភាសន៍ជាមួយកម្មកររោងចក្រកាត់ដេរចំនួន ១១៨០ នាក់ (៨៥% ជាស្ត្រី ហើយ ១៥% ជាបុរស) បានបង្ហាញថា មានតែ ៦.៣៥% ប៉ុណ្ណោះ ដែលពុំធ្លាប់លឺ ឬពុំធ្លាប់ឃើញការបៀតបៀនផ្លូវភេទនៅក្នុងរោងចក្រ ខណៈដែល ៩៣.៦៥% រាយការណ៍ថា ធ្លាប់បានលឺ ឬឃើញការបៀតបៀនផ្លូវភេទៈ ក្នុងនោះ កម្រមាន (៣១.០៦%) ម្តងម្កាល មាន (៤៨.២៤%) ឬញឹកញាប់មាន (១៤.៣៥%)។ ក្នុងចំណោមអ្នកឆ្លើយសំណួរទាំងនេះ មានរហូតដល់ទៅ ៩៦.៤៧% រាយការណ៍ថា ជាធម្មតា "ពុំមានអន្តរាគមន៍" ទេ បន្ទាប់ពីកើតមានឧប្បត្តិហេតុនៃការបៀតបៀនផ្លូវភេទនេះ ហើយ ២.៥៩% រាយការណ៍ថា ជាធម្មតា មានការសម្រុះសម្រួល ផ្ទៃក្នុង ហើយមានតែ ០.៩៤% ប៉ុណ្ណោះ ដែលបង្ហាញថាមានការរាយការណ៍ទៅមន្ត្រីនគរបាល។

អ្នកឆ្លើយតបចំនួន ១៤.០៦% បានរាយការណ៍ ថាបានឆ្លងកាត់ដោយផ្ទាល់នូវការបៀតបៀន ដែលកើតឡើងនៅក្នុងរោងចក្រក្នុងអំឡុងពេល ១២ ខែចុងក្រោយនេះ ហើយជារឿងគួរឱ្យព្រួយបារម្ភដែលអ្នកឆ្លើយតបរហូតដល់ទៅ ៤១% ត្រូវបានរាយការណ៍ថាបានឆ្លងកាត់ ឬបានឃើញអំពើហិង្សាលើដៃគូស្និទ្ធស្នាល ឬអំពើហិង្សាលើស្ត្រី ក្នុងចំណោមកម្មកររោងចក្រកាត់ដេរ ដែលជាធម្មតាកើតមាននៅខាងក្រៅ កន្លែងធ្វើការ (៨៧.៧%) ជាជាងនៅក្នុងរោងចក្រ (១២.៣%)។

ទោះបីជា អ្នកឆ្លើយតបចំនួន ៨០.៤២% បានរាយការណ៍ថារោងចក្ររបស់ខ្លួនមានគោលនយោបាយសម្រាប់រាយការណ៍អំពីការបៀតបៀនផ្លូវភេទក៏ដោយ ប៉ុន្តែ ក្នុងចំណោមអ្នកដែលបានឆ្លងកាត់ ឬបានឃើញការបៀតបៀនផ្លូវភេទ មានតែ ២៤.៧៥% ប៉ុណ្ណោះដែលបានរាយការណ៍ពីករណីនោះ។ ក្នុងចំណោមនោះ មានតែ ១៦% ប៉ុណ្ណោះបានរាយការណ៍ថាមាន ឬនឹងមានការស៊ើបអង្កេត ហើយចំនួនដូចគ្នានេះដែរ (១៦%) បានរាយការណ៍ពីជំនឿចិត្តថា "មាន/នឹងមានការផ្តន្ទាទោសគ្រប់គ្រាន់ទៅលើជនល្មើស"។ ផ្ទុយទៅវិញ ២០% បានរាយការណ៍ថាមិនមានលទ្ធផលអ្វីនោះទេ បន្ទាប់ពីពួកគេបានរាយការណ៍ករណីនៃការបៀតបៀនផ្លូវភេទនោះ។

នៅក្នុងសេចក្តីអង្កេតសន្និដ្ឋាន ឆ្នាំ២០១៩ របស់គណៈកម្មាធិការទទួលបន្ទុកអនុសញ្ញាស៊ីដ (គណៈកម្មាធិការ) បានកត់សម្គាល់ថាប្រទេសកម្ពុជាខ្វះ "ច្បាប់គ្រប់ជ្រុងជ្រោយមួយ ដែលកំណត់ច្បាស់លាស់ និងហាមឃាត់ប្រកបដោយប្រសិទ្ធភាពនូវអំពើហិង្សា និងការបៀតបៀន រួមទាំងការបៀតបៀនផ្លូវភេទនៅកន្លែងធ្វើការ ដែលត្រូវបានគេរាយការណ៍ថាកើតមានជាទូទៅ... ជាពិសេសនៅក្នុងឧស្សាហកម្មកាត់ដេរ និងពេលធ្វើដំណើរទៅមកពីកន្លែងធ្វើការ" [កថាខណ្ឌ ៣៦]។ គណៈកម្មាធិការបានផ្តល់អនុសាសន៍ថា រាជរដ្ឋាភិបាលកម្ពុជាគួរអនុម័ត និងអនុវត្តច្បាប់គ្រប់ជ្រុងជ្រោយដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សា និងការបៀតបៀន រួមទាំងការបៀតបៀនផ្លូវភេទនៅកន្លែងធ្វើការ និងបង្កើតយន្តការបណ្តឹងឯករាជ្យ ដើម្បីធានាថាជនរងគ្រោះមានលទ្ធភាពទទួលបានសំណងប្រកបដោយប្រសិទ្ធភាព ហើយជនល្មើសត្រូវបាននាំយកមកឱ្យទទួលខុសត្រូវចំពោះទង្វើរបស់គេ។ គណៈកម្មាធិការក៏បានផ្តល់អនុសាសន៍បន្ថែមទៀតថា រដ្ឋាភិបាលគួរផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីអំពើហិង្សា និងការបៀតបៀនរបស់អង្គការពលកម្មអន្តរជាតិ ឆ្នាំ២០១៩ (លេខ ១៩០)។

ខណៈដែលយើងធ្វើការកត់សម្គាល់ជាវិជ្ជមានចំពោះរាជរដ្ឋាភិបាលកម្ពុជា ដែលបានបោះឆ្នោតអនុម័តលើអនុសញ្ញាលេខ ១៩០ របស់អង្គការពលកម្មអន្តរជាតិ (ILO C ១៩០) នៅទីក្រុងហ្សឺណែវ ក្នុងខែមិថុនា ឆ្នាំ២០១៩ ក្តី ប៉ុន្តែប្រទេសកម្ពុជាមិនទាន់ផ្តល់សច្ចាប័នលើអនុសញ្ញានេះនៅឡើយ។ តំណាងរបស់រាជរដ្ឋាភិបាលកម្ពុជា បាននិយាយជាសាធារណៈថា រដ្ឋាភិបាលកំពុងពិចារណាលើជំហានឆ្ពោះទៅរកការផ្តល់សច្ចាប័នអនុសញ្ញានេះ ហើយប្តេជ្ញាលុបបំបាត់អំពើហិង្សានៅកន្លែងធ្វើការ។ ទោះជាយ៉ាងនេះក្តី ជំហានដែលបានលើកឡើងនេះនៅពុំទាន់លេចចេញជារូបរាងនៅឡើយ ហើយមិនទាន់មានការផ្តល់ព័ត៌មានថាតើជំហានទាំងនោះមានអ្វីខ្លះនោះទេ។ ដោយសារ អនុសញ្ញាលេខ ១៩០ របស់អង្គការពលកម្មអន្តរជាតិ (ILO C ១៩០) ផ្តល់ក្របខណ្ឌ និងអនុសាសន៍ច្បាស់លាស់សម្រាប់ដោះស្រាយអំពើហិង្សា និងការបៀតបៀននៅកន្លែងធ្វើការ ហើយសំខាន់អនុសញ្ញានេះពង្រីកការគាំពារដល់កម្មករទាំងអស់ ដូច្នេះវាពិតជាចាំបាច់ណាស់ដែលរដ្ឋាភិបាលផ្តល់សច្ចាប័នលើអនុសញ្ញានេះដោយគ្មានការពន្យាពេលបន្ថែមទៀត។

## ១.៧. អំពើហិង្សាផ្អែកលើយេនឌ័រទៅលើក្រុមជនងាយរងគ្រោះ

### ១.៧.១ សហគមន៍អ្នកស្រលាញ់ភេទដូចគ្នា (LBT+)

នៅខែមីនា ឆ្នាំ២០២២ របាយការណ៍រួមមួយរបស់អង្គការសង្គមស៊ីវិលស្តីពីសិទ្ធិនៃនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ (SOGIESC) រួមទាំងភេទ និងសិទ្ធិសុខភាពបន្តពូជ ត្រូវបានបោះពុម្ពផ្សាយសម្រាប់ពេលធ្វើរបាយការណ៍ពាក់កណ្តាលអាណត្តិដោយស្ម័គ្រចិត្តនៃរបាយការណ៍ការពិនិត្យជាសកលតាមកាលកំណត់ (UPR) ជុំទីបីរបស់កម្ពុជា។ [២៦] នៅក្នុងរបាយការណ៍នេះ សង្គមស៊ីវិលបានកត់សម្គាល់ដោយមានការកោតសរសើរថា រាជរដ្ឋាភិបាលកម្ពុជាមានវឌ្ឍនភាពទាក់ទងនឹងការលើកកម្ពស់ និងការការពារសិទ្ធិស្មើគ្នានៃអ្នកស្រឡាញ់ភេទដូចគ្នា អ្នកមានភេទពីរផ្ទុយគ្នា និងអ្នកប្តូរភេទ (LBT+) នៅកម្ពុជា ដែលក្នុងនោះរួមទាំងវឌ្ឍនភាពឆ្ពោះទៅរកការសម្រេចបាននូវការអប់រំផ្លូវភេទទូលំទូលាយក្នុងសាលារៀន ដែលមានបញ្ចូល SOGIESC ផងដែរ ក៏ដូចជាការកោតសរសើរចំពោះសេចក្តីថ្លែងការណ៍ជាសាធារណៈរបស់មន្ត្រីជាន់ខ្ពស់រដ្ឋាភិបាលកម្ពុជា ដែលបានលើកទឹកចិត្តមន្ត្រីរដ្ឋាភិបាលនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ឪពុកម្តាយ និងក្រុមគ្រួសារនៃអ្នកស្រឡាញ់ភេទដូចគ្នា (LGBT+) ប្រព័ន្ធផ្សព្វផ្សាយ ក៏ដូចជាមហាជនទូទៅកុំឱ្យមានការរើសអើង។

អង្គការសហគមន៍ឥន្ទធនូកម្ពុជា (RoCK) ជាអង្គការក្នុងស្រុកផ្អែកសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា ភេទទីបី អ្នកមានភេទពីរផ្ទុយគ្នា និងអ្នកប្តូរភេទ (LGBT+) បានធ្វើការពិគ្រោះយោបល់ជាប្រចាំជាមួយក្រុមអ្នកស្រឡាញ់ភេទដូចគ្នា LBT+ ពេញមួយឆ្នាំ២០២២ ដែលពួកគេបានប្រាប់ពីបទពិសោធន៍ជីវិតរបស់ខ្លួនមកកាន់បុគ្គលិករបស់អង្គការនេះ។ តាមរយៈការពិគ្រោះយោបល់ទាំងនេះ អង្គការ RoCK បានរកឃើញថា ទម្រង់ផ្សេងៗនៃអំពើហិង្សាលើក្រុមអ្នកស្រឡាញ់ភេទដូចគ្នា LBT+ នៅក្នុងប្រទេសកម្ពុជាដែលបានចងក្រងឯកសារបោះពុម្ពផ្សាយពីមុនៗមក (រួមទាំងអំពើហិង្សាផ្លូវអារម្មណ៍ក្នុងរង្វង់គ្រួសារផង) បានបន្តកើតមានក្នុងឆ្នាំ២០២២ បើទោះបីជាមិនបានរាយការណ៍ជាផ្លូវការសម្រាប់ឆ្នាំ ២០២២ ឱ្យបានជាក់លាក់ក្តី។ [២៧] ក្នុងអំឡុងពេលពិគ្រោះយោបល់ជាប្រចាំជាមួយក្រុមអ្នកស្រឡាញ់ភេទដូចគ្នា (LBT+) ដែលសម្របសម្រួលដោយអង្គការ RoCK ពេញមួយឆ្នាំ២០២២

ក្រុមអ្នកស្រឡាញ់ភេទដូចគ្នា LBTQ+ បានប្រាប់ពីស្ថានភាពនៃ “ការរើសអើង” និង “ការបដិសេធ” ដែលគេប្រឈមមុខនៅក្នុងរង្វង់គ្រួសារ (ការបដិសេធមិនទទួលយកថា “ពួកគេជានរណា” “របៀបស្លៀកពាក់របស់គេ” និង “មនុស្សដែលគេស្រឡាញ់”) ក៏ដូចជាការឆ្លងកាត់នូវការរើសអើងដែលជួបប្រទះនៅកន្លែងធ្វើការ ជាពិសេសកើតឡើងលើអ្នកប្តូរភេទ។

របាយការណ៍ពាក់កណ្តាលអាណត្តិ UPR ជុំទីបីរបស់សង្គមស៊ីវិលស្តីពី SOGIESC-SRHR មានបញ្ចូលនូវអនុសាសន៍ជាក់លាក់ខាងក្រោមដើម្បីធានាឱ្យបាននូវការការពារប្រកបដោយប្រសិទ្ធភាព សម្រាប់ក្រុម LBT+ ពីអំពើហិង្សាផ្អែកលើយេនឌ័រ រួមទាំងការដោះស្រាយចំណុចចន្លោះប្រហោងដែលនៅសេសសល់ក្នុងផែនការសកម្មភាពជាតិដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រីដំណាក់កាលទី III (NAPVAW III)

- រៀបចំការអនុវត្តប្រកបដោយប្រសិទ្ធភាព និងអន្តរាគមន៍ជាយុទ្ធសាស្ត្រ អមដោយការបែងចែកធនធានគ្រប់គ្រាន់ ជាពិសេសទាក់ទងនឹងការអប់រំ ការលើកកម្ពស់ការយល់ដឹង និងការការពារអ្នកស្រឡាញ់ភេទដូចគ្នា LBT ពីការរើសអើង និងអំពើហិង្សាផ្អែកលើយេនឌ័រ រួមទាំងការផ្តល់សេវាសុខភាព និងផ្លូវច្បាប់ដែលទូលំទូលាយ និងងាយស្រួលសម្រាប់ជនរងគ្រោះជាក្រុម LBT ផងដែរ។ ការងារនេះគួរត្រូវបានអនុវត្តឡើងតាមរយៈការពង្រឹងការងាររបស់ក្រុមការងារបច្ចេកទេស ឆ្លើយតបលើអំពើហិង្សាផ្អែកលើ យេនឌ័រ (TWGG-GBV) និងមានការពិគ្រោះយោបល់ជាមួយសង្គមស៊ីវិលដែលធ្វើការលើសិទ្ធិរបស់ក្រុម LGBT+។
- [ក្រសួងកិច្ចការនារី] តាមរយៈការងាររបស់ក្រុមការងារបច្ចេកទេស ឆ្លើយតបលើអំពើហិង្សាផ្អែកលើ យេនឌ័រ (TWGG-GBV) ក៏គួរពិចារណាផងដែរអំពីការសិក្សាលើកំណែទម្រង់ច្បាប់ចាំបាច់ ដើម្បីការពារក្រុមអ្នកស្រឡាញ់ភេទដូចគ្នា LBT ពីអំពើហិង្សាផ្អែកលើយេនឌ័រ និងការរើសអើង។

ក្នុងចំណោមអនុសាសន៍មួយចំនួន ដើម្បីធានាបាននូវសិទ្ធិស្មើគ្នាសម្រាប់ក្រុម LGBT+ ក្នុងប្រទេសកម្ពុជា របាយការណ៍របស់សង្គមស៊ីវិលក៏បានរួមបញ្ចូលផងដែរនូវអនុសាសន៍ឱ្យចាត់វិធានការជាក់ស្តែង ដោយធ្វើការជាមួយភាគីពាក់ព័ន្ធទាំងអស់ ដើម្បីជំរុញឱ្យមានសមភាពអាពាហ៍ពិពាហ៍ស្របច្បាប់សម្រាប់គូស្នេហ៍ LGBT+ ដោយផ្អែកលើការប្តេជ្ញាចិត្តក្នុងរបាយការណ៍ UPR ជុំទីបី ដែលសិទ្ធិមួយនេះ ត្រូវបានសមាជិកសហគមន៍ LGBT+ កម្ពុជា កំណត់ជាបន្ទប់ទ្បាប់ថាជាអាទិភាពមួយក្នុងការការពារសិទ្ធិអាពាហ៍ពិពាហ៍ និងសិទ្ធិគ្រួសារស្មើភាពគ្នាសម្រាប់ពួកគេ ព្រមទាំងកាត់បន្ថយ និងលុបបំបាត់ការរើសអើងកម្រិតខ្ពស់ ដែលពួកគេប្រឈម។

## ១.៧.២. ស្ត្រី និងកុមារីជនជាតិដើម និងជនជាតិភាគតិច

នៅឆ្នាំ២០២២ របាយការណ៍ស្តីពីអំពើហិង្សាផ្អែកលើយេនឌ័រលើស្ត្រីជនជាតិដើមនៅក្នុងខេត្តចំនួនបី (មណ្ឌលគិរី រតនគិរី និងស្ទឹងត្រែង) ត្រូវបានបោះពុម្ពផ្សាយដោយអង្គការចំនួនបី៖ អង្គការជនជាតិដើមភាគតិចកម្ពុជា (CIPO) សមាគមស្ត្រីជនជាតិដើមភាគតិចកម្ពុជា (CIWA) និងអង្គការក្លាហាន។ [២៨] យោងតាមរបាយការណ៍នេះ អំពើហិង្សាក្នុងគ្រួសារ “ជារឿងធម្មតាសម្រាប់សហគមន៍ជនជាតិដើមភាគតិច ដែលអាជ្ញាធរមូលដ្ឋានទទួលបានការរាយការណ៍ច្រើនករណីនៅក្នុងភូមិរបស់ពួកគាត់។

ជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេរាយការណ៍ទៅអាជ្ញាធរមូលដ្ឋានអំពីករណីជាច្រើននៃការរំលោភសេពសន្ថវៈ រួមទាំងការរំលោភសេពសន្ថវៈដោយសមាជិកគ្រួសារ ការប៉ុនប៉ងចាប់រំលោភ ការរំលោភសេពសន្ថវៈហើយសម្លាប់ជនរងគ្រោះ ក៏ដូចជាករណីបៀតបៀនផ្លូវភេទផងដែរ”។

របាយការណ៍នេះបានរកឃើញការកើនឡើងជាក់ស្តែងនៃករណីអំពើហិង្សាផ្អែកលើយេនឌ័រ លើស្ត្រីជនជាតិដើមភាគតិចធៀបនឹងមុនឆ្នាំ២០១៥។ ទោះជាយ៉ាងណា គួរកត់សម្គាល់ផងដែរថា ការបញ្ជាក់ឱ្យច្បាស់ពីនិន្នាការ និងលំអាននៃអំពើហិង្សាផ្អែកលើយេនឌ័រលើស្ត្រីជនជាតិដើមភាគតិចនោះ គឺមិនអាចធ្វើទៅបាននោះទេ ដោយសារតែខ្វះទិន្នន័យដែលមានភាពស៊ីសង្វាក់គ្នា គ្រប់ជ្រុងជ្រោយ និងទិន្នន័យបែងចែកតាមប្រភេទ ទាក់ទងនឹងអំពើហិង្សាផ្អែកលើយេនឌ័រ។ ឧទាហរណ៍ ចន្លោះឆ្នាំ២០១៥ និង ២០២០ មន្ទីរកិច្ចការនារីខេត្តរតនគិរីបានរាយការណ៍ថា ខ្លួនបានទទួល និងចងក្រងសំណុំរឿងចំនួន ៤៩២ ករណីអំពើហិង្សាផ្អែកលើយេនឌ័រ ដែលក្នុងនោះ ៤៥០ករណី ជាករណីអំពើហិង្សាក្នុងគ្រួសារ និង ៤២ករណី ជាករណីរំលោភសេពសន្ថវៈ។ ទោះជាយ៉ាងណាក៏ដោយ ទិន្នន័យនេះមិនត្រូវបានគេបែងចែកតាមភេទ អាយុ ឬជាតិពន្ធនោះទេ។

ទិន្នន័យសម្ភាសន៍ជាមួយស្ត្រីដែលជាជនរងគ្រោះ សាច់ញាតិរបស់ជនរងគ្រោះ អាជ្ញាធរមូលដ្ឋានបុរសជាមេដឹកនាំប្រពៃណី អាជ្ញាធរខេត្ត និងអង្គការសង្គមស៊ីវិលបានចងក្រងឯកសារករណីអំពើហិង្សាផ្អែកលើយេនឌ័រចំនួន ២៣ករណី នៅក្នុងខេត្តចំនួនបី។ ជនដៃដល់ភាគច្រើនជាសាច់ញាតិ ឬមិត្តភក្តិរបស់ជនរងគ្រោះ ឬក្រុមគ្រួសាររបស់ពួកគេ។

របាយការណ៍នោះរៀបរាប់លម្អិតថា “ការសម្ភាសន៍ជាមួយជនរងគ្រោះបង្ហាញថា ការមាក់ងាយមានផលប៉ះពាល់អវិជ្ជមានលើសុខភាពផ្លូវចិត្តរបស់ជនរងគ្រោះ និងរារាំងដល់ការអប់រំ និងជីវិតសង្គមរបស់ពួកគេ”។ លទ្ធភាពទទួលបានយុត្តិធម៌ត្រូវបានគេរាយការណ៍ថាមានកម្រិតតិចតួចសម្រាប់ស្ត្រីជនជាតិដើមភាគតិច ដោយសារថាអាជ្ញាធរមូលដ្ឋានរួមទាំងមន្ត្រីនគរបាលមិនបានបំពេញអាណត្តិផ្លូវច្បាប់របស់ខ្លួនក្នុងការបញ្ជូនសំណុំរឿងទៅតុលាការ ហើយផ្ទុយមកវិញ ដោះស្រាយសំណុំរឿងអំពើហិង្សាផ្អែកលើយេនឌ័រភាគច្រើនតាមរយៈយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅថ្នាក់មូលដ្ឋាន ឃុំ ឬស្រុក (ដូចដែលបានពិភាក្សាពីខាងដើមក្នុងវគ្គ ១.៤)៖ “ករណីដែលបានចងក្រងជាឯកសារបង្ហាញថា វិធានការដោះស្រាយវិវាទបែបប្រពៃណីមិនបានប្រើវិធីសាស្ត្រផ្តោតលើជនរងគ្រោះ/អ្នករស់រានមានជីវិតនោះទេ ហើយផ្ទុយទៅវិញគឺផ្តោតលើអ្វីដែលត្រូវបានគេជឿថាជាប្រយោជន៍របស់សហគមន៍ទៅវិញ។”

របាយការណ៍ឆ្នាំ២០២២ ដែលទទួលបានពីអង្គការសិទ្ធិស្ត្រីក្នុងស្រុកមួយគឺ អង្គការនារីដើម្បីសន្តិភាព (WPM) បានរកឃើញថា អត្រាប្រេវ៉ាឡង់នៃអំពើហិង្សាផ្អែកលើយេនឌ័រ មានសភាពកាន់តែធ្ងន់ធ្ងរនៅក្នុងសហគមន៍ជនជាតិដើម (និងជនជាតិភាគតិចផ្សេងទៀត)។ [២៩] របាយការណ៍នោះត្រូវបានពិភាក្សាយ៉ាងលម្អិតនៅផ្នែកទី ២ ហើយមានផ្ទុកទិន្នន័យដែលប្រមូលបានក្នុងរយៈពេល ៣ ឆ្នាំ ពីក្មេងស្រី និងស្ត្រីចំនួន ២៦៨ នាក់ មកពីក្រុមជនជាតិភាគតិចគោលដៅចំនួន ៤ (ជនជាតិដើម ខ្មែរក្រោម ជនជាតិភាគតិចវៀតណាម និងសហគមន៍ចាម)។

ការសិក្សាបានរកឃើញថា អំពើហិង្សាក្លាយជាផ្នែកមួយធម្មតានៃជីវិតរស់នៅរបស់ក្មេងស្រីជនជាតិភាគតិចជាច្រើន។ ពួកគេភាគច្រើនមិនបានស្វែងរកជំនួយពីអាជ្ញាធរទេ ហើយមនុស្សជាច្រើនឆ្លងកាត់ការស្ដីបន្ទោសខ្លួនឯង ភាពអាម៉ាស់ និងការមាក់ងាយ។ របាយការណ៍រៀបរាប់ពីរបបធម៌ហិង្សា "ធូន់ធូរ/ឈឺចាប់" មកលើស្ត្រីនៅក្នុងសហគមន៍ជនជាតិភាគតិច ដែលជនល្មើសរស់នៅដោយនិទណ្ឌភាព។

របាយការណ៍នេះក៏បានកំណត់ផងដែរនូវភ័ស្តុតាងមួយចំនួនដូចខាងក្រោមដែលទាក់ទងនឹងអំពើហិង្សាផ្អែកលើយេនឌ័រ៖

### ស្ត្រី និងកុមារីជនជាតិដើម

- ២៥% នៃក្មេងស្រីជនជាតិដើមបានរាយការណ៍ថាធ្លាប់ឆ្លងកាត់អំពើហិង្សារាងកាយ ចំណែកឯ ៥៨% បានរាយការណ៍អំពីអំពើហិង្សាសេដ្ឋកិច្ច ហើយ ៨៨% រាយការណ៍អំពើហិង្សាផ្លូវអារម្មណ៍
- ទោះបីជាអំពើហិង្សាមានអត្រាខ្ពស់ ប៉ុន្តែ ៧០% នៃស្ត្រី និងក្មេងស្រី ជនជាតិដើម ដែលរស់នៅជាមួយអំពើហិង្សា បាននិយាយថា ពួកគេពុំបានស្វែងរកការជួយ ឬការគាំទ្រក្នុងទម្រង់ណាមួយពីខាងក្រៅផ្ទះឡើយ។

### ស្ត្រី និងកុមារីជនជាតិភាគតិចវៀតណាម

- ៨៥% នៃក្មេងស្រីជនជាតិភាគតិចវៀតណាមបានរាយការណ៍ថាបានឆ្លងកាត់អំពើហិង្សាផ្លូវអារម្មណ៍ រាងកាយ និង/ឬសេដ្ឋកិច្ច ហើយ ៣៨% ជឿថាវាជាកំហុសរបស់ខ្លួន។
- ៤៨% នៃក្មេងស្រីជនជាតិភាគតិចវៀតណាមបានឆ្លងកាត់ការបៀតបៀនផ្លូវភេទយ៉ាងហោចក៏ម្តងដែរ។

### ស្ត្រី និងកុមារីជនជាតិចាម

- ៣៦% នៃក្មេងស្រីជនជាតិចាមបានរាយការណ៍ថាធ្លាប់ឆ្លងកាត់អំពើហិង្សារាងកាយ ហើយ ៩% រាយការណ៍អំពីអំពើហិង្សាសេដ្ឋកិច្ច ខណៈដែល ៨៦% រាយការណ៍អំពីអំពើហិង្សាផ្លូវអារម្មណ៍ ឬផ្លូវចិត្ត។
- ២៣% នៃក្មេងស្រីអ៊ីស្លាមកម្ពុជា ធ្លាប់ឆ្លងកាត់ការបៀតបៀនផ្លូវភេទយ៉ាងហោចក៏ម្តងដែរ។

## ១.៧.៣.ស្ត្រីមានពិការភាព

ស្ត្រី និងក្មេងស្រីដែលមានពិការនៅកម្ពុជា មានហានិភ័យខ្ពស់ប្រឈមនឹងអំពើហិង្សា។ នៅឆ្នាំ២០២២ អង្គការបន្ទាយស្រី ជាអង្គការសិទ្ធិមនុស្សក្នុងស្រុក បានផ្តល់សេវាដល់ស្ត្រីពិការចំនួន ៧ នាក់តាមរយៈកម្មវិធី ផ្ទះសុវត្ថិភាព (Safe House) របស់ខ្លួន (ក្នុងចំណោមស្ត្រីសរុបចំនួន ១៥៨ នាក់ ដែលពួកគេបានផ្តល់សេវានៅឆ្នាំនោះ)។ ក្នុងចំណោមស្ត្រីទាំង ៧ នាក់នោះ មាន ៤ ករណីកើតឡើងនៅខេត្តសៀមរាប និងពាក់ព័ន្ធនឹងអំពើហិង្សាក្នុងគ្រួសារ។ ៣ ករណីផ្សេងទៀតកើតឡើងនៅខេត្តបាត់ដំបង ក្នុងនោះ ២ ករណីពាក់ព័ន្ធអំពើហិង្សាក្នុងគ្រួសារ និងមួយករណីទៀតពាក់ព័ន្ធការរំលោភសេពសន្ថវៈ។ ករណីអំពើហិង្សាក្នុងគ្រួសារទាំងអស់រួមមាន ការប្រើអំពើហិង្សាលើរាងកាយ អំពើហិង្សាផ្លូវចិត្ត និងអំពើហិង្សាសេដ្ឋកិច្ច។ ក្នុងចំណោមស្ត្រីរងគ្រោះទាំងនោះ អង្គការបន្ទាយស្រីបានរាយការណ៍ថា ស្ត្រីពីរនាក់មានពិការភាពត្រង់ជើង ស្ត្រីម្នាក់មានជំងឺឆ្អឹងខ្នង ស្ត្រីបីនាក់មានជំងឺអូទីហ្សឹម និងស្ត្រីម្នាក់មានពិការភ្នែក។

ស្ត្រីម្នាក់ៗបានទទួលការប្រឹក្សា និងការគាំទ្រតាមរយៈដំណើរការតុលាការពីអង្គការបន្ទាយស្រី។ ស្ត្រីម្នាក់ៗ និង/ឬក្រុមគ្រួសាររបស់គេ បានស្វែងរកជំនួយពីអាជ្ញាធរមូលដ្ឋានរៀងៗខ្លួន មុននឹងមកជួបជាមួយនឹងអង្គការនេះ ប៉ុន្តែពុំមានការចាត់វិធានការណាមួយ ឬពុំមានការស្នើឡើងនូវដំណោះស្រាយឱ្យបានគ្រប់គ្រាន់នោះដែរ។ ស្ត្រីម្នាក់ៗពិបាកឆ្លើយសំណួររបស់អាជ្ញាធរមូលដ្ឋាន ហើយស្ត្រីមួយចំនួនជួបបញ្ហាបែបនេះក៏ដោយសារពិការភាពរបស់ខ្លួន។ អ្នកខ្លះបានរាយការណ៍ទៅអង្គការបន្ទាយស្រីថា អាជ្ញាធរមូលដ្ឋានបានស្នើសុំម្តងហើយម្តងទៀតឱ្យពួកគេដោះស្រាយ ឬ “បញ្ចប់” ករណីរបស់ខ្លួនតាមរយៈការសម្រុះសម្រួល និងទទួលសំណងក្រៅផ្លូវការ ប៉ុន្តែសូម្បីតែការធ្វើបែបនេះក៏ដោយ ក៏ត្រូវបានរាយការណ៍ថា ការអន្តរាគមន៍នេះនៅតែយឺតយ៉ាវផងដែរ។ ស្ត្រីទាំងនោះជឿថា អាជ្ញាធរមូលដ្ឋានមិនបានយកចិត្តទុកដាក់ចំពោះពួកគាត់ ឬមិនផ្តល់អាទិភាពលើករណីរបស់ពួកគាត់ទេដោយសារពួកគាត់ជាស្ត្រីមានពិការភាព។

នៅក្នុងការស្វែងរកលទ្ធភាពទទួលបានយុត្តិធម៌តាមរយៈប្រព័ន្ធតុលាការផ្លូវការ ស្ត្រីទាំងនោះបានលើកឡើងនូវបញ្ហាប្រឈមផ្សេងទៀត រួមមានការលំបាកក្នុងការធ្វើដំណើរផ្លូវឆ្ងាយ (ទោះបីជាមានបុគ្គលិកស្ម័គ្រចិត្តអមដំណើរពួកគាត់ទៅអង្គការបន្ទាយស្រី និងតុលាការក៏ដោយ) ចំណេះដឹងមានកម្រិតរបស់ពួកគាត់អំពីច្បាប់ និងនីតិវិធីទាក់ទងនឹងអំពើហិង្សា ការប្រាស្រ័យទាក់ទងជាមួយមនុស្សម្នាផ្សេងទៀត និងការខ្វះខាតថវិកាសម្រាប់ផ្គត់ផ្គង់អាហារ និងកន្លែងស្នាក់នៅខ្លួនឯង អំឡុងពេលដំណើរការនីតិវិធីតុលាការដែលអូសបន្លាយពេលវេលាយូរ។

នៅខេត្តសៀមរាប មានករណីហិង្សាក្នុងគ្រួសារមួយដែលពាក់ព័ន្ធនឹងការដាក់ពាក្យសុំលែងលះនៅថ្នាក់ឃុំ ដោយលើកឡើងពីមូលហេតុនៃអំពើហិង្សា។ អំពើហិង្សាក្នុងគ្រួសារចំនួន បី ករណីផ្សេងទៀតត្រូវបានគេរាយការណ៍ថាពាក់ព័ន្ធនឹងជម្លោះដែលផ្តើមចេញពីអំពើផិតក្បត់ ដោយប្តីមានជម្លោះជាមួយស្ត្រីដែលមានរាងកាយពេញលេញ និងប្រើហិង្សានៅពេលប្រឈមមុខដាក់គ្នា។ ក្នុងចំណោមករណីទាំងនេះ មានករណីមួយនោះ បុរសជាប្តីបានបដិសេធមិនព្រមលែងលះឡើយ ដោយសារគាត់មិនចង់បាត់បង់ទ្រព្យសម្បត្តិ ដោយអះអាងថាទ្រព្យសម្បត្តិទាំងអស់ជាកម្មសិទ្ធិរបស់គាត់ស្វ័យប្រវត្តិដោយសារប្រពន្ធរបស់គាត់ជាជនពិការ និងមិនអាចរកប្រាក់ចំណូលបាន។ ក្នុងករណីនេះ ស្ត្រីរងគ្រោះនៅទីបំផុតបានសម្រេចចិត្តមិនលែងលះគ្នា ហើយបន្តរស់នៅក្នុងទំនាក់ទំនងជាប្តីប្រពន្ធបន្តទៀត។

នៅខេត្តបាត់ដំបង មានករណីអំពើហិង្សាក្នុងគ្រួសារមួយដែលស្ថិតក្នុងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (ADR) ហើយមិនត្រូវបានបញ្ជូនបន្តទៅតុលាការទេ បើទោះជាករណីនេះពាក់ព័ន្ធនឹងអំពើហិង្សាលើរាងកាយរបស់ស្ត្រីមានពិការភាពក៏ដោយ។ អង្គការ បន្ទាយស្រី ក៏នៅបន្តផ្តល់ជំនួយដល់ជនរងគ្រោះ ដែលករណីរបស់ពួកគាត់ត្រូវបានបង្វែរទៅរកយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (ADR) ទៅហើយ។ ក្នុងចំណោមករណីរំលោភសេពសន្ថវៈនៅខេត្តបាត់ដំបង ករណីទាំងបីបានបន្តទៅប្រព័ន្ធតុលាការផ្លូវការ។ ករណីមួយកំពុងបន្ត ខណៈសំណុំរឿងពីរទៀតបានឈានដល់ការផ្តន្ទាទោសដោយជនល្មើសត្រូវជាប់ពន្ធនាគារ ហើយជនរងគ្រោះទទួលបានសំណង។

ក្នុងករណីទាំងបីនេះ ស្ត្រីទាំងនោះមានជំងឺអូទីហ្សឹមធ្ងន់ធ្ងរ ហើយត្រូវអ្នកជិតខាងចាប់រំលោភសេពសន្ថវៈ។ ករណីទាំងនេះបានបន្តទៅតុលាការ បើទោះបីជាអាជ្ញាធរមូលដ្ឋានទទួចលើកទឹកចិត្តក្រុមគ្រួសារពាក់ព័ន្ធ ឱ្យធ្វើតាមយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (ADR) ក៏ដោយ។ យោងតាមកិច្ចសម្ភាសន៍របស់ក្រុមការងារ អង្គការបន្ទាយស្រី ជាមួយស្ត្រីទាំងនោះ និងក្រុមគ្រួសាររបស់គេបានឱ្យដឹងថា ដោយសារតែស្ត្រីទាំងនេះរស់នៅតំបន់ដាច់ស្រយាល និងមានជំងឺអូទីហ្សឹម ទើបជនដៃដល់បានគិតថា ពួកគេមិនអាចរាយការណ៍ពីបទល្មើសនោះបានឡើយ។ បុគ្គលិកម្នាក់មកពីអង្គការនេះបាននិយាយថា "យើងដឹងហើយថា ជនរងគ្រោះនឹងមិនរាយការណ៍ថាករណីនោះជាបទល្មើសព្រហ្មទណ្ឌហិង្សានោះទេ លុះត្រាតែក្រុមគ្រួសាររបស់ពួកគេបានដឹង [ថាមានការប្រព្រឹត្តអំពើហិង្សាក្នុងករណីនោះ] ធ្វើការរាយការណ៍ និងស្វែងរកវិធីដើម្បីជួយគាំទ្រដល់ជនរងគ្រោះ។"

សរុបមក ទស្សនៈរើសអើងនានាដែលយល់ថាស្ត្រី និងកុមារីដែលមានពិការភាពមិនសូវមានតម្លៃ និងជាបន្ទុកច្រើនជាងអ្នកដែលគ្មានពិការភាព បង្កជាឧបសគ្គបន្ថែមសម្រាប់ស្ត្រី និងកុមារីក្នុងការទទួលបានយុត្តិធម៌។ អាជ្ញាធរមូលដ្ឋានក៏ត្រូវបានគេរាយការណ៍ថា មានការយល់ដឹង និងការតាំងចិត្តតិចតួចក្នុងការគាំទ្រដល់ជនរងគ្រោះទាំងនេះ ជាពិសេសស្ត្រីដែលមានជំងឺអូទីហ្សឹម។

កម្មវិធីបង្ការបឋម រហូតមកដល់ពេលនេះមិនទាន់បានដោះស្រាយបានទាំងស្រុងនៅឡើយទេ នូវបញ្ហានៃការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រីមានពិការភាព ជាធម្មតាខ្វះខាតនូវចំណុចប្រសព្វគ្នានៃតម្រូវការចាំបាច់ ដើម្បីដោះស្រាយទម្រង់ជាច្រើននៃភាពងាយរងគ្រោះរបស់ស្ត្រី និងក្មេងស្រីដែលមានពិការភាព។ ចាំបាច់ត្រូវមានការបង្កើតយុទ្ធសាស្ត្រសម្រាប់ផ្សារភ្ជាប់ជាមួយស្ត្រី និងក្មេងស្រីមានពិការភាព និងដើម្បីគាំទ្រដល់អង្គការជនពិការដែលដឹកនាំដោយស្ត្រី ដែលអាចនិយាយការពារសិទ្ធិស្ត្រី និងក្មេងស្រីមានពិការភាព ដើម្បីឱ្យពួកគេអាចរស់នៅដោយគ្មានអំពើហិង្សា។

# ២. ស្ត្រី និងក្មេងស្រីជនជាតិដើម និងជនជាតិភាគតិច

ដូចដែលបានរៀបរាប់នៅក្នុងវគ្គ ១.៧.២ ការស្រាវជ្រាវថ្មីស្ដីពីបទពិសោធន៍ទាក់ទងនឹងសិទ្ធិរបស់ស្ត្រី និងក្មេងស្រីជនជាតិដើម និងជនជាតិភាគតិច ត្រូវបានចងក្រងឡើងដោយ អង្គការ នារីដើម្បីសន្តិភាព (WPM) ក្នុងឆ្នាំ២០២២។[៣០] ការសិក្សានោះបានរកឃើញថា ក្មេងស្រី និងស្ត្រីជនជាតិភាគតិចមានហានិភ័យខ្ពស់ក្នុងការប្រឈមកាន់តែខ្ពស់ចំពោះអំពើហិង្សាផ្អែកលើយេនឌ័រ បញ្ហាដែលកើនឡើងច្រើនជាងគេគឺ ការទទួលបានសេវាសាធារណៈដូចជា សេវាសុខភាព សេវាអប់រំ និងយុត្តិធម៌ ហើយពួកគេ ងាយបាត់ឱកាសផ្នែកសេដ្ឋកិច្ច ឬមានហានិភ័យខ្ពស់ក្នុងការធ្លាក់ទៅកាន់ភាពក្រីក្រ និងបញ្ហាសុខភាព។ ទោះជាយ៉ាងណា ប្រជាជនភាគច្រើនគឺ "ជារឿយៗមិនដឹងអំពីបញ្ហាធ្ងន់ធ្ងរដែលស្ត្រី និងក្មេងស្រីជនជាតិភាគតិចប្រឈមមុខនោះទេ ដែលបណ្តាលឱ្យមានការផាត់ពួកគេចេញជាបន្តបន្ទាប់" ហើយបញ្ហានេះកាន់តែធ្ងន់ធ្ងរទៅៗ ដោយសារភាពខ្វះចន្លោះនៃព័ត៌មាន អំពីស្ថានភាពក្មេងស្រី និងស្ត្រីជនជាតិភាគតិចនៅក្នុងប្រទេស។

## ២.១. លទ្ធភាពទទួលបានការអប់រំ និងសេវាសុខភាពបន្តពូជ

យោងតាមការសិក្សានេះបានបង្ហាញថា ក្មេងស្រីជនជាតិភាគតិចជាច្រើនមានអារម្មណ៍ថា ពួកគេឆ្លងកាត់ភាពពេញក្រមុំតែម្នាក់ឯងដោយគ្មានការគាំទ្រ ឬការផ្តល់ព័ត៌មានពីគ្រួសារ សហគមន៍ ឬរដ្ឋា ភិបាលឡើយ។ កង្វះការអប់រំផ្លូវភេទគឺជារឿងពិបាកមែនទែនសម្រាប់ក្មេងស្រីជនជាតិដើមភាគតិច និងចាម ដែលជារឿយៗរៀបការនៅវ័យក្មេង និងបង្កើតកូនក្នុងពេលខ្លួនវ័យជំទង់។ ឧបសគ្គចម្បងមួយគឺការមាក់ងាយជុំវិញប្រធានបទទាំងអស់នេះ ដែលធ្វើអោយក្មេងស្រីស្ទាក់ស្ទើរ ឬហាមឃាត់មិនឱ្យពិភាក្សាបញ្ហាទាំងនេះជាមួយក្រុមគ្រួសារ ឬចាស់ទុំ។ ក្មេងស្រីចំនួន ៥២% បាននិយាយថាពួកគេខ្លាចគេចាត់ទុកថាជា “ក្មេងមិនល្អ” ប្រសិនបើពួកគេលើកឡើងពីបញ្ហាទាំងនេះ។

ក្មេងស្រីមកពីក្រុមជនជាតិដើម និងជនជាតិភាគតិច ដែលចូលរួមក្នុងការសិក្សានេះក៏បានរាយការណ៍ថាមានអារម្មណ៍មិនស្រួលនៅអំឡុងពេលមករដូវ។ ក្មេងស្រីជាច្រើនមិនបានទិញផលិតផលសម្រាប់ប្រើពេលមករដូវទេ ដោយសារតែពួកគេខ្មាស់អៀនមិនហ៊ានទិញ ឬមិនហ៊ានប្រាប់អ្នកដទៃអំពីការប្រែប្រួលរាងកាយរបស់ខ្លួន។ ជារឿយៗ ពួកគេក៏ខ្វះខាតថវិកាដើម្បីទិញផលិតផលប្រើពេលមករដូវដែលអាចបោះចោលបាន។ អនាម័យពេលមករដូវជាទូទៅជាកង្វល់ដ៏ធំមួយសម្រាប់ក្មេងស្រីជនជាតិភាគតិចមួយចំនួន ដែលមិនមានបង្គន់អនាម័យឯកជន។ កត្តាទាំងអស់នេះត្រូវបានរាយការណ៍ថានាំឲ្យមានទំនាក់ទំនងមិនល្អជាមួយនឹងដំណើរការធម្មជាតិនៃរូបរាងកាយរបស់ក្មេងស្រី ហើយក៏អាចរួមចំណែកដល់ការបោះបង់ការសិក្សាមួយចំនួនផងដែរ។

កង្វះលទ្ធភាពទទួលបានការអប់រំ និងសេវាសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ គឺមានគ្រោះថ្នាក់ខ្លាំងសម្រាប់ក្មេងស្រី និងស្ត្រីវ័យក្មេងជនជាតិដើម ដោយសារតែមានអត្រាអាពាហ៍ពិពាហ៍កុមារខ្ពស់នៅក្នុងសហគមន៍ទាំងនេះ។ នៅក្នុងការសិក្សានេះ មានចំនួន ១០.៥% នៃក្មេងស្រីជនជាតិដើម ដែលមានអាយុក្រោម ១៥ ឆ្នាំ ត្រូវបានកំណត់ឃើញថាបានរៀបការរួចហើយ ហើយចំនួន ៥៥% ដែលមានអាយុចន្លោះពី ១៥-១៩ ឆ្នាំបានកំណត់ឃើញថារៀបការរួច។ នៅពេលសួរថា តើពួកគេយល់ដឹងពីសុខភាពផ្លូវភេទ និងសុខភាពបន្តពូជកម្រិតណានោះ មានចំនួនរហូតដល់ ៩៧.៥% នៃក្មេងស្រីជនជាតិភាគតិចរៀតណាមបានឆ្លើយថា ដឹងមិនច្រើនតិចតួច ឬមិនដឹងទាល់តែសោះ។ ចំនួន ៦០% នៃក្មេងស្រីទាំងនេះក៏បានរាយការណ៍ថា គេយល់ឃើញថាប្រធានបទទាក់ទងនឹងសុខភាពផ្លូវភេទ និងសិទ្ធិសុខភាពបន្តពូជ ជារឿងហាមឃាត់។

ស្រដៀងគ្នានេះដែរ ស្ទើរតែពាក់កណ្តាល (៤៨%) នៃក្មេងស្រីចាមម៉ូស្លីមយល់ថា ការនិយាយអំពីសុខភាពផ្លូវភេទ និងសុខភាពបន្តពូជគឺជារឿងហាមឃាត់។ នៅពេលសួរថាតើពួកគេធ្លាប់មានបញ្ហាផ្លូវភេទ ឬសុខភាពបន្តពូជឬអត់នោះ ក្មេងស្រី ៣០% ឆ្លើយថា ពួកគេមិនដឹងថាពួកគេធ្លាប់មានបញ្ហានេះ ឬអត់នោះទេ។

ភស្តុតាងទាំងអស់ខាងលើចង្អុលបង្ហាញឱ្យឃើញពីតម្រូវការបន្ទាន់ ឱ្យមានការអប់រំផ្លូវភេទ និងសុខភាពបន្តពូជឱ្យកាន់តែខ្លាំងឡើង និងលទ្ធភាពទទួលបានព័ត៌មានសម្រាប់ក្រុមជនជាតិដើម និងជនជាតិភាគតិច។ របាយការណ៍នេះបានផ្តល់អនុសាសន៍ថា រដ្ឋាភិបាលគួរតែចាត់វិធានការដើម្បីកាត់បន្ថយតម្លៃផលិតផលអនាម័យស្ត្រី ដោយកាត់បន្ថយពន្ធលើផលិតផលទាំងនេះដល់កម្រិតសូន្យ។ លើសពីនេះទៅទៀត ថ្នាក់សិក្សាអប់រំផ្លូវភេទទូលំទូលាយគួរតែត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សារបស់សាលារដ្ឋ និងឯកជន ដោយចាប់ផ្តើមពីវ័យក្មេង ហើយគួរមានការបង្រៀនជាភាសាជនជាតិដើម និងជនជាតិភាគតិចតាមភាពសមស្រប។

## ២.២. បទពិសោធន៍នៃការរើសអើង

ក្មេងស្រីជនជាតិដើម និងជនជាតិភាគតិច ដែលចូលរួមក្នុងការសិក្សារបស់អង្គការ នារីដើម្បីសន្តិភាព (WPM) បានរាយការណ៍ពីបទពិសោធន៍នៃការរើសអើង។ បើនិយាយឱ្យទូលំទូលាយ គឺមានចំនួន ៦៩% នៃក្មេងស្រីដែលចូលរួមការសិក្សានោះ បាននិយាយថាពួកគេមានអារម្មណ៍ថាក្នុងជីវិតរបស់ពួកគេគឺគេបានរងការរើសអើង។ មានចំនួន ២៥% គឺជាការរើសអើងចំពោះរបៀបនិយាយស្តីរបស់ពួកគេ ២៣% ជាការរើសអើងលើទម្លាប់ប្រតិបត្តិសាសនារបស់ពួកគេ ៣៣% ជាការរើសអើងចំពោះជាតិពន្ធរបស់ពួកគេ ២៨% ជាការរើសអើងចំពោះការស្លៀកពាក់របស់ពួកគេ ៣០% ជាការរើសអើងចំពោះការដែលគេនិយាយស្តីភាសារបស់ខ្លួន និង ២៣% ជាការរើសអើងលើវប្បធម៌និងប្រពៃណីរបស់ពួកគេ។

ថ្វីដ្បិតការព្រួយបារម្ភអំពីភាពដែលមិនមានសញ្ជាតិ និងការរើសអើងត្រូវបានលើកយកមកឆ្លុះបញ្ចាំងឡើងហើយក្តី ដោយគណៈកម្មាធិការស៊ី-ដ (CEDAW) នៅក្នុងសេចក្តីអង្កេតសន្និដ្ឋានរបស់ខ្លួន នៅក្នុងកិច្ចពិនិត្យឡើងវិញនៃរបាយការណ៍ជាតិរបស់កម្ពុជាពីឆ្នាំ២០១៣ និងឆ្នាំ២០១៩ និងដោយគណៈកម្មាធិការសិទ្ធិមនុស្ស ក្នុងដំណើរការពិនិត្យឡើងវិញលើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ (CCPR) ប៉ុន្តែស្ថានភាពមិនមានភាពប្រសើរឡើងនោះទេ ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ សម្រាប់ក្មេងស្រី/ស្ត្រីវ័យក្មេង ខ្មែរក្រោម និងជនជាតិភាគតិចវៀតណាមមកពីសហគមន៍បណ្តែតទឹក ដែលឪពុកម្តាយរបស់ពួកគេមានបណ្តស្នាក់នៅអចិន្ត្រៃយ៍ថ្មីរួចហើយនោះ។[៣១]

ភាពបរាជ័យក្នុងការជួយសម្រួលឱ្យទទួលបានសំបុត្រកំណើត បានបន្តនាំឱ្យមានការរើសអើងផ្នែកនយោបាយ អប់រំ ហិរញ្ញវត្ថុ និងការរើសអើងក្នុងការប្រាស្រ័យទាក់ទងអន្តរបុគ្គលផងដែរ កុំថាឡើយនិយាយដល់អ្នកដែលទទួលបានសញ្ជាតិខ្មែរ ដែលជា អ្នកបានបំពេញតាមលក្ខខណ្ឌក្នុងការទទួលបានសញ្ជាតិ ជាពិសេស អ្នកដែលមានដើមកំណើតជាជនជាតិវៀតណាម និងខ្មែរក្រោមនោះ។ ទោះបីជាធ្វើតាមគោលការណ៍ រដ្ឋាភិបាលកម្ពុជា ទទួលស្គាល់ខ្មែរក្រោមជាពលរដ្ឋខ្មែរក្តី ប៉ុន្តែ អ្នករស់នៅរយៈពេលយូរមកហើយ និងអ្នកមកដល់ថ្មីៗជាច្រើនប្រឈមនឹងឧបសគ្គនៅពេលពួកគេព្យាយាមធ្វើអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរជាផ្លូវការ ជាពិសេសទាក់ទងនឹងការស្នើសុំអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ។ [៣២] ផលប៉ះពាល់នេះត្រូវបានបង្ហាញនៅក្នុងលទ្ធផលដូចខាងក្រោមៈ

- ៤៥% នៃក្មេងស្រី និងស្ត្រីវ័យក្មេងខ្មែរក្រោម ដែលចូលរួមការអង្កេតបានរាយការណ៍ថា បានរងការរើសអើង ដែលក្នុងនោះ ៣៣% បានបញ្ជាក់ថា គេបានបោះបង់ចោលការសិក្សា ដោយសារតែការរើសអើងនេះ។

- ៦០% នៃក្មេងស្រីជនជាតិវៀតណាម ក៏បានរាយការណ៍ពីការរើសអើងដោយផ្អែកលើជាតិពន្ធរបស់ពួកគេផងដែរ។

នៅពេលដែលមានការរើសអើងកើតឡើង ការអប់រំរបស់ក្មេងស្រីក៏ត្រូវបានបាត់បង់ ដូច្នេះការរើសអើងបានធ្វើឲ្យបាត់បង់ជំនឿចិត្តរបស់ពួកគេផងដែរ ហើយធ្វើឱ្យពួកគេមានអារម្មណ៍ថាមិនសូវមានតម្លៃនៅក្នុងសង្គម។ ការសិក្សាបានរកឃើញថាការរើសអើងនេះបានធ្វើឱ្យក្មេងស្រី ៦៩% មានអារម្មណ៍ថាគ្មានតម្លៃ ២៩% បាត់បង់ជំនឿចិត្ត ១៥% មានអារម្មណ៍ឯកោ និងមិនចង់ទាក់ទងជាមួយមនុស្សប្លែកមុខ និង ១៤% បោះបង់ការសិក្សា។

អនុសាសន៍

- ជាឧទាហរណ៍ បង្កើតវប្បធម៌ដែលលើកតម្កើង ដល់ភាពចម្រុះ ដោយបញ្ចូលវប្បធម៌ជនជាតិភាគតិចទៅក្នុងកម្មវិធីសិក្សារបស់សាលា ដើម្បីបង្រៀនកុមារអំពីរឿងផ្សេងៗ និងលុបបំបាត់ពាក្យចចាមអារ៉ាមអំពីក្រុមជនជាតិដើម និងជនជាតិភាគតិច។
- ធានាថារដ្ឋបាលមូលដ្ឋាន និងមន្ត្រីសុខាភិបាលទទួលបានការអប់រំត្រឹមត្រូវអំពីច្បាប់សញ្ជាតិ និងពលរដ្ឋ ព្រមទាំងគោលនយោបាយ និងគោលការណ៍ណែនាំពាក់ព័ន្ធផ្សេងទៀតដែលមានបំណងបង្កើនអត្រានៃការចុះសំបុត្រកំណើតសម្រាប់ជនជាតិភាគតិច និងការផ្តល់វិញ្ញាបនបត្រពាក់ព័ន្ធស្របតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDG) លេខ ១៦.៩ ដែលចែងថា "នៅឆ្នាំ២០៣០ ផ្តល់ការទទួលស្គាល់ស្របច្បាប់សម្រាប់ទាំងអស់គ្នា រួមទាំងការចុះសំបុត្រកំណើតដោយឥតគិតថ្លៃ"។
- បញ្ជាក់អំពីសិទ្ធិស្របច្បាប់នៃបណ្ណស្នាក់នៅអចិន្ត្រៃយ៍ និងធានាថាការចែកបណ្ណនេះមិនបដិសេធឬលុបបំបាត់សិទ្ធិ និងឱកាសដែលមានពីមុន ក្នុងការទទួលបានការអប់រំ ការងារ ការថែទាំសុខភាព និងសេវាមូលដ្ឋានផ្សេងទៀតនោះទេ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះគួរតែមានគោលបំណងកាត់បន្ថយការជំរុញឲ្យមានការប្រកាន់ពូជសាសន៍ ឬការវិនិច្ឆ័យទុកមុនលើបុព្វសិទ្ធិរបស់ពលរដ្ឋ។

## ២.៣. កង្វះក្តីសង្ឃឹមទទួលបានការអប់រំបានខ្ពស់

ការសិក្សារបស់អង្គការនារីដើម្បីសន្តិភាព (WPM) បានបង្ហាញអំពីលទ្ធផលគួរឱ្យព្រួយបារម្ភអំពីលទ្ធភាពរបស់ក្មេងស្រីជនជាតិភាគតិចក្នុងការទទួលបានការអប់រំកម្រិតមធ្យមសិក្សា និងឧត្តមសិក្សា។ ក្មេងស្រីជាច្រើនត្រូវបានជំរុញទឹកចិត្តឱ្យបោះបង់ចោលការសិក្សា ពីសំណាក់សមាជិកគ្រួសារ ដែលមិនឱ្យតម្លៃលើការអប់រំសម្រាប់កូនស្រីដូចគ្នានឹងកូនប្រុសនោះ។ ជាអកុសល ទោះបីជាគ្រួសារមួយចង់បញ្ជូនកូនស្រីទៅរៀនក៏ដោយ ប៉ុន្តែ ក៏ពួកគេនៅតែខ្វះខាតធនធានសម្រាប់ផ្គត់ផ្គង់កូនស្រីឱ្យទៅរៀនដដែល។

ក្មេងស្រីមកពីសហគមន៍ជនជាតិភាគតិចផ្សេងៗគ្នា ងាយបោះបង់ចោលការសិក្សានៅកម្រិតផ្សេងៗគ្នា។ ក្មេងស្រីជនជាតិដើមភាគតិចពូនងជាច្រើនឈប់រៀន គឺនៅបឋមសិក្សា ឬដើមកម្រិតមធ្យមសិក្សា។ ពួកគេប្តូរទៅធ្វើការងារផ្ទះពេញម៉ោង ឬធ្វើស្រែចម្ការ ឬរៀបការ។

ក្មេងស្រីជនជាតិភាគតិចវៀតណាមជាច្រើន ប្រឈមនឹងបញ្ហាដ៏ស្មុគស្មាញក្នុងការទទួលបានអត្តសញ្ញាណស្របច្បាប់ ហើយជារឿយៗមិនដែលចូលសាលាទាល់តែសោះ។ សម្រាប់ក្មេងស្រីជនជាតិវៀតណាមមកពីបណ្តាភូមិបណ្តែតទឹកនានា ពួកគេមានការលំបាកខ្លាំងណាស់ក្នុងការចូលរៀន ប៉ុន្តែក្នុងចំណោមសិស្សមួយចំនួនតូចដែលចូលរៀននោះ ភាគច្រើនត្រូវបោះបង់ចោលការសិក្សា ហើយចាប់យកការងារក្នុងវិស័យនេសាទដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសាររបស់គេ។

ក្មេងស្រីខ្មែរឥស្លាមជាធម្មតាចូលរៀនរហូតដល់វិទ្យាល័យ ប៉ុន្តែភាគច្រើនបានឈប់រៀនដើម្បីចាប់ផ្តើមធ្វើការនៅរោងចក្រកាត់ដេរក្បែរៗនោះ ឬដើម្បីជួយអាជីវកម្មគ្រួសាររបស់ខ្លួន។ ក្មេងស្រីខ្មែរក្រោមត្រូវបានរាយការណ៍ថា ជាញឹកញាប់បោះបង់ចោលការសិក្សានៅពេលពួកគេចូលរៀនដល់អនុវិទ្យាល័យ ឬវិទ្យាល័យ ដើម្បីទៅជួយឪពុកម្តាយលក់ម្ហូបអាហារ ឬជួយការងារអាជីវកម្មខ្នាតតូចឪពុកម្តាយ។

សម្រាប់អ្នកដែលអាចរៀនចប់វិទ្យាល័យ ក្មេងស្រីជនជាតិភាគតិចជាច្រើនមិនមានលទ្ធភាពទទួលបានព័ត៌មានដើម្បីលើកទឹកចិត្តពួកគេឱ្យបន្តការសិក្សានៅកម្រិតបរិញ្ញាបត្រទេ។ សម្រាប់អ្នកដែលសុបិនចង់បន្តការសិក្សានៅថ្នាក់ឧត្តមសិក្សា ពួកគេបាត់បង់ទឹកចិត្តដោយសារឧបសគ្គជាច្រើន រួមមាន ការចំណាយ កង្វះមធ្យោបាយធ្វើដំណើរ ឧបសគ្គភាសា បទដ្ឋានសង្គម ឬការភ័យខ្លាចអំពីសុវត្ថិភាព និងការរើសអើងជាដើម។

នៅពេលសាកសួរអំពីឧបសគ្គជាក់លាក់ដែលអាចរារាំងពួកគេមិនឱ្យទទួលបានការអប់រំឱ្យបានខ្ពស់នោះ ៩០% នៃក្មេងស្រីជាអ្នកឆ្លើយបាននិយាយថា ដោយសារខ្វះខាតលុយកាក់ ៤៨% និយាយថា ដោយសារខ្វះការគាំទ្រពីគ្រួសារ ហើយ ២២% និយាយថា ដោយសារកង្វះហេដ្ឋារចនាសម្ព័ន្ធ។

សម្រាប់ក្មេងស្រីជនជាតិភាគតិចវៀតណាម បញ្ហាខ្វះឯកសារផ្លូវច្បាប់នៅតែជាកង្វល់ដ៏ធ្ងន់ធ្ងរបំផុត។ ក្នុងចំណោមក្មេងស្រី ៤០ នាក់មកពីសហគមន៍នេះ មានតែ ២៧.៥% ប៉ុណ្ណោះ ដែលត្រូវបានកំណត់ថាជាសិស្ស។ ចំពោះកុមារជនជាតិភាគតិចវៀតណាមភាគច្រើននៅក្នុងសហគមន៍បណ្ដែតទឹក ពួកគេអាចចូលរៀនបានតែនៅសាលាឯកជន ដែលជាធម្មតាជាកន្លែងប្រមូលផ្ដុំគ្នាប្ដូរវេននៅលើផ្ទះទូកផ្សេងទៀតជាមួយសមាជិកសហគមន៍ដែលជាអ្នកបង្រៀន។ សាលាក្រៅផ្លូវការទាំងនេះមានបង្រៀនកុមារតែអំពីអក្ខរកម្ម និងលេខនព្វន្តមូលដ្ឋានប៉ុណ្ណោះ ពុំសូវមានអ្វីលើសពីនេះទេ។ សិស្សានុសិស្សបានរាយការណ៍ថាមិនមានឱកាសបន្តការសិក្សាលើសពីអនុវិទ្យាល័យឡើយ។

ការសិក្សារបស់អង្គការនារីដើម្បីសន្តិភាព (WPM) បានបង្ហាញ ៧៤% នៃក្មេងស្រីជនជាតិភាគតិចបានរាយការណ៍អំពីជំនឿថា ការអប់រំសម្រាប់ក្មេងស្រីមានសារៈសំខាន់ខ្លាំងណាស់ ហើយ ៤២% បានរាយការណ៍អំពីបំណងប្រាថ្នាផ្ទាល់ខ្លួនក្នុងការរៀនដល់ថ្នាក់បរិញ្ញាបត្រ។ ភស្ដុតាងនេះបង្ហាញថា ក្មេងស្រីជនជាតិភាគតិចចង់ទៅសាលារៀន ហើយចាត់ទុកការសិក្សាជារឿងសំខាន់ ប៉ុន្តែភាគច្រើនបំផុតគឺខ្វះធនធាន និងការគាំទ្រ ដើម្បីធ្វើតាមការប្រាថ្នារបស់ខ្លួន។

អនុសាសន៍៖

- លុបបំបាត់ឧបសគ្គ (ជាប្រព័ន្ធ) ក្នុងការទទួលបានការអប់រំ សម្រាប់ក្មេងស្រីជនជាតិដើម និងជនជាតិភាគតិច រួមទាំងកង្វះគ្រូបង្រៀនមានគុណភាព ដែលចេះនិយាយភាសាជនជាតិដើម និងភាសាជនជាតិភាគតិច កង្វះហេដ្ឋារចនាសម្ព័ន្ធសាលារៀននៅជិតផ្ទះ កង្វះសាលារៀនដែលមានអនាម័យ សម្រាប់ក្មេងស្រីជាជនជាតិភាគតិច ។ល។

- គួរតែបង្កើត និងអនុវត្តវិធានការពិសេសនានា ដូចជាការផ្ដល់អាហារូបករណ៍ អន្តេវាសិកដ្ឋាន គ្រូបង្រៀនប្រកបដោយគុណភាពដែលអាចចេះនិយាយភាសាជនជាតិដើម និងភាសាជនជាតិភាគតិច ការលើកកម្ពស់ការយល់ដឹងអំពីសារៈសំខាន់នៃការអប់រំ ក្នុងចំណោមអ្នកថែទាំកុមារ ការមិនប្រើសំបុត្រកំណើតជាដើម ដើម្បីធានាថាក្មេងស្រី និងស្ត្រីវ័យក្មេងជនជាតិដើម និងជនជាតិភាគតិច អាចទទួលបានការអប់រំប្រកបដោយគុណភាពស្មើៗគ្នាដូចមានចែងក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDG) ទី៤ ថា “ធានាបាននូវការអប់រំដែលមានគុណភាព ប្រកបដោយបរិយាបន្ន និងសមធម៌ និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា”។

- ផ្ដល់ការណែនាំ និងការអប់រំច្បាស់លាស់ដល់គ្រូបង្រៀន ស្ដីពីការលុបបំបាត់ការរើសអើងពូជសាសន៍ ពីសំណាក់មិត្តភក្ដិមកកាន់សិស្សជនជាតិដើម និងជនជាតិភាគតិចនៅក្នុងថ្នាក់រៀន និងលើកកម្ពស់វប្បធម៌នៃការលើកតម្កើងភាពទីទៃពីគ្នា និងភាពចម្រុះ។

# ៣. ពលកម្មការងារ

## ៣.១. ការរើសអើង និងការបង្ក្រាបលើសមាជិកសហជីព/អ្នករៀបចំសហជីព

ពេញមួយឆ្នាំ២០២២ ការបង្ក្រាបលើការធ្វើកូដកម្មរបស់កម្មការិនី ដែលបានកើនឡើងខ្លាំងនៅចុងឆ្នាំមុននោះ នៅតែបន្ត។ កាលពីខែធ្នូ ឆ្នាំ ២០២១ សហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៃក្រុមហ៊ុនណាហ្គាវើលដ៍ (LRSU) ដែលសមាជិកភាគច្រើនជាស្ត្រី បានធ្វើកូដកម្ម និងបាតុកម្មនៅជិតកាស៊ីណូណាហ្គាវើលដ៏ ក្នុងរាជធានីភ្នំពេញ បន្ទាប់ពីក្រុមហ៊ុនបញ្ឈប់បុគ្គលិកកម្មករចំនួន ១៣២៩ នាក់ ក្នុងឆ្នាំ២០២១។ ៨២% នៃកម្មករដែលត្រូវបានបណ្តេញចេញគឺជាសមាជិកសហជីព រួមទាំងថ្នាក់ដឹកនាំសហជីពទាំងអស់ប្រចាំក្រុមហ៊ុនផងដែរ។ មេដឹកនាំសហជីពក៏បានកត់សម្គាល់ផងដែរថាការបញ្ឈប់ការងារនេះ ផ្តោតគោលដៅលើស្ត្រីមានផ្ទៃពោះ ឬទើបសម្រាលកូនថ្មីៗ។

ត្រឹមខែកុម្ភៈ ឆ្នាំ២០២២ រដ្ឋាភិបាលបានរងការរិះគន់ធ្ងន់ៗចំពោះការប្រើប្រាស់វិធានសុខាភិបាលចត្តាឡីស័កសាធារណៈ ដើម្បីផ្តោតគោលដៅលើបុគ្គលិកកម្មករដែលធ្វើកូដកម្ម ផ្លាស់ទីកន្លែងពួកគេដោយបង្ខំ និងឃុំខ្លួនបុគ្គលិកកម្មករដែលធ្វើកូដកម្មទាំងនោះ។ នៅថ្ងៃទី១៦ ខែកុម្ភៈ អ្នកជំនាញសិទ្ធិមនុស្សសំខាន់ៗរបស់អង្គការសហប្រជាជាតិចំនួន ប្រាំនាក់ បានចេញសេចក្តីថ្លែងការណ៍មួយពីទីក្រុងហ្សឺណែវ ដោយរិះគន់លើវិធានចត្តាឡីស័កសម្រាប់ជំងឺកូវីដ-១៩ ដែលបានដាក់បន្ទុកលើបុគ្គលិកកម្មករកាស៊ីណូដែលធ្វើកូដកម្ម ដោយបានលើកឡើងថា “អាជ្ញាធរមិនត្រូវក្លែងបន្លំការបង្ក្រាបលើសកម្មភាពការងារដោយសន្តិវិធី និងស្របច្បាប់ ថាជាចំណាត់ការឆ្លើយតបផ្នែកសុខភាពសាធារណៈនោះឡើយ”។ [៣៣] អ្នកជំនាញក៏បានអះអាងផងដែរថា “វិធានការសុខាភិបាលសម្រាប់ជំងឺកូវីដ-១៩ របស់កម្ពុជា ពុំមានភាពស៊ីសង្វាក់ជារួម និងខ្វះតម្លាភាព” ហើយថា “ក្នុងករណីនេះ អាជ្ញាធរហាក់ដូចខិតខំប្រឹងប្រែងដើម្បីរារាំងសកម្មភាពការងារដោយសន្តិវិធី និងស្របច្បាប់ ដោយក្លែងថាជាវិធានការសុខភាពសាធារណៈ។ មិនអាចមានវិធានមួយសម្រាប់កម្មករដែលធ្វើកូដកម្ម និងមួយទៀតសម្រាប់មហាជនទូទៅទាំងស្រុងនោះទេ”។

គិតត្រឹមខែមីនា យ៉ាងហោចណាស់មានបាតុករពីសហជីព LRSU ចំនួន ៣៥ នាក់ត្រូវបានចាប់ខ្លួនពីបទ “ញុះញង់” ក្រោមមាត្រា ៤៩៤ និង ៤៩៥ នៃក្រមព្រហ្មទណ្ឌ ឬពីបទរារាំងវិធានការអនុវត្តក្រោមច្បាប់ស្តីពីជំងឺកូវីដ-១៩។ ក្រោយមក ក្រុមបាតុករត្រូវបានដោះលែងឱ្យនៅក្រៅឃុំ ឬក្រោយពេលចុះកិច្ចសន្យាដែលបានចុះហត្ថលេខាជាមួយនគរបាល ប៉ុន្តែមេដឹកនាំសហជីព និងសមាជិកចំនួន ១១ នាក់ ក្នុងនោះ មាន ៧ នាក់ជាស្ត្រី រួមទាំង ឈឹម ស៊ីថរ ប្រធានសហជីព LRSU ផងនោះត្រូវបានឃុំខ្លួនបណ្តោះអាសន្នមុនពេលកាត់ទោស រហូតដល់ទៅ ២ ខែកន្លះ មុនពេលត្រូវបានដោះលែងឱ្យនៅក្រៅឃុំ។ [៣៤]

មនុស្សទាំង ១១ នាក់នោះ ម្នាក់ៗ ត្រូវបានចោទប្រកាន់ពីបទញុះញង់ឱ្យប្រព្រឹត្តបទល្មើសតាមមាត្រា ៤៩៤ និង ៤៩៥ នៃក្រមព្រហ្មទណ្ឌ ឬរារាំងដល់ការអនុវត្តវិធានការណ៍ប្រឆាំងជំងឺកូវីដ-១៩ តាមមាត្រា ១១ នៃច្បាប់ស្តីពីការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត (ច្បាប់កូវីដ-១៩) ទោះបីសិទ្ធិធ្វើកូដកម្មមានចែងក្នុងរដ្ឋធម្មនុញ្ញរបស់ប្រទេសកម្ពុជា ច្បាប់ស្តីពីការងាររបស់កម្ពុជា និងច្បាប់ស្តីពីសហជីពក៏ដោយ។ រដ្ឋាភិបាលបរទេស អង្គការពលកម្មអន្តរជាតិ (ILO) និងសហព័ន្ធសហជីពអន្តរជាតិបានថ្កោលទោសការកាត់ទោស និងការឃុំខ្លួនសកម្មជនទាំងនោះ។[៣៥]

ជាធម្មតា បុគ្គលិកកម្មករទាំងនោះត្រូវបានបង្ខំឱ្យឡើងរថយន្តក្រុងដែលដឹកចេញឱ្យទៅឆ្ងាយពីកន្លែងធ្វើកូដកម្ម ក្នុងឆ្នាំ២០២២។ ក្នុងអំឡុងពេលនេះ កងកម្លាំងសន្តិសុខជាច្រើនបានបៀតបៀនផ្លូវភេទលើសមាជិកសហជីព ហើយក្នុងឧបទ្ទវហេតុមួយនោះ បុរសជាមន្ត្រីម្នាក់បានចាប់ និងច្របាច់ដោះរបស់ស្ត្រីបាតុករមួយរូប នៅពេលដែលស្ត្រីរូបនោះត្រូវបានបង្ខំឱ្យឡើងលើរថយន្តក្រុង។

កាលពីខែវិច្ឆិកា ឆ្នាំ២០២២ អង្គការ ឃ្លាំមើលសិទ្ធិមនុស្ស បានចេញផ្សាយរបាយការណ៍ ៩៧ ទំព័រ ដែលមានចំណងជើងថា "មានតែសហជីពមិកញប់ ឬសហជីពស្និទ្ធនឹងថៅកែទេដែលអាចបន្តរស់រានបាន" ដែលចងក្រងជាឯកសារអំពីវិធី ដែលអាជ្ញាធរនៅកម្ពុជាអនុញ្ញាតឱ្យនិយោជកធ្វើប្រតិបត្តិការដោយ រំលងបទប្បញ្ញត្តិការងារ និងប្រព្រឹត្តិអំពើអយុត្តិធម៌ ដែលខ្លួនចោទថាខុសច្បាប់ទាំងនៅក្នុងប្រទេសកម្ពុជា និងច្បាប់អន្តរជាតិ។ [៣៦] របាយការណ៍នេះមានបញ្ចូលការសម្ភាសន៍ជាមួយមេដឹកនាំ និងសមាជិកសហជីពឯករាជ្យចំនួន ៣០ នាក់ ក្នុងវិស័យកាត់ដេរ និងទេសចរណ៍របស់កម្ពុជា។ នៅក្នុងសេចក្តីប្រកាសព័ត៌មានដែលផ្ញើទៅឱ្យសារព័ត៌មាន វីអូអេ (VOA) និងបណ្តាញសារព័ត៌មានផ្សេងទៀត អនុប្រធានទទួលបន្ទុកតំបន់អាស៊ីនៃអង្គការឃ្លាំមើលសិទ្ធិមនុស្សបានចោទប្រកាន់ទាំងរដ្ឋាភិបាលកម្ពុជា និង "និយោជកគ្មានគុណធម៌" ថាបាន "ប្រើប្រាស់ជំងឺរាតត្បាតកូវីដ-១៩ ជាលេសក្នុងការរឹតបន្តឹងសហជីពឯករាជ្យបន្ថែមទៀតជំនួសឱ្យការការពារសុខុមាលភាព និងសិទ្ធិរបស់កម្មករនៅក្នុងគ្រាអស់សង្ឃឹមនោះ"។ [៣៧]

នៅថ្ងៃទី២៦ ខែវិច្ឆិកា នគរបាលបានចាប់ខ្លួនជាថ្មីទៀត នូវមេដឹកនាំលេចធ្លោរបស់សហជីព LRSU គឺ ឈឹម ស៊ីថរ។ យោងតាមសេចក្តីថ្លែងការណ៍របស់អង្គការសិទ្ធិមនុស្សក្នុងស្រុក លីកាដូ បានឱ្យដឹងថា ស៊ីថរ ត្រូវបានចាប់ខ្លួននៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ បន្ទាប់ពីនាងវិលត្រឡប់មកពីប្រទេសអូស្ត្រាលី ដើម្បីចូលរួមសន្និសីទសហជីពរយៈពេល ១២ ថ្ងៃ។[៣៨]

នៅថ្ងៃទី ២៨ ខែវិច្ឆិកា អង្គការសង្គមស៊ីវិលក្នុងស្រុកប្រហែល ៧០ អង្គការ បានចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍រួមមួយ ដោយអំពាវនាវ "ឱ្យមានការដោះលែងពីពន្ធនាគារជាបន្ទាន់ និងដោយគ្មានលក្ខខណ្ឌ និងបញ្ចប់ការយាយីតាមប្រព័ន្ធតុលាការលើមេដឹកនាំ និងសមាជិកសហជីព"។[៣៩] មន្ត្រីនាំពាក្យក្រសួងការបរទេសសហរដ្ឋអាមេរិក បានចេញសេចក្តីអំពាវនាវនេះជាថ្មីដោយជំរុញឱ្យរដ្ឋាភិបាលកម្ពុជាបញ្ចប់ការកាត់ទោសមេដឹកនាំសហជីព និងកម្មករដែលធ្វើកូដកម្ម ហើយ "ឈានទៅដោះស្រាយវិវាទរបស់ពួកគេដោយប្រសិទ្ធភាព"។[៤០, ៤១]

ស៊ីចរ បន្តស្ថិតក្នុងពន្ធនាគារ ដោយស្ថិតក្នុងស្ថានភាព ដែលអង្គការការពារសិទ្ធិមនុស្សអន្តរជាតិ Frontline Defenders (FLD) រៀបរាប់ថា "ពិបាកខ្លាំង... ចង្អៀតដោយអ្នកទោស និងមានអនាម័យតិចតួច ឬគ្មានទាល់តែសោះ"។ អង្គការ FLD និយាយផងដែរថា "សិទ្ធិក្នុងការតវ៉ាដោយសន្តិវិធី និងការតស៊ូមតិដើម្បីសិទ្ធិការងារត្រូវតែមានការធានាក្រោមការប្តេជ្ញាចិត្តគោរពសិទ្ធិមនុស្សនៅថ្នាក់ជាតិ និងអន្តរជាតិ" ហើយបានអំពាវនាវឱ្យអាជ្ញាធរកម្ពុជាដោះលែងស្ត្រីជាអ្នកការពារសិទ្ធិមនុស្ស ឈឹម ស៊ីចរ ជាបន្ទាន់ និងដោយគ្មានលក្ខខណ្ឌ និងទម្លាក់រាល់បទចោទប្រកាន់ទាំងអស់មកលើរូបនាង។ [៤២]

## ៣.២. ផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុមកលើស្ត្រីជាកម្មករនិយោជិក

នៅខែមេសា ឆ្នាំ២០២២ អ្នកសិក្សាស្រាវជ្រាវឈានមុខគេរបស់ចក្រភពអង់គ្លេស និងកម្ពុជា ដែលធ្វើការជាមួយអង្គការសិទ្ធិការងារ មជ្ឈមណ្ឌលសាមគ្គី Solidarity Center បានចេញផ្សាយរបាយការណ៍ថ្មីមួយ ដែលស៊ើបអង្កេតពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមកលើស្ថានភាពការងារ សុខភាព និងសុខុមាលភាពរបស់កម្មករកាត់ដេរជិតមួយលាននាក់របស់កម្ពុជា។[៤៣] របាយការណ៍នេះបានរកឃើញថា"ផលប៉ះពាល់ពីអាកាសធាតុ និងបរិស្ថានមានទំនាក់ទំនងគ្នាយ៉ាងខ្លាំងជាមួយនឹងការធ្លាក់ចុះស្ថានភាពការងារក្នុងវិស័យកាត់ដេររបស់កម្ពុជា"។

របាយការណ៍នេះបានលើកឡើងថា ការប្រែប្រួលអាកាសធាតុ "មិនមែនជាបញ្ហាពេលអនាគតសម្រាប់កម្មករកាត់ដេរទេ ប៉ុន្តែជាបញ្ហាដែលកំពុងប៉ះពាល់ដល់ជីវិតកម្មករកាត់ដេរ ក្នុងនោះមានកម្មករជាងពីរភាគបី (៦៧%) ហើយដែលបច្ចុប្បន្នកំពុងជួបប្រទះផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ"។ តាមរយៈការសង្កេតលើសំណាកជាងពាក់កណ្តាល (៥៥%) បានបង្ហាញថា ការកើនឡើងនូវកម្តៅផែនដីជាមធ្យមនៃថ្ងៃដែលមានអាកាសធាតុក្តៅ ត្រូវបានបង្ហាញថាជាផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុដ៏ខ្លាំងបំផុត បើយោងតាមការយល់ឃើញដោយអ្នកធ្វើការក្នុងវិស័យនេះ។ នេះជាបញ្ហាដែលគេមានអារម្មណ៍ថា កំពុងកើតមាននៅក្នុងមជ្ឍដ្ឋានរោងចក្រ ដែលក្នុងនោះ មានមនុស្ស ២៦% ក្នុងចំណោមកម្លាំងពលកម្មក្នុងវិស័យរោងចក្រកាត់ដេរបានរាយការណ៍ថា នៅកន្លែងធ្វើការរបស់ពួកគេមានកម្តៅកើនឡើងខ្លាំងដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ។ ផលប៉ះពាល់ផ្សេងទៀតដែលត្រូវ បានរាយការណ៍ថាកើតមាននៅក្នុងមជ្ឍដ្ឋានរោងចក្រ រួមមានការកើនឡើងនូវការបំពុលខ្យល់ ទឹកជំនន់ អគ្គិភ័យ សត្វចង្រៃ និងការបំពុលទឹក។

របាយការណ៍នេះ ក៏បានសិក្សាឱ្យឃើញថា តើជីវភាពរបស់កម្មករកំពុងរងផលប៉ះពាល់បែបណានៅខាងក្រៅកន្លែងធ្វើការ។ សរុបរួម ២៩% នៃកម្មករទាំងនោះ បានរាយការណ៍អំពីការឆ្លងកាត់អាកាសធាតុអាក្រក់ ឬមហន្តរាយផ្សេងទៀតនៅកន្លែងស្នាក់នៅរបស់ខ្លួនក្នុងរយៈកាល ១២ ខែចុងក្រោយ។ ក្នុងចំណោមអ្នកដែលបានឆ្លងកាត់បញ្ហានេះ បញ្ហាដែលត្រូវបានរាយការណ៍ញឹកញាប់ជាងគេបំផុតគឺគ្រោះទឹកជំនន់ ដែលមានរហូតដល់ទៅ ៦៣% និង ៤២%ពីការកើនឡើងកម្តៅខ្លាំង។ ជាងមួយភាគបី (៣៨%) នៃកម្មករដែលរាយការណ៍អំពីទឹកជំនន់នៅតាមកន្លែងស្នាក់នៅរបស់ខ្លួន ក៏បានរាយការណ៍អំពីបញ្ហាសុខភាពដែលជាប់ពាក់ព័ន្ធផងដែរ ខណៈដែលជាងពីរភាគបី (៦៧%) នៃកម្មករដែលជួបប្រទះនឹងកម្តៅខ្លាំងលើសលុបនៅកន្លែងស្នាក់នៅរបស់ខ្លួនបញ្ជាក់ថា ស្ថានភាពបែបនោះបានធ្វើឲ្យសុខភាពរបស់ពួកគេមានការប៉ះពាល់។

យោងតាមអ្នកស្រាវជ្រាវ លទ្ធផលនៃរបាយការណ៍នេះ បានអំពាវនាវឱ្យមានការផ្តោតការយកចិត្តទុកដាក់ជាថ្មី នៅក្នុងកម្មវិធីឆ្លើយតបហានិភ័យគ្រោះមហន្តរាយ (DRR) នៅក្នុងប្រទេសកម្ពុជា ដោយផ្តោតលើការគាំទ្រដល់ប្រជាពលរដ្ឋ និងសហគមន៍ក្នុងទីក្រុងដែលមានចំណូលទាប ដើម្បីពង្រឹងភាពស៊ាំចំពោះហានិភ័យគ្រោះមហន្តរាយ ក្នុងការការពារសុខភាព និងសុវត្ថិភាពរបស់កម្មករនៅផ្ទះរបស់ពួកគេ ក៏ដូចជានៅកន្លែងធ្វើការផងដែរ។ និយាយឱ្យចំទៅ កម្មវិធីឆ្លើយតបហានិភ័យគ្រោះមហន្តរាយ (DRR) គួរត្រូវបានបញ្ជ្រាបទៅក្នុងយុទ្ធសាស្ត្រនគរូបនីយកម្មសន្តនិយម តាមរយៈការធ្វើសមាហរណកម្មបញ្ញត្តិនគរូបនីយកម្មគ្រប់ជ្រុងជ្រោយ ដែលមានទិសដៅផ្តោតលើការឆ្លើយតបហានិភ័យគ្រោះមហន្តរាយ (DRR) រាប់បញ្ចូលទាំងកូដបែងចែកតំបន់ និងកូដអគារផង ចូលទៅក្នុងផែនការមេទីក្រុងសម្រាប់ការអភិវឌ្ឍដែលទទួលបានការអនុញ្ញាត។ ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធលូ និងហេដ្ឋារចនាសម្ព័ន្ធការពារទឹកជំនន់ គួរតែត្រូវបានពង្រីកដល់តំបន់ជុំវិញទីក្រុង ដោយការវិនិយោគដើម្បីធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធលូ និងហេដ្ឋារចនាសម្ព័ន្ធស្នូលផ្សេងទៀតដូចជា ផ្លូវក្រាលកៅស៊ូ លើកផ្លូវឱ្យខ្ពស់ ទុយោទឹក និងប្រព័ន្ធការពារទឹកជំនន់។

លើសពីនេះ រដ្ឋាភិបាលគួរតែ "កែលម្អកិច្ចគាំពារសង្គមសម្រាប់ក្រុមជនងាយរងគ្រោះ ដែលជារឿយៗងាយរងគ្រោះដោយសារការប្រែប្រួលអាកាសធាតុ ហើយមានធនធានតិចតួចសម្រាប់ចាប់យករបរចិញ្ចឹមជីវិតផ្សេងទៀត"។ ឧទាហរណ៍ ការកាត់បន្ថយការពឹងផ្អែករបស់ប្រជាជនវ័យចំណាស់លើរបរចិញ្ចឹមជីវិត ឬផលិតផលដំណាំដាំដុះសម្រាប់លក់ ដើម្បីបានប្រាក់ចំណូលប្រើប្រាស់ពេលវ័យចំណាស់ និងការថែទាំសុខភាព នឹងជួយសម្រាលបន្ទុកខ្លះដល់កម្មករក្នុងឧស្សាហកម្មកាត់ដេរ ដើម្បីបន្តចូលរួមគាំទ្របន្ថែមទៀតដល់ផលិតកម្មកសិកម្មក្នុងគ្រួសារ។ ជាចុងក្រោយ រដ្ឋាភិបាលគួរតែដាក់បញ្ចូលកម្មករ និងសហជីពរបស់ពួកគេឲ្យចូលរួមនៅក្នុង "ការអភិវឌ្ឍក្របខណ្ឌបរិស្ថាន និងច្បាប់ជាតិ និងការត្រួតពិនិត្យ និងការអនុវត្តច្បាប់ចាំបាច់ ដើម្បីលើកទឹកចិត្តឱ្យមានការផ្លាស់ប្រែក្នុងការវិនិយោគទៅលើបរិស្ថានប្រកបដោយនិរន្តរភាពនិងយូរអង្វែង"។

## ផលប៉ះពាល់ពីគ្រោះមហន្តរាយពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុទៅលើសុខភាពស្ត្រី

នៅឆ្នាំ២០២១អង្គការរ៉ាក់ (RHAC) ក៏បានធ្វើការស្រាវជ្រាវបែបគុណវិស័យដើម្បីកំណត់ពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមកលើសុខភាពស្ត្រីផងដែរ។ [៤៤] លទ្ធផលបានបង្ហាញថា ផលប៉ះពាល់ទាំងនេះគឺមានភាពធ្ងន់ធ្ងរលើស្ត្រីច្រើនជាងបុរស ដោយសារស្ត្រីមានចំណេះដឹង និងការយល់ដឹងនៅមានកម្រិតអំពីការប្រែប្រួលអាកាសធាតុ និងសមត្ថភាពនៅមានកម្រិតក្នុងការសម្របខ្លួន។ លើសពីនេះទៀត ការស្រាវជ្រាវបានរកឃើញថាសេវាសម្រាប់ឆ្លើយតបទៅនឹងផលប៉ះពាល់ទាក់ទងនឹងសុខភាពដោយសារការប្រែប្រួលអាកាសធាតុនៅមានកម្រិតនៅឡើយ។ អាជ្ញាធរពាក់ព័ន្ធបានទទួលស្គាល់ថា ភាពមានកម្រិតទាំងនេះគឺមួយផ្នែកដោយសារការផ្សព្វផ្សាយអប់រំសុខភាពក្នុងបរិបទគ្រោះមហន្តរាយនៅតែបន្តផ្តោតលើការលើកកម្ពស់សុខភាពជាទូទៅ ដោយមិនបានផ្សារភ្ជាប់គ្រោះមហន្តរាយទៅនឹងសិទ្ធិសុខភាពផ្លូវភេទ សុខភាពបន្តពូជ (SRHR) ឡើយ។

អង្គការនេះ បានផ្តល់អនុសាសន៍ថា យន្តការរួមមួយគួរតែត្រូវបានបង្កើតឡើង ដើម្បីដោះស្រាយបញ្ហាសិទ្ធិសុខភាពផ្លូវភេទ និង សុខភាពបន្តពូជ (SRHR) ក្នុងអំឡុងពេលមានគ្រោះមហន្តរាយ ដោយចាត់ទុកជាកិច្ចការអាទិភាពសម្រាប់រដ្ឋាភិបាល និងភាគីពាក់ព័ន្ធដទៃទៀត។

លើសពីនេះ មធ្យោបាយសម្រាប់លើកកម្ពស់ការយល់ដឹង និងចំណេះដឹងអំពីទំនាក់ទំនងរវាង សិទ្ធិសុខភាពផ្លូវភេទ និង សុខភាពបន្តពូជ (SRHR) ជាមួយនិងការប្រែប្រួលអាកាសធាតុ/គ្រោះមហន្តរាយ គួរត្រូវបានបង្កើតឡើង និងមានធនធានសមស្រប ហើយគួរបង្កើនកិច្ចខិតខំប្រឹងប្រែងពហុវិស័យ ដើម្បីពង្រឹងសេវា សិទ្ធិសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ (SRHR) ក្នុងអំឡុងដំណាក់កាលឆ្លើយតបនៃការគ្រប់គ្រងគ្រោះមហន្តរាយ។

# ៤. ការអប់រំ

## ៤.១. លទ្ធភាពទទួលបានចំណេះដឹងដែលឆ្លើយតបនឹងយេនឌ័រ

បទដ្ឋានយេនឌ័របែបបុរាណនៅកម្ពុជានៅតែជាបញ្ហាចម្បង និងជំរុញឱ្យមានអំពើហិង្សាលើកុមារី និងស្ត្រី។ ការបង្កើតអត្តសញ្ញាណយេនឌ័រ និងទំនាក់ទំនងដោយផ្អែកលើវិសមភាពសង្គម សេដ្ឋកិច្ច កើតឡើងនៅក្នុងបរិយាកាសផ្សេងៗ ដូចជាសាលារៀន គ្រួសារ និងសហគមន៍ធំ។ សមភាពយេនឌ័រត្រូវបានរារាំងយ៉ាងខ្លាំងដោយសារអំពើហិង្សាផ្អែកលើយេនឌ័រដែលទាក់ទងនឹងនៅសាលារៀន ហើយបានក្លាយទៅជាឧបសគ្គធំក្នុងការសម្រេចបាននូវសមភាពយេនឌ័រ។ ប្រព័ន្ធអប់រំផ្តល់នូវឱកាសសម្រាប់អន្តរាគមន៍ប្រកបដោយភាពច្នៃប្រឌិត ជោគជ័យ និងយូរអង្វែង ដើម្បីបញ្ឈប់អំពើហិង្សាលើកុមារ និងក្នុងចំណោមកុមារ ព្រមទាំងផ្តល់ឱកាសសម្រាប់ការផ្លាស់ប្តូរអាកប្បកិរិយា និងគំនិតយល់ឃើញអំពីតួនាទីយេនឌ័រ។ ការស្រាវជ្រាវពីសាកលវិទ្យាល័យឡឺវ៉ែន (Leuven) សាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងអង្គការមិនមែនរដ្ឋាភិបាល VVOB ដែលបានបោះពុម្ពផ្សាយក្នុងឆ្នាំ២០២១ បានបង្ហាញថា ការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀនប្រកបដោយប្រសិទ្ធភាព ក្នុងការបង្រៀនដែលឆ្លើយតបនឹងយេនឌ័រ មានឥទ្ធិពលវិជ្ជមានទៅលើការកើតឡើងនៃអំពើហិង្សា ដែលសិស្សានុសិស្សជួបប្រទះនៅក្នុងសាលារៀន។[៤៥]

បន្ទាប់ពីគ្រូបង្រៀនចំនួន ៤៨០ នាក់ មកពីសាលាបឋមសិក្សា និងអនុវិទ្យាល័យក្នុងខេត្តបាត់ដំបង បានទទួលការអភិវឌ្ឍវិជ្ជាជីវៈជាមួយអង្គការ VVOB និងអង្គការសង្គមស៊ីវិលដៃគូ រួមជាមួយនឹងការគាំទ្រផ្នែកហិរញ្ញវត្ថុ និងការកសាងសមត្ថភាព សិស្សានុសិស្សបានរាយការណ៍ពីការថយចុះនូវការរំលោភបំពានផ្លូវអារម្មណ៍ ផ្លូវកាយ និងផ្លូវភេទ ដែលធ្លាប់បានជួបប្រទះនៅសាលារៀន ឬតាមផ្លូវទៅសាលារៀន។ [៤៦]

បន្ថែមលើនេះ សមាជិកចំនួន ១០៥ នាក់ នៃមហាវិទ្យាល័យអប់រំគ្រូបង្រៀនខេត្តបាត់ដំបង បានទទួលការបណ្តុះបណ្តាលចំណេះដឹងឆ្លើយតបនឹងយេនឌ័រ ដោយធានាថាគរុសិស្សទាំងនេះមានសមត្ថភាពអនុវត្តគោលការណ៍គរុកោសល្យនេះ នៅពេលចាប់ផ្តើមអាជីពរបស់ខ្លួនតាំងពីដំបូង។ [៤៧] ទោះបីជារាជរដ្ឋាភិបាលកម្ពុជា បានអនុញ្ញាតឱ្យមានការអនុវត្តគម្រោងគរុកោសល្យនេះក្តី ប៉ុន្តែពុំមានមូលនិធិដែលអាចបន្តដើម្បីពង្រីកគម្រោងនេះទេ បន្ទាប់ពីមូលនិធិដែលគាំទ្រដោយសហភាពអឺរ៉ុបនោះបានបញ្ចប់ទៅហើយ។ ដោយសារលទ្ធផលនៃការស្រាវជ្រាវបង្ហាញឱ្យឃើញពីសក្តានុពលរបស់កម្មវិធីបែបនេះ ក្នុងការបង្កើតបរិយាកាសសិក្សាដែលឆ្លើយតបនឹងយេនឌ័រ និងគ្មានអំពើហិង្សាសម្រាប់សិស្ស ដូច្នេះ ជាអនុសាសន៍ រាជរដ្ឋាភិបាលកម្ពុជាគួរចាត់វិធានការដើម្បីបញ្ចូល និងលើកកម្ពស់គរុកោសល្យឆ្លើយតបនឹងយេនឌ័រសម្រាប់គរុសិស្ស ក៏ដូចជាបញ្ចូលក្នុងគម្រោងអភិវឌ្ឍន៍វិជ្ជាជីវៈសម្រាប់គ្រូបង្រៀនដែលមានស្រាប់ផងដែរ (សូមមើលវគ្គ ៤.៤ សម្រាប់អនុសាសន៍លម្អិត)។

ចំណុចនេះមានសារៈសំខាន់ណាស់ បើយើងក្រឡេកមើលការសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការទទួលបន្ទុកអនុសញ្ញា ស៊ី-ដ របស់អង្គការសហប្រជាជាតិ ឆ្នាំ២០១៩ ក្នុងកថាខណ្ឌទី ៤២ ដែលមានបញ្ជាក់ពីក្ដីបារម្ភអំពី "ការយល់ដឹងអំពីយេនឌ័រមិនគ្រប់គ្រាន់នៅកម្ពុជា ក្នុងការអប់រំបច្ចេកទេស ការបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងកម្មវិធីបំណិនជីវិត ដែលជាការបង្កើនផ្ដត់គំនិតរើសអើងយេនឌ័រ និងនាំទៅរកការបាត់តំណាងក្មេងស្រី និងស្ត្រី ក្នុងការសិក្សា និងការចាប់យកជំនាញដែលមិនមែនតាមបែបប្រពៃណី"។ [៤៨]

## ៤.២. ផ្នត់គំនិតរើសអើងលើយេនឌ័រ និងឧបសគ្គចំពោះការអប់រំ

ការសិក្សាស្រាវជ្រាវមួយ ដែលបានបោះពុម្ពផ្សាយកាលពីឆ្នាំ២០២២ មានការអង្កេតលើសិស្សចំនួន ៥៨០ នាក់ ដែលរៀននៅថ្នាក់ទី ៧ ដល់ថ្នាក់ទី ១២ នៅសាលារៀនក្នុង និងជិតខេត្តសៀមរាប ប្រទេសកម្ពុជា។ របាយការណ៍នោះបានបែងចែកអ្នកចូលរួមក្នុងការអង្កេតទៅតាមប្រភេទផ្សេងៗ ដោយផ្អែកលើសេចក្ដីប្រាថ្នារបស់ពួកគេ ដែលមានដូចជា កម្រិតទាបនៅគ្រប់ផ្នែកទាំងអស់ មានកម្រិតខ្ពស់នៅក្នុងផ្នែកមួយ ដូចជាការមានគ្រួសារ មានជំនាញវិជ្ជាជីវៈ (ជោគជ័យក្នុងអាជីព និង/ឬការអប់រំនៅមហាវិទ្យាល័យ) និងការបម្រើសហគមន៍/ប្រទេស និងមានកម្រិតខ្ពស់នៅគ្រប់ផ្នែក។ [៤៩]

របាយការណ៍នេះបានកត់សម្គាល់ថា "មានឧបសគ្គជាច្រើនចំពោះការអប់រំរបស់ក្មេងស្រីនៅកម្ពុជា រួមមានការចូលរួមធ្វើការងារផ្ទះច្រើន កង្វះការគាំទ្រពីឪពុកម្ដាយ ការដាក់សម្ពាធឱ្យឆាប់រៀបការ ចំនួនស្ត្រីជាជនគំរូដែលមានទស្សនៈវិជ្ជមាននៅមានតិច និងមានការរឹតត្បិតក្នុងការនិយាយស្ដីជុំវិញភាពជាក្មេងស្រី/ភាពជាស្ត្រី"។ លទ្ធផលនៃការសិក្សាបានបង្ហាញថា ក្មេងស្រី/ស្ត្រីងាយនឹងស្ថិតក្នុងទម្រង់នៃការសង្ឃឹមទាប ឬខ្ពស់ តិចជាងក្មេងប្រុស/បុរស ហើយទំនងជាស្ថិតក្នុងទម្រង់នៃការរំពឹងចង់បានខ្ពស់ទាក់ទងនឹងគោលដៅវិជ្ជាជីវៈ/សេវា។ អ្នកស្រាវជ្រាវបានលើកឡើងថា "អាចថាក្មេងស្រីទំនងជាងក្មេងប្រុស ដែលត្រូវបានគេរំពឹងទុកថាត្រូវទទួលបានការអប់រំ និងមានអាជីព ដែលច្បាស់ណាស់ទាក់ទងនឹងការជួយដល់អ្នកដទៃ" ហើយថា បន្ទុកការងារថៃទាំខ្ពស់នាពេលនេះអាច "ជំរុញឱ្យទទួលបានសមិទ្ធផលបែបនេះជាបន្តទៀតប្រសិនបើការអប់រំ និងអាជីពរបស់ពួកគេត្រូវបានមើលឃើញថាជាមធ្យោបាយមួយដែលក្នុងនោះ ក្មេងស្រី អាចផ្ដល់ការគាំទ្របន្ថែមនាពេលអនាគត"។ ទោះជាយ៉ាងណាជារឿងសំខាន់ដែលត្រូវកត់សម្គាល់ថា គោលដៅជីវិតមិនមែនជាការនាំទៅរកភាពជោគជ័យក្នុងជីវិតទេ ប្រសិនបើមានឧបសគ្គរាំងច្រើន។

អ្នកស្រាវជ្រាវម្នាក់ទៀត បានសម្ភាសសិស្សានុសិស្ស និងបុគ្គលិកសង្គមកិច្ច នៅសាលារៀនសម្រាប់សិស្សស្រី ដែលដំណើរការដោយអង្គការមិនមែនរដ្ឋាភិបាលមួយ ដែលសាលារៀននេះស្ថិតនៅទីជនបទនៃប្រទេសកម្ពុជា ហើយអ្នកស្រាវជ្រាវនោះបានកត់សម្គាល់ឃើញថា ឪពុកម្ដាយមួយចំនួនកំពុងចាប់ផ្ដើមកែប្រែតួនាទីយេនឌ័រ ដោយលើកទឹកចិត្តកូនស្រីរបស់ខ្លួនឱ្យបន្តការអប់រំឱ្យបានខ្ពស់ ប៉ុន្តែ "ទំនួលខុសត្រូវបន្ថែមនេះ ក៏ជាប្រភពសម្ពាធសម្រាប់ក្មេងស្រីផងដែរ ដោយសារឪពុកម្ដាយរបស់ខ្លួនមានការរំពឹងកាន់តែខ្លាំងឡើងថា កូនស្រីរបស់ខ្លួននឹងជួយទាញខ្លួនឱ្យចាកចេញពីភាពក្រីក្រ"។ [៥០]

មន្ត្រីរដ្ឋាភិបាលមួយចំនួនបានកត់សម្គាល់នៅក្នុងឆ្នាំ២០២២ ថា បើទោះបីក្មេងជំទង់ជាច្រើនដែលមានផ្ទៃពោះបានបោះបង់ចោលការសិក្សាដោយសារតែការយាយី (bullying) ឬអារម្មណ៍នៃការខ្មាសអៀន ឬមិនមានការស្វាគមន៍ក្តី តាមពិតពួកគេគួរតែបន្តទៅសាលារៀនហើយអាជ្ញាធរគួរតែធ្វើការងារដើម្បីទប់ស្កាត់ការយាយីៗ [៥១]

របាយការណ៍វិភាគឆ្នាំ២០២២ លើគោលនយោបាយយេនឌ័ររបស់កម្ពុជាក្នុងវិស័យអប់រំ បានរកឃើញថា គោលនយោបាយជាលាយលក្ខណ៍អក្សរមានគ្រប់គ្រាន់ហើយ ប៉ុន្តែកង្វះមូលនិធិនៅតែជា"ឧបសគ្គដ៏ចំបងសម្រាប់ការអនុវត្តគោលនយោបាយក្នុងការធ្វើអោយប្រសើឡើងនៃការអប់រំសម្រាប់ស្ត្រី"។ ការសិក្សានេះក៏បានកត់សម្គាល់ផងដែរនូវការប្តេជ្ញាចិត្តទន់ខ្សោយក្នុងការអនុវត្តគោលនយោបាយនានា ដោយសារបទដ្ឋានយេនឌ័របែបបុរាណ និងប្រព័ន្ធសម្រាប់អនុវត្តគោលនយោបាយនានាដែលមិនមានប្រសិទ្ធភាព។ [៥២]

អង្គការ ក្លាហាន ដែលជាសមាជិករបស់ NGO-CEDAW បានបោះពុម្ពរបាយការណ៍មួយនៅឆ្នាំ២០២២ ស្តីពីការងារថែទាំដែលគ្មានប្រាក់កម្រៃ និងតួនាទីយេនឌ័រ ដោយផ្អែកលើការសម្ភាសន៍បែបគុណភាពចំនួន ៦០ ការពិភាក្សាក្រុម និងការឆ្លើយតបចំពោះការសិក្សាតាមអនឡាញ ចំនួន ២៥០។ អ្នកឆ្លើយតបក្នុងការសិក្សា ភាគច្រើនមានអារម្មណ៍ថា ស្ត្រីទទួលខុសត្រូវភាគច្រើនបំផុត ឬទាំងអស់លើការងារថែទាំនៅក្នុងផ្ទះដែលគ្មានប្រាក់កម្រៃ។ អ្នកផ្តល់សម្ភាសន៍ជាច្រើនបានសម្តែងការព្រួយបារម្ភថា ក្មេងប្រុសត្រូវបានអនុញ្ញាតឱ្យរៀននៅពេលល្ងាច ប៉ុន្តែក្មេងស្រីត្រូវធ្វើកិច្ចការផ្ទះ។ លទ្ធផលនៃការសិក្សាបានបង្ហាញថា អ្នកចូលរួមជាច្រើនមានការព្រួយបារម្ភថា បន្ទុកការងារថែទាំគ្មានប្រាក់កម្រៃនេះមិនត្រឹមតែបង្កជាឧបសគ្គដល់ការសិក្សារបស់ក្មេងស្រីប៉ុណ្ណោះទេ ប៉ុន្តែក៏ជាឧបសគ្គរារាំងដល់ឱកាសការងាររបស់ពួកគេផងដែរ។ [៥៣]

នៅទីបំផុត សិស្សស្រីៗ ទ្រាំនឹងការបៀតបៀនផ្លូវភេទ ជាពិសេសនៅពេលដែលមិនមានតុល្យភាពអំណាចរវាងគ្រូ និងសិស្ស ធ្វើឱ្យជនរងគ្រោះមួយចំនួនភ័យខ្លាចមិនហ៊ានរាយការណ៍អំពីការរំលោភបំពាន។ មានការកំណត់សម្គាល់លើករណីមួយ ដែលបានចុះផ្សាយជាសាធារណៈនៅ ឆ្នាំ២០២២ ទាក់ទងនឹងសិស្សស្រីជាអ្នកផលិតភាពយន្តមួយចំនួន ត្រូវបានបៀតបៀនដោយគ្រូបណ្តុះបណ្តាលពីរនាក់ ក្នុងកម្មវិធីបណ្តុះបណ្តាលរយៈពេលមួយឆ្នាំនៅមជ្ឈមណ្ឌលធនធានសោតទស្សន៍បុប្ផាណា។ សិស្ស មួយចំនួនបានរងការព្រមានថា ប្រសិនបើពួកគេឈប់ពីកម្មវិធីបណ្តុះបណ្តាល នោះពួកគេនឹងត្រូវសងប្រាក់ឧបត្ថម្ភដែលពួកគេបានទទួលកន្លងមក ដែលបង្កើតជារបាំងហិរញ្ញវត្ថុសម្រាប់ពួកគេក្នុងការគេចចេញពីវដ្តនៃអំពើហិង្សា។ [៥៤]

## ៤.៣. អត្រាបោះបង់ចោលការសិក្សារបស់សិស្ស

ប្រទេសកម្ពុជាបានធ្វើឲ្យមានភាពល្អប្រសើរច្រើន នូវអត្រាចុះឈ្មោះចូលរៀននៅគ្រប់កម្រិតនៃការអប់រំក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ ទោះជាយ៉ាងណាក្តី អត្រាបោះបង់ចោលការសិក្សានៅតែខ្ពស់ខ្លាំង។ អត្រាបោះបង់ការសិក្សានៅបឋមសិក្សាមានជាង ៧% ចាប់ពីឆ្នាំ២០១៩ ដល់ ២០២១។ [៥៥] យោងតាមស្ថិតិ និងសូចនាករអប់រំសាធារណៈ ឆ្នាំ២០២០-២០២១ របស់ក្រសួងអប់រំ យុវជន និងកីឡា (MoEYS) បង្ហាញថា ប្រមាណ ១៧% នៃសិស្សស្រីនៅកម្រិតអនុវិទ្យាល័យ (ថ្នាក់ទី ៧-៩) បានបោះបង់ចោលការសិក្សា ខណៈដែលអត្រាសិស្សប្រុសបោះបង់ចោលការសិក្សាមានរហូតដល់ទៅជាង ១៩%។ [៥៦]

ទោះជាយ៉ាងណា ការសិក្សាថ្មីមួយដែលចុះផ្សាយក្នុង ឆ្នាំ២០២២ ដោយអ្នកសិក្សាស្រាវជ្រាវឈ្មោះ Gehrke, Lehnel និង Schupp បានបង្ហាញថា អត្រាបោះបង់ការសិក្សារបស់សិស្សទាំងពីរភេទ អាចនឹងកាន់តែខ្ពស់ជាងនេះ ដោយសារមានសិស្សច្រើនទៀតបញ្ចប់ការសិក្សាត្រឹមថ្នាក់អនុវិទ្យាល័យ ប៉ុន្តែមិនបានឈានទៅដល់ថ្នាក់វិទ្យាល័យ។ [៥៧]សិស្សច្រើនបន្ថែមទៀតបោះបង់ការសិក្សានៅកម្រិតវិទ្យាល័យជារៀងរាល់ឆ្នាំ ដូច្នេះសិស្សជាងពាក់កណ្តាលមិនបានបញ្ចប់ថ្នាក់មធ្យមសិក្សាត្រឹមអាយុ ១៧ ឆ្នាំនោះទេ។ [៥៨]

ជារួមមក ទិន្នន័យបង្ហាញថាសិស្សប្រុសទំនងជាបោះបង់ការសិក្សាច្រើន ។ ទោះជាយ៉ាងណាការសិក្សាក៏បានកំណត់ពីភាពខុសគ្នាច្បាស់លាស់ ទាក់ទងនឹងហេតុផលនៅពីក្រោយការបោះបង់ការសិក្សានេះដែរ។ បើទោះបីជាសិស្សប្រុសងាយនឹងបោះបង់ការសិក្សាដើម្បីចាប់យកការងារដែលមានប្រាក់កម្រៃ (ជារឿយៗពាក់ព័ន្ធនឹងការធ្វើចំណាកស្រុកទៅប្រទេសថៃ) ឬចាប់ផ្តើមចូលរួមក្នុងវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ ប៉ុន្តែសិស្សស្រីទំនងជាបោះបង់ចោលការសិក្សា ដោយសារតែពួកគេត្រូវរៀបការ (ដែលការសិក្សាបានបង្ហាញថាជាមូលហេតុចម្បង ដែលសិស្សស្រីបោះបង់ចោលការសិក្សា) ឬដោយសារតែពួកគេត្រូវបានតម្រូវឱ្យជួយគ្រួសារនៅផ្ទះ។ ដូច្នេះហើយ សិស្សស្រីកាន់តែត្រូវពឹងផ្អែកគេខ្លាំងឡើងនៅពេលដែលពួកគេឈប់រៀន ខណៈពេលដែលសិស្សប្រុសហាក់ដូចជាកាន់តែមានភាពឯករាជ្យជាងមុន តាមរយៈការរកប្រាក់ចំណូលដោយខ្លួនឯង។

## ៤.៤. អនុសាសន៍សម្រាប់ការអប់រំ

ដើម្បីពន្លឿនវត្ថុបំណងគោលនយោបាយ (១) នៃផែនការមេអភិវឌ្ឍន៍សមត្ថភាពឆ្នាំ ២០២០-២០២៤ (CDMP) របស់ក្រសួងអប់រំ យុវជន និងកីឡា ដែលមានបំណងធានាឱ្យបាននូវការអប់រំប្រកបដោយបរិយាប័ន្ន សមធម៌ និងគុណភាព និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ក៏ដូចជាឆ្លើយតបឱ្យបានគ្រប់គ្រាន់ទៅនឹងអនុសាសន៍របស់គណៈកម្មាធិការ ស៊ី-ដ នៅក្នុងសេចក្តីអង្កេតសន្និដ្ឋានឆ្នាំ២០១៩ កថាខណ្ឌទី ៣៥ លើកឡើងថា រាជរដ្ឋាភិបាលកម្ពុជាគួរតែធានាឱ្យគ្រូបង្រៀន "ទទួលបានការបណ្តុះបណ្តាលជាទៀងទាត់ និងទូលំទូលាយអំពីសមភាពយេនឌ័រ ដើម្បីលុបបំបាត់ភាពលម្អៀងផ្អែកយេនឌ័រ និងផ្តត់គំនិតរើសអើងយេនឌ័រ" [៥៩] ជាអនុសាសន៍រដ្ឋាភិបាលគួរតែ៖

- ដាក់បញ្ចូលកម្មវិធីសិក្សា អំពីសមភាពយេនឌ័រ ទៅក្នុងសាលារៀនទាំងការសិក្សាផ្លូវការ និងក្រៅផ្លូវការ។ ឧទាហរណ៍ដូចជាការបញ្ចូលទៅក្នុងកម្មវិធីសិក្សាដូចខាងក្រោម៖
  - ក) តួនាទីយេនឌ័រ និងការបែងចែកកិច្ចការងារផ្ទះក្នុងគ្រួសារ
  - ខ) ឯកសារណែនាំសម្រាប់ការសិក្សា និងជំនាញគ្រប់គ្រងពេលវេលា
  - គ) បទដ្ឋានយេនឌ័រ និងការបៀតបៀនមកលើក្មេងស្រីនៅសាលារៀន
  - ឃ) ការដោះស្រាយទំនាស់ និងអំពើហិង្សានៅផ្ទះ
  - ង) សុខភាពផ្លូវចិត្ត និងការបញ្ចេញអារម្មណ៍តានតឹង

ភាគីពាក់ព័ន្ធដែលរួមមានអង្គការសង្គមស៊ីវិល និងក្រុមការងារបច្ចេកទេស គួរតែចូលរួមក្នុងដំណើរការរៀបចំកម្មវិធីសិក្សា ដើម្បីធានាថាខ្លឹមសាររបស់កម្មវិធីសិក្សាមានលក្ខណៈផ្លាស់ប្រែ សមស្របតាមអាយុ មានភាពចម្រុះ បរិយាប័ន្ន និងប្រទាក់ក្រឡាគ្នា។

- ពង្រឹងសមត្ថភាពភាគីពាក់ព័ន្ធទាំងអស់ ទាំងកម្រិតស្ថាប័ន និងកម្រិតបុគ្គល រួមមានមន្ត្រី គ្រូបង្រៀន មាតាបិតា និងអាណាព្យាបាល ដើម្បីផ្តល់នូវកម្មវិធីសិក្សាអំពីសមភាពយេនឌ័រ ដោយមានភ្ជាប់ជាមួយការអប់រំបណ្តុះបណ្តាល និងការណែនាំជាបន្តបន្ទាប់ ព្រមទាំងគាំទ្រដល់គរុកោសល្យដែលមានលក្ខណៈឆ្លើយតបយេនឌ័រ តាមរយៈការផ្តល់សម្ភារៈបង្រៀន និងរៀនតាមសាលាគរុកោសល្យទូទាំងប្រទេស។ ការធ្វើដូចនេះនឹងជួយពន្លឿនការសម្រេចបានលទ្ធផល (៥) និង (៦) នៃ ផែនការមេអភិវឌ្ឍន៍សមត្ថភាព (CDMP) ឆ្នាំ២០២០-២០២៤ របស់ក្រសួងអប់រំ យុវជន និងកីឡា។

- ធានាថា រាល់គំនិតផ្តួចផ្តើមដើម្បីជំរុញការអភិវឌ្ឍសមត្ថភាពជាប្រព័ន្ធ និងលើកកម្ពស់គរុកោសល្យដែលមានលក្ខណៈឆ្លើយតបនឹងយេនឌ័រសម្រាប់មន្ត្រីអប់រំត្រៀមចុះបម្រើការងារ និងកំពុងបម្រើការងារ និងអ្នកគ្រប់គ្រងសាលា ត្រូវបានអនុវត្តតាមវិធីសាស្ត្រនៅទូទាំងខេត្តទាំងអស់ ផ្ទុយពីការផ្តួចផ្តើមអនុវត្តគម្រោងដែលមានថេរវេលាខ្លីៗ។

- ធានាថា អន្តរាគមន៍ទៅតាមគោលដៅនានា ដូចជាការវាយតម្លៃសាលារៀនផ្តោតលើយេនឌ័រ ដើម្បីពិនិត្យមើលការរំលោភបំពានលើផ្លូវអារម្មណ៍ ផ្លូវកាយ និងផ្លូវភេទជាដើម ត្រូវបានរៀបចំឡើងដើម្បីតាមដានមើលការផ្លាស់ប្តូរក្នុងរយៈពេលមួយ ទាំងការផ្លាស់ប្តូរនៅកម្រិតបុគ្គល និងនៅកម្រិតស្ថាប័ន ហើយបន្ថែមទិន្នន័យពីចំណេះដឹងដែលទាក់ទងនឹងការទប់ស្កាត់អំពើហិង្សាផ្អែកលើយេនឌ័រនៅតាមសាលារៀន។

- ផ្សព្វផ្សាយ និងលើកទឹកចិត្តក្មេងស្រី និងស្ត្រីឱ្យចុះឈ្មោះចូលរៀនក្នុងមុខវិជ្ជាដែលមិនមែនជាមុខវិជ្ជាទូទៅដូចពីមុន ដូចជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM)។ ក្រសួងពាក់ព័ន្ធគួរតែបន្តកិច្ចសហប្រតិបត្តិការជាមួយគ្នា និងជាមួយភាគីពាក់ព័ន្ធខាងក្រៅ ដែលមកពីវិស័យសាធារណៈ និងឯកជន ដើម្បីពង្រីកការងារដែលមានស្រាប់នៅក្នុងវិស័យនេះ ឈានទៅរកការដោះស្រាយបញ្ហាប្រឈមក្នុងការអនុវត្ត និងដើម្បីផ្លាស់ប្តូរទស្សនៈយល់ឃើញអំពីតួនាទី និងសមត្ថភាពយេនឌ័រ។

# ៥. ស្ត្រីក្នុងភាពជាអ្នកដឹកនាំ

## ៥.១. ស្ត្រីក្នុងកិច្ចការនយោបាយ និងសាធារណៈ

យោងតាមរបាយការណ៍ចេញផ្សាយក្នុងខែធ្នូ ឆ្នាំ២០២២ ដោយគណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល) អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា (GADC) អង្គការសីលការ អង្គការបន្ទាយស្រី និងអង្គការអភិវឌ្ឍន៍សំឡេងសហគមន៍ (BCV) ស្តីពី "ការពង្រឹងអំណាចស្ត្រីក្នុងឆាកនយោបាយ និងការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២" ចំនួនបេក្ខជន និងអ្នកតំណាងនយោបាយជាស្ត្រីនៅកម្ពុជា នៅមានកម្រិតទាបនៅឡើយ។ [៦០]

បន្ទាប់ពីការបោះឆ្នោតឃុំ-សង្កាត់ខែមិថុនា ឆ្នាំ២០២២ ភាគរយសរុបនៃស្ត្រី និងបុរស ដែលជាប់ឆ្នោត ជាសមាជិកក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី ៥ ក្នុងឆ្នាំ២០២២ គឺ "លំអៀងខ្លាំងរវាងភេទទាំងពីរ [ដោយក្នុងនោះ] ស្ត្រីជាប់ឆ្នោតមាន ២២% និងបុរសជាប់ឆ្នោតមាន ៧៨%"។

ជាងនេះទៅទៀត មានតែ ១ នាក់ ប៉ុណ្ណោះ ក្នុងចំណោម ១០ នាក់ ជាមេឃុំដែលជាប់ឆ្នោតនៅទូទាំងប្រទេសក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់នេះជាស្ត្រី ហើយអ្នកនាំពាក្យរបស់គណបក្សកាន់អំណាចប្រាប់សារព័ត៌មានថា អ្វីដែលសំខាន់គឺគោលនយោបាយលើកកម្ពស់យេនឌ័រដែលមានប្រសិទ្ធភាព មិនមែនយេនឌ័ររបស់បេក្ខជននោះទេ [៦១]។ ស្ត្រីចំនួន ១៧៣ នាក់បានជាប់ឆ្នោតជាមេឃុំ ក្នុងចំណោមមេឃុំសរុបចំនួន ១,៦៥២ នាក់។ ទោះបីជាតួលេខនេះនៅមានកម្រិតតិចតួចក្តី ប៉ុន្តែតួលេខនេះមានការកើនឡើងនូវមេឃុំស្ត្រីចំនួន ៣២ នាក់ ឬស្មើពីរភាគរយពោលគឺកើនពី ៨% ទៅ ១០% ធៀបនឹងការបោះឆ្នោតឃុំសង្កាត់កាលពី ឆ្នាំ២០១៧។ ការវិភាគក្នុងរបាយការណ៍របស់អង្គការមិនមែនរដ្ឋាភិបាលបង្ហាញថា ចាប់ពីអាណត្តិទី ៤ ក្នុងឆ្នាំ២០១៧ តួលេខស្ត្រីជាប់ឆ្នោតក្នុងអាណត្តិទី ៥ ឆ្នាំ២០២២ ពិតជាតំណាងឱ្យកំណើនចំនួនស្ត្រីពិតមែន ទោះបីជាកំណើននោះមានកម្រិតតិចតួចត្រឹម ០.២% ក្តី។

ការប្រៀបធៀបចំនួនសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ជាបុរស និងស្ត្រី នៅក្នុងការបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី ៤ និងទី ៥



ស្ត្រី-បុរសជាសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ ឆ្នាំ២០១៧



ស្ត្រី-បុរសជាសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ ឆ្នាំ២០២២

**ប្រភព៖ គ.ជ.ប, ស្រង់ពី ខុមហ្វ្រែល។ "របាយការណ៍ស្តីពីការពង្រឹងអំណាចស្ត្រីក្នុងឆាកនយោបាយ និងការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២" ទំព័រ ១៤**

របាយការណ៍របស់អង្គការមិនមែនរដ្ឋាភិបាលដដែលនេះបានរៀបរាប់លម្អិតថា អ្នកនយោបាយស្ត្រីនៅកម្ពុជានៅតែប្រឈមមុខនឹងការរើសអើង និងអំពើហិង្សាជាច្រើនទម្រង់ក្នុងការចូលរួម និងផលប្រយោជន៍នយោបាយរបស់ពួកគាត់ ដោយក្នុងនោះអំពើហិង្សាលើស្ត្រីក្នុងវិស័យនយោបាយបានក្លាយជាបទពិសោធន៍ប្រចាំថ្ងៃរបស់ពួកគាត់ទៅហើយ សម្រាប់ស្ត្រីដែលចង់ចូលរួមក្នុងឆាកនយោបាយ និងជាអ្នកនយោបាយ។ របាយការណ៍នេះបានដកស្រង់ការអង្កេតកាលពី ឆ្នាំ២០២០ របស់អង្គការខុមហ្វ្រែល ស្តីពីការចូលរួមរបស់ស្ត្រីសកម្មជននយោបាយនៅក្នុងឆាកនយោបាយ ដែលបង្ហាញថា ៧១% នៃអ្នកឆ្លើយសំណួរ បានឆ្លងកាត់អំពើហិង្សាលើស្ត្រី ៨២% ជួបប្រទះនឹងការគំរាមកំហែង ៧០.៩% ឆ្លងកាត់អំពើហិង្សាផ្លូវចិត្ត ៣៤.៥% ទទួលរងការរំលោភបំពានលើរាងកាយ និង ៩.១% ធ្លាប់ឆ្លងកាត់ការបៀតបៀនផ្លូវភេទ។

ក្រៅពីការប្រថុយក្នុងការទទួលរងអំពើហិង្សា និងការបៀតបៀន ស្ត្រីនៅកម្ពុជាក៏ជួបប្រទះនឹងបញ្ហាប្រឈមជាច្រើនផ្សេងទៀតផងដែរ ក្នុងការចូលរួមក្នុងឆាកនយោបាយ និងការបោះឆ្នោត៖ ទីមួយ កង្វះគោលនយោបាយជាលាយលក្ខណ៍អក្សរជាក់លាក់ ដើម្បីផ្តល់ចំណាត់ការវិជ្ជមានបណ្តោះអាសន្ន និងកង្វះមាត្រាជាក់លាក់ក្នុងច្បាប់បោះឆ្នោតដើម្បីគាំទ្រ និងផ្តល់ឱកាសស្មើភាពគ្នាសម្រាប់ ស្ត្រី និង បុរស ដើម្បីចូលរួមក្នុងនយោបាយ រួមទាំងការឈរឈ្មោះជាបេក្ខជនប្រកបដោយសក្តានុពល ដែលមានឱកាសអាចជាប់ឆ្នោត។ ទី២ ការរើសអើងជាបន្តបន្ទាប់មកលើស្ត្រី ជាពិសេសកើតឡើងក្នុងអំឡុងពេលដំណើរការជ្រើសរើសបេក្ខជន និងការបោះឆ្នោតជ្រើសរើសបេក្ខជនក្នុងគណបក្សនយោបាយ។ ទីបី កង្វះឆន្ទៈនយោបាយរបស់គណបក្សនយោបាយ និងការប្តេជ្ញាចិត្តរបស់អ្នកដឹកនាំក្នុងការលើកកម្ពស់សមភាពយេនឌ័រក្នុងឆាកនយោបាយ និងនៅកម្រិតនៃអំណាចសម្រេចចិត្ត ។ ហើយចុងក្រោយ ផ្នត់គំនិតសង្គមតាមបែបប្រពៃណី ដែលរារាំងដល់ការលើកកម្ពស់ភាពជាអ្នកដឹកនាំរបស់ស្ត្រី ហើយជាឧបសគ្គចំពោះការចូលរួមរបស់ស្ត្រីជាអ្នកនយោបាយ។ របាយការណ៍ ឆ្នាំ២០២២ អះអាងថា ដោយសារហេតុផលទាំងនេះហើយទើប “ប្រទេសកម្ពុជានៅតែបន្តមានវិសមភាពនៃភាពជាតំណាង និងការអនុវត្តសិទ្ធិរវាងស្ត្រី និងបុរសក្នុងវិស័យនយោបាយ”។

អនុសាសន៍ពីរបាយការណ៍នេះ ទាក់ទងនឹងស្ត្រីក្នុងភាពជាអ្នកដឹកនាំក្នុងកិច្ចការនយោបាយ និងសាធារណៈ រួមមាន៖

- រដ្ឋសភា និងព្រឹទ្ធសភាគួរតែចាត់វិធានការវិជ្ជមាន ដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងផ្តល់ឱកាសសម្រាប់ស្ត្រីបានចូលរួមដោយស្មើភាពគ្នាក្នុងឆាកនយោបាយ រួមទាំងការធ្វើវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ព្រឹទ្ធសភា និងក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលកំណត់ឱ្យប្រើប្រព័ន្ធឆ្លាស់ (sandwich system) សម្រាប់ការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ។ ប្រព័ន្ធបែបនេះនឹងជំនួសបេក្ខជនស្ត្រី និងបេក្ខជនបុរសពីថ្នាក់លើដល់ថ្នាក់ក្រោម ហើយនឹងមានចំនួនស្ត្រីឈរឈ្មោះនៅជួរលើនៃពាក់កណ្តាលនៃបញ្ជីឈ្មោះបេក្ខជនទាំងអស់ ដើម្បីឱ្យស្ត្រីមិនត្រឹមតែក្លាយជាអនុប្រធានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាមន្ត្រីដែលមានឋានៈខ្ពស់បំផុតនៅក្នុងពាក់កណ្តាលនៃយុត្តាធិការ/ដែនសមត្ថកិច្ច។
- រាជរដ្ឋាភិបាលកម្ពុជា គួរសម្របសម្រួលសកម្មភាពដោយពិគ្រោះយោបល់ជាមួយអង្គការសង្គមស៊ីវិល រួមទាំងអង្គការសិទ្ធិស្ត្រី តួអង្គក្នុងវិស័យឯកជន និងទីភ្នាក់ងារប្រព័ន្ធផ្សព្វផ្សាយ ដើម្បីផ្លាស់ប្រែបទដ្ឋានយេនឌ័រដែលកំណត់ឱកាសរបស់ស្ត្រីក្នុងភាពជាអ្នកដឹកនាំ។ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន បណ្តាញសង្គម និងវេទិកាសហគមន៍ គួរត្រូវបានប្រើប្រាស់ដើម្បីជំនះផ្នត់គំនិតរើសអើងយេនឌ័រ ហើយបង្ហាញគំរូតួនាទីវិជ្ជមានរបស់ស្ត្រីជាមេដឹកនាំផង និងបុរសជាអ្នកតស៊ូមតិដើម្បីសិទ្ធិស្ត្រី និងស្ត្រីក្នុងភាពជាអ្នកដឹកនាំ។
- រាជរដ្ឋាភិបាលកម្ពុជា គួរដាក់ចេញនូវវិធានការច្បាប់ជាក់ស្តែង ដើម្បីជំរុញគោលដៅនៃការសម្រេចឱ្យបានសមភាពយេនឌ័រ ក្នុងក្រុមប្រឹក្សាឃុំ ឱ្យលើសពីគោលដៅរយៈពេលខ្លី ដែលមានរៀបរាប់ក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់កម្ពុជា។
- រាជរដ្ឋាភិបាលកម្ពុជា គួរតែចាត់វិធានការដើម្បីគាំទ្រស្ត្រីក្នុងតួនាទីចម្រុះ នៅក្នុងក្រុមប្រឹក្សាឃុំបន្ថែមលើតួនាទី គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារក្នុងឃុំ-សង្កាត់ (CCWC) ហើយកំណត់គោលដៅឱ្យមានតុល្យភាពយេនឌ័រសម្រាប់មុខតំណែងស្មៀនឃុំទាំងអស់។

- រាជរដ្ឋាភិបាលកម្ពុជា គួរបង្កើនគំនិតផ្តួចផ្តើមនានា ដើម្បីពង្រឹងការឆ្លើយតបផ្នែកយេនឌ័ររបស់ក្រុមប្រឹក្សាឃុំ ដើម្បីជំរុញសមភាពយេនឌ័រនៅក្នុងមុខងារ ចរិកា និងសកម្មភាពរបស់ក្រុមប្រឹក្សា។
- គណបក្សនយោបាយគួរអនុវត្តគោលនយោបាយ និងវិធានការដែលអាចអនុវត្តបាន ដើម្បីសម្រេចបានសមភាពយេនឌ័រ នៅក្នុងបញ្ជីបេក្ខជនរបស់ខ្លួន ដោយធ្វើការជាមួយរាជរដ្ឋាភិបាលកម្ពុជា និងភាគីពាក់ព័ន្ធសង្គមស៊ីវិលតាមភាពចាំបាច់ ដើម្បីគាំទ្រដល់ការអនុវត្តនេះ។

## ៥.២. ស្ត្រីក្នុងវិស័យសារព័ត៌មាន

ក្នុងចំណោមអ្នកសារព័ត៌មានកម្ពុជា ៥,០០០ នាក់ មានតែ ៤៧០ នាក់ (៩.៤%) ប៉ុណ្ណោះជាស្ត្រី។ របាយការណ៍ស្តីពី "ស្ថានភាពសេរីភាពសារព័ត៌មាននៅកម្ពុជា" ខែសីហា ឆ្នាំ២០២២ របស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) បានចងក្រងឯកសារបទសម្ភាសន៍ជាមួយអ្នកសារព័ត៌មានស្ត្រីចំនួន ៧ នាក់ ដែលសុទ្ធតែធ្លាប់បានរងការប្រមាថ និង/ឬបៀតបៀនផ្លូវភេទ ពីសំណាក់មន្ត្រីតំណាងរដ្ឋាភិបាលក្នុងពេលបំពេញការងាររបស់ពួកគេ។ បន្ថែមពីលើនេះ ស្ត្រីអ្នកសារព័ត៌មានទាំង ៧ រូប សុទ្ធតែរងសម្ពាធពីក្រុមគ្រួសារ ដែលជំរុញឱ្យពួកគេចាកចេញពីការងារនេះ ដែលគេចាត់ទុកថាមិនមានសុវត្ថិភាពសម្រាប់ស្ត្រី។ [៦២]

នៅថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០២២ វេទិកាស្ត្រីអ្នកសារព័ត៌មានៈ "សំឡេងយើង" ត្រូវបានរៀបចំឡើងដោយ មជ្ឈមណ្ឌលព័ត៌មានស្ត្រីកម្ពុជា (WMC)។ [៦៣] គោលបំណងនៃវេទិកានេះ រួមមានការផ្តល់ឱកាសដល់សិក្ខាកាមចំនួន ៦៩ នាក់ បានចែករំលែកបទពិសោធន៍ មតិយោបល់ និងបញ្ហាប្រឈមក្នុងអាជីពរបស់ខ្លួន និងដើម្បីកំណត់យុទ្ធសាស្ត្រសក្តានុពលក្នុងការដោះស្រាយបញ្ហាប្រឈមរបស់អ្នកសារព័ត៌មានស្ត្រី និងលើកទឹកចិត្តឱ្យនិស្សិតស្ត្រីសារព័ត៌មានជាច្រើនថែមទៀត ចូលរួមក្នុងអាជីពសារព័ត៌មាន។

សិក្ខាកាមទាំងនោះ រួមមាន ស្ត្រីអ្នកសារព័ត៌មានមកពីស្ថាប័នឯករាជ្យផ្សេងៗគ្នា ដែលធ្វើការនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងតួនាទីជាអ្នកយកព័ត៌មាន អ្នកគ្រប់គ្រងការផលិត អ្នកសរសេរអត្ថបទ និស្សិតប្រព័ន្ធផ្សព្វផ្សាយ និងការីនិពន្ធ ក៏ដូចជាតំណាងរបស់អង្គការសង្គមស៊ីវិលជាដើម។

របាយការណ៍សង្ខេបចងក្រងដោយ មជ្ឈមណ្ឌលព័ត៌មានស្ត្រីកម្ពុជា (WMC) ផ្តល់នូវសេចក្តីសង្ខេបអំពីសារសំខាន់ៗដែលកើតចេញពីការសន្ទនាជាក្រុម ការពិភាក្សាជាក្រុម បទបង្ហាញជាក្រុម និងការផ្តល់យោបល់ពីសិក្ខាកាមអំឡុងពេលសិក្ខាសាលារួម។ បញ្ហាប្រឈមសម្រាប់ស្ត្រីជាអ្នកសារព័ត៌មានដែលត្រូវបានលើកឡើងទៅតាមផ្នែកនីមួយៗដូចខាងក្រោមៈ

### ទំនាក់ទំនងក្នុងគ្រួសារ និងជីវិតនៅផ្ទះ

- ស្ត្រីជាអ្នកសារព័ត៌មានជាច្រើនបានលាលែងពីតំណែង ដោយសារតែទម្ងន់បន្ទុកការងារថែទាំនៅផ្ទះគ្មានប្រាក់កម្រៃ ដែលជាចំណែកមួយនាំឱ្យមានតំណាងតិចតួចសម្រាប់ស្ត្រីក្នុងវិស័យសារព័ត៌មាន។

- ឪពុកម្តាយភាគច្រើនមិនចង់ឱ្យកូនស្រីរបស់ខ្លួនធ្វើការជាអ្នកសារព័ត៌មាននោះទេ ដោយសារតែបញ្ហាសន្តិសុខ។ ស្ត្រីវ័យក្មេង មិនទទួលបានការលើកទឹកចិត្ត ឬត្រូវបានហាមប្រាមមិនឱ្យសិក្សាមុខវិជ្ជាសារព័ត៌មាន និងធ្វើការក្នុងប្រព័ន្ធផ្សព្វផ្សាយឡើយ។

## ទំនាក់ទំនងនៅកន្លែងធ្វើការ

- ស្ថាប័នភាគច្រើនមិនបានលើកទឹកចិត្ត និងគាំទ្រដល់និយោជិតជាស្ត្រីឱ្យធ្វើការលើប្រធានបទសំខាន់ៗទាក់ទងនឹងនយោបាយ ច្បាប់ និងសេដ្ឋកិច្ចឡើយ។
- ស្ថាប័នភាគច្រើនខ្វះការប្តេជ្ញាចិត្តក្នុងការបង្កើនចំនួនស្ត្រីនៅក្នុងរចនាសម្ព័ន្ធស្ថាប័នរបស់ខ្លួន។ ដោយសារអ្នកដឹកនាំភាគច្រើនជាបុរស ដូច្នេះខ្លឹមសារព័ត៌មានបង្ហាញពីសំឡេងបុរស។ ព័ត៌មានដែលផ្តោតលើស្ត្រី អំពើហិង្សាលើស្ត្រី និងសិទ្ធិស្ត្រី នៅតែមានការយកព័ត៌មានតិចតួច។
- ស្ថាប័នភាគច្រើនមិនផ្តល់ឱកាសបណ្តុះបណ្តាលសម្រាប់ស្ត្រី អំពីរបៀបប្រើប្រាស់កុំព្យូទ័រ និងប្រព័ន្ធផ្សព្វផ្សាយឌីជីថលទេ។ ជាលទ្ធផល អ្នកសារព័ត៌មានស្ត្រីជាច្រើនខ្វះការយល់ដឹង និងជំនាញក្នុងការប្រើប្រាស់ឧបករណ៍ប្រព័ន្ធផ្សព្វផ្សាយឌីជីថល។
- ស្ត្រីមានតំណាងតិចតួចក្នុងមុខតំណែងជាន់ខ្ពស់នៃស្ថាប័នប្រព័ន្ធផ្សព្វផ្សាយព័ត៌មានហើយសម្រាប់អ្នកដែលត្រូវបានតំឡើងតួនាទី ជារឿយៗ ប្រាក់ខែរបស់ពួកគេមិនសមនឹងមុខតំណែង និងទំនួលខុសត្រូវរបស់ខ្លួនឡើយ។
- ស្ថាប័នប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងប្រទេសកម្ពុជា មិនបានផ្តល់យន្តការបណ្តឹងសម្ងាត់ផ្ទៃក្នុងដល់បុគ្គលិកឡើយ ដូច្នេះមានការពិបាកក្នុងការតស៊ូមតិសម្រាប់ការកែលម្អកន្លែងធ្វើការ។

## ទំនាក់ទំនងនៅក្នុងសង្គម និងទីសាធារណៈ

- ស្ត្រីជាអ្នកសារព័ត៌មានប្រឈមខ្ពស់នឹងការបៀតបៀន និងការរំលោភបំពានផ្លូវភេទ ដែលនាំឱ្យមានភាពតានតឹងផ្លូវចិត្ត អារម្មណ៍ និងសម្ពាធផ្លូវចិត្ត។
- ការស្វែងរកព័ត៌មានគឺជារឿងពិបាកសម្រាប់ស្ត្រីអ្នកសារព័ត៌មាន ដោយសារតែមិនមានការសហការពីសង្គម (រួមទាំងអាជ្ញាធរ និងប្រភពផ្សេងទៀត)។ ពួកគេក៏ប្រឈមមុខនឹងការគំរាមកំហែង និងការបៀតបៀនតាមកម្មវិធីបណ្តាញផ្សព្វផ្សាយសង្គមផងដែរ។ បញ្ហានេះ កើតមានជាពិសេសចំពោះស្ត្រីជាអ្នកសារព័ត៌មាន ដែលធ្វើការលើបញ្ហារសើបដូចជាជម្លោះដីធ្លីជាដើម។ ពេលខ្លះ អាជ្ញាធរមូលដ្ឋានរារាំងស្ត្រីអ្នកសារព័ត៌មាន នៅពេលពួកគេចូលទៅស្វែងរកព័ត៌មានពីប្រភពជាដើម។
- ស្ត្រីជាអ្នកសារព័ត៌មាន ប្រឈមនឹងការរិះគន់ចំពោះរបៀបស្លៀកពាក់នៅកន្លែងសាធារណៈ និងទទួលរងការគំរាមកំហែង ជាពិសេសនៅពេលដែលរូបថត ឬវីដេអូដែលផលិតដោយពួកគេ ត្រូវបានផ្សព្វផ្សាយ។

# ៦. ការពពោះជំនួស

ពេញមួយ ឆ្នាំ២០២២ អត្ថបទព័ត៌មាន និងវីដេអូស៊ីជម្រៅ បានចុះផ្សាយអំពីស្ត្រីជាច្រើន ដែលក្នុងឆ្នាំ២០១៨ ត្រូវបានចោទប្រកាន់ពីបទល្មើសក្រោមច្បាប់ស្តីពីការជួញដូរមនុស្សរបស់កម្ពុជា ពីបទធ្វើជាអ្នកពពោះជំនួសឱ្យឪពុកម្តាយជាជនបរទេស។ [៦៤, ៦៥] បន្ទាប់ពីបានស្ថិតក្នុងការឃុំឃាំងរយៈពេលយូរនៅក្នុងមន្ទីរពេទ្យយោធាអំឡុងពេលមានផ្ទៃពោះ ស្ត្រីទាំងនេះបានទទួលការព្យួរទោស ក្រោមលក្ខខណ្ឌតាមកាតព្វកិច្ចដែលពួកគេត្រូវពពោះតាមកាលកំណត់ ហើយចិញ្ចឹមកូននោះជាកូនរបស់ខ្លួនឯងផ្ទាល់។ លើសពីនេះទៀត យ៉ាងហោចណាស់មានបុរសជាឪពុកម្នាក់ ត្រូវបានកាត់ទោសពីបទជួញដូរមនុស្ស និងកាត់ទោសឱ្យជាប់ពន្ធនាគារ ១៥ ឆ្នាំ ពីបទព្យាយាមនាំកូនប្រុសបង្កើតរបស់ខ្លួនទៅប្រទេសចិន បានប្តឹងឧទ្ធរណ៍ជំទាស់នឹងការផ្តន្ទាទោសលើរូបគាត់នៅក្នុងខែមករា ឆ្នាំ២០២២។ [៦៦]
ទោះជាយ៉ាងណា អត្ថបទសារព័ត៌មានកាលពីឆ្នាំ២០២២ មានបញ្ចូលនូវសក្ខីកម្មអំពីផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុ និងផ្លូវចិត្តដែលបន្តកើតមានមកលើស្ត្រីដែលរដ្ឋបង្ខំឱ្យចិញ្ចឹមកូន ដែលមិនមែនជាកូនបង្កើតរបស់ខ្លួន។

ដូចដែលគណៈកម្មាធិការទទួលបន្ទុកអនុសញ្ញា ស៊ី - ដ បានធ្វើកំណត់សម្គាល់នៅក្នុងសេចក្តីអង្កេតសន្និដ្ឋានឆ្នាំ២០១៩ ក្នុងកថាខ័ណ្ឌទី ៤៦ កាតព្វកិច្ចមួយនេះជាការដាក់បន្ទុករយៈពេលវែងដល់ស្ត្រីដែលរស់នៅក្នុងស្ថានភាពមិនច្បាស់លាស់ ដែលស្ថានភាពនោះហើយនាំឱ្យពួកគេដើរតួជាអ្នកពពោះជំនួសតាំងពីដំបូង។ ស្ត្រីមួយចំនួនបានរាយការណ៍ថាកំពុងប្រឈមមុខនឹងការរើសអើង និងការប្រមាថពីសំណាក់សហគមន៍របស់ខ្លួន ហើយមានស្ត្រីម្នាក់ បានរៀបរាប់ថា ការលាបពណ៌សក់កូនប្រុសដែលគាត់ពពោះជំនួសនោះ ឱ្យខ្មៅបន្តិច ដើម្បីកុំឱ្យកូនប្រុសនោះខុសពីគេពេក។[៦៧]

ជារឿងដែលគួរឱ្យព្រួយបារម្ភ ក៏មានរបាយការណ៍នានាអំពីស្ត្រីពពោះជំនួស កំពុងស្ថិតក្រោមការតាមដានពីសំណាក់អង្គការប្រឆាំងអំពើជួញដូរមនុស្សរបស់សហរដ្ឋអាមេរិក ដែលសហការជាមួយនឹងរដ្ឋាភិបាល ដើម្បីធានាថាកុមារនោះនៅតែស្ថិតក្រោមការថែទាំរបស់ស្ត្រីនោះដដែល [៦៨] ហើយរបាយការណ៍នេះ មានភាពស៊ីសង្វាក់គ្នានឹងរបាយការណ៍មុនៗ ពីឆ្នាំ២០២០។ [៦៩] ស្ត្រីពពោះជំនួសផ្សេងទៀតបានប្រាប់សារព័ត៌មានញូវយ៉កថាមស៍ (NYT) ថា ពួកគេក៏ត្រូវ "រាយការណ៍ទៅប៉ុស្តិ៍នគរបាលផងដែរ ដោយនាំកុមារទៅជាមួយ" ដោយនិយាយថា ការធ្វើបែបនេះធ្វើឱ្យពួកគេមានអារម្មណ៍ថា "... យើងដូចជាឧក្រិដ្ឋជន" ហើយថា "កូនរបស់យើងដូចកូនជនល្មើស"។ អង្គការសប្បុរសធម៌ប្រឆាំងការជួញដូរមនុស្ស មិនមានសិទ្ធិធ្វើការត្រួតពិនិត្យ ឬសកម្មភាពអនុវត្តច្បាប់ណាមួយឡើយ ហើយជារឿងគួរកត់សម្គាល់ផងដែរថា រដ្ឋកម្ពុជាមានតួនាទីដើម្បីធានាថាមានការគោរព និងការពារសិទ្ធិឯកជនភាព និងជីវិតគ្រួសារ។

សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងការពពោះជំនួស ដែលត្រូវបានរៀបចំដំបូងកាលពីចុងឆ្នាំ២០១៦ មិនទាន់ត្រូវបានផ្សព្វផ្សាយជាសាធារណៈនៅឡើយទេ។ តំណាងនានារបស់រាជរដ្ឋាភិបាលបានជូនដំណឹងក្នុងខែមេសា ឆ្នាំ២០២២ ថា សេចក្តីព្រាងច្បាប់នោះនឹងត្រូវបានបញ្ចប់ក្នុងពេលឆាប់ៗនេះ ដោយក្នុងនោះអ្នកនាំពាក្យក្រសួងកិច្ចការនារី បានជូនដំណឹងថា សេចក្តីព្រាងច្បាប់នោះ "នឹងត្រូវបានដាក់ឱ្យប្រើប្រាស់ក្នុងពេលដ៏ខ្លីខាងមុខនេះ"។ [៧០]

សេចក្តីអង្កេតសន្និដ្ឋានឆ្នាំ២០១៩ របស់គណៈកម្មាធិការទទួលបន្ទុកអនុសញ្ញា ស៊ី-ដ បានលើកទឹកចិត្ត ឱ្យរដ្ឋាភិបាលកម្ពុជា ធានាថាសេចក្តីព្រាងច្បាប់ណាមួយ "មិនត្រូវដាក់ការទទួលខុសត្រូវព្រហ្មទណ្ឌ ឬ ទណ្ឌកម្មរដ្ឋបាលលើស្ត្រីដែលដើរតួជាអ្នកពពោះជំនួសឡើយ" [កថាខណ្ឌ ៤៧]។

ទោះជាយ៉ាងណា បទប្បញ្ញត្តិមួយចំនួននៃពង្រាងច្បាប់ ខែកញ្ញា ឆ្នាំ២០១៩ ត្រូវបានព្រាងឡើងដោយ ភាពមិនច្បាស់លាស់ ហើយអាចនឹងត្រូវបានប្រើដើម្បីដាក់ទោសចំពោះអ្នកពពោះជំនួស។ ឧទាហរណ៍ មានមាត្រាមួយចែងថា "បុគ្គលណាដែលប្រើប្រាស់បច្ចេកវិទ្យាបន្តពូជជំនួយសម្រាប់ការពពោះជំនួស ដោយគ្មានការអនុញ្ញាតពីគណៈកម្មាធិការជាតិគ្រប់គ្រងការពពោះជំនួស នឹងត្រូវផ្តន្ទាទោសដាក់ ពន្ធនាគារ ... និងពិន័យជាប្រាក់"។

មន្ត្រីនាំពាក្យក្រសួងកិច្ចការនារី បានបន្ថែមថា ការពពោះជំនួសនៅតែត្រូវបានចាត់ទុកថាជាការជួញដូរ មនុស្ស ប្រសិនបើកុមារ "ត្រូវបានលក់ពីមនុស្សម្នាក់ទៅឱ្យមនុស្សម្នាក់ទៀត ហើយគេលែងដឹងពី ជោគវាសនារបស់កុមារនោះហើយ"។ គួរកត់សម្គាល់ថា សេចក្តីព្រាងច្បាប់ស្តីពីការពពោះជំនួសនឹង មិនធ្វើទីត្បានុកូលកម្មអាជីវកម្មពពោះជំនួស ឬការពពោះជំនួសជាលក្ខណៈអន្តរជាតិឡើយ ហើយមិន បានបញ្ជាក់ អំពីការបម្លាស់ទីរបស់កុមារឆ្លងដែននោះដែរ។ ការប្រើប្រាស់ច្បាប់ស្តីពីអំពើជួញដូរមនុស្ស និងក្រមព្រហ្មទណ្ឌដែលមានស្រាប់ ដើម្បីដាក់ទោសទណ្ឌចំពោះសកម្មភាពពពោះជំនួសដោយមិនមាន ការអនុញ្ញាត គ្រោងនឹងត្រូវបន្តប្រើប្រាស់ព្រមជាមួយនឹងច្បាប់ថ្មីស្តីពីការពពោះជំនួស។ ច្បាប់នោះនឹង មិនស្របទៅតាមអនុសាសន៍របស់ របស់គណៈកម្មាធិការទទួលបន្ទុកអនុញ្ញា ស៊ី-ដ ឆ្នាំ២០១៩ នោះទេ ប្រសិនបើមិនមានបទប្បញ្ញត្តិ ឬច្បាប់ថ្មីណាមួយបញ្ជាក់យ៉ាងច្បាស់ថា ទាំងច្បាប់នេះ ឬច្បាប់ផ្សេង ទៀតនឹងមិនត្រូវបានប្រើប្រាស់ដើម្បីចោទប្រកាន់ ដាក់ទោស ឬដាក់បម្រាមលើស្ត្រីដែលដើរតួជាអ្នក ពពោះជំនួសដោយគ្មានការអនុញ្ញាត។

ជាងនេះទៅទៀត ការរឹតបន្តឹងនៅក្នុងសេចក្តីព្រាងច្បាប់ ឆ្នាំ២០១៩ លើអ្នកដែលអាចក្លាយជាឪពុក ម្តាយពពោះជំនួស ហើយអ្នកណាអាចដើរតួជាអ្នកពពោះជំនួសនោះ គឺជាការរើសអើងយ៉ាងច្បាស់ និងពឹងផ្អែកលើផ្នត់គំនិតដែលរើសអើងលើតួនាទីយេនឌ័រ។ ឧទាហរណ៍ ក្រៅពីការរឹតបន្តឹងផ្សេងទៀត មានការរឹតបន្តឹងមួយដែលកំណត់ថា មានតែស្ត្រីខ្មែរដែលរៀបការ និងមានកូនរួចហើយ ប៉ុន្តែមិនធ្លាប់ បានពពោះជំនួសពីមុន ដោយមានការអនុញ្ញាតពីស្វាមីជាជនជាតិខ្មែរ ប៉ុណ្ណោះ អាចធ្វើការសម្រេចចិត្ត ទាក់ទងនឹងការក្លាយជាអ្នកពពោះជំនួស ឬមាតាបិតាពពោះជំនួស ឬធ្វើការសម្រេចចិត្តផ្នែកវេជ្ជ សាស្ត្រជុំវិញទារកក្នុងគភ៌នោះ ប្រសិនបើមានបញ្ហាសុខភាពបន្ទាន់កើតឡើង។ ជាងនេះទៅទៀត ឪពុក ម្តាយបង្កើតក៏ត្រូវតែជាគូស្វាមីភរិយាជនជាតិខ្មែរដែលមិនដែលមានកូនទៀត។ ជាចុងក្រោយទីភ្នាក់ ងាររដ្ឋាភិបាល ត្រូវតែអនុម័តជាមុនលើកិច្ចព្រមព្រៀងណាមួយស្តីពីការពពោះជំនួស។ នេះមានន័យថា ស្ត្រីមានសិទ្ធិបញ្ចេញមតិតិចតួចជុំវិញសុខភាពបន្តពូជរបស់ខ្លួន ដោយប្រគល់ឱ្យរដ្ឋាភិបាល និងស្វាមី ជាអ្នកធ្វើការសម្រេចចិត្តសម្រាប់ខ្លួនទៅវិញ។ មនុស្សនៅលីវ និងគូស្នេហ៍ អ្នកស្រឡាញ់ភេទដូចគ្នា (LGBTIQ) មិនអាចក្លាយជាអ្នកពពោះជំនួស ឬឪពុកម្តាយបានទេ។ មានផ្នែកខ្លះចែងថា អ្នកមិនមែន ជាពលរដ្ឋនៃប្រទេសមិនអាចចូលរួមការពពោះជំនួសនេះបានទេ ទោះបីជារៀបការជាមួយជនជាតិខ្មែរ ក៏ដោយ។ ដើម្បីអនុលោមតាមអនុសាសន៍របស់គណៈកម្មការទទួលបន្ទុកអនុសញ្ញា ស៊ី-ដ រាល់បទ ប្បញ្ញត្តិនានាមិនត្រូវពឹងផ្អែកលើផ្នត់គំនិតផ្សេងៗ ដើម្បីកំណត់ថា តើអ្នកណាទើបអាចដើរតួជាអ្នក ពពោះជំនួស និងឪពុកម្តាយនោះទេ។

បន្ថែមនៅក្នុងសេចក្តីព្រាងច្បាប់ឆ្នាំ២០១៩ អាជីវកម្មពពោះជំនួសនៅតែត្រូវបានហាមឃាត់។ ការពពោះជំនួសតាមធម្មជាតិ ជាជាងការប្រើបច្ចេកវិទ្យាជំនួយ មិនត្រូវបានលើកយកមកនិយាយនោះទេ។ តាមពិតទៅ ផលប៉ះពាល់ជាក់ស្តែងនៃច្បាប់ នឹងបន្តហាមឃាត់ស្ទើរតែរាល់ការរៀបចំ ការពពោះជំនួស ហើយបង្កើតវិធីថ្មីដើម្បីដាក់ទោសជនណាដែលប៉ុនប៉ងធ្វើការពពោះជំនួសនោះ។

ជាអនុសាសន៍៖

- រដ្ឋាភិបាល និង/ឬនគរបាលបញ្ឈប់រាល់ការពិនិត្យតាមដាន ឬការឃ្លាំមើលស្ត្រីដែលធ្លាប់ធ្វើជាអ្នកពពោះជំនួសពីមុន ដើម្បីការពារសិទ្ធិឯកជនភាពរបស់ពួកគាត់។ រាល់សេចក្តីសម្រេចរបស់តុលាការ ដែលបង្ខំស្ត្រីដែលបានធ្វើជាអ្នកពពោះជំនួសឱ្យចិញ្ចឹមកូនរហូតដល់ពេញវ័យ ត្រូវលុបចោលជាបន្ទាន់។
- លុបចោលភ្លាមៗនូវការផ្តន្ទាទោសលើស្ត្រីពពោះជំនួស និងសេចក្តីសម្រេចរបស់តុលាការដែលបង្ខំស្ត្រីដែលដើរតួជាអ្នកពពោះជំនួសឱ្យចិញ្ចឹមកូនរហូតដល់ពេញវ័យ។
- រដ្ឋាភិបាលគួរតែបញ្ឈប់សកម្មភាពណាមួយ ក្នុងការជំរុញច្បាប់ស្តីពីការពពោះជំនួសនេះឱ្យទៅមុខ ដោយមិនបានផ្សព្វផ្សាយសេចក្តីព្រាងច្បាប់នេះជាសាធារណៈជាមុន និងធ្វើការពិគ្រោះយោបល់ប្រកបដោយអត្ថន័យជាមួយតួអង្គសង្គមស៊ីវិលពាក់ព័ន្ធ។
- ជំនួសឱ្យការបង្កើតច្បាប់ថ្មី ត្រឹមការចេញប្រកាសស្តីពីការពពោះជំនួសអាចមានប្រសិទ្ធភាពជាង ដោយបញ្ជាក់ឱ្យច្បាស់អំពីគោលជំហររបស់រាជរដ្ឋាភិបាលថា ស្ត្រីទាំងអស់នឹងមិនត្រូវបានដាក់ទោសទណ្ឌនោះទេ បើគ្រាន់តែពួកគាត់ដើរតួជាអ្នកពពោះជំនួសនោះ។

# ៧. លទ្ធភាពទទួលបានការថែទាំសុខភាព

## ៧.១. លទ្ធភាពទទួលបានការថែទាំសុខភាពក្នុងចំណោមពលករចំណាកស្រុកដែលត្រូវបានបញ្ជូនត្រលប់មកវិញ

ត្រឹមឆ្នាំ២០២០ ចំនួនជនចំណាកស្រុកកម្ពុជាដែលស្វែងរកការងារធ្វើនៅក្រៅប្រទេស ត្រូវបានប៉ាន់ប្រមាណថាមានចំនួន ១,១ លាននាក់ ឬប្រហែល ៧% នៃចំនួនប្រជាជនសរុប។ ក្នុងចំណោមជនចំណាកស្រុកដែលកំពុងស្វែងរកការងារធ្វើ មានប្រហែល ៤០% ជាស្ត្រី។ មូលហេតុភាគច្រើននៃការធ្វើចំណាកស្រុកគឺដោយសារភាពអត់ការងារធ្វើ ប្រាក់ឈ្នួលទាបបើប្រៀបធៀបទៅនឹងប្រទេសជិតខាង និងការបាត់បង់ដីធ្លី។ ភាគច្រើនបំផុតនៃអ្នកដែលស្វែងរកការងារនៅបរទេសត្រូវបានចាត់ទុកថា "គ្មានជំនាញ" ហើយមកពីតំបន់ជនបទ។

ទោះបីជាការធ្វើចំណាកស្រុកត្រូវបានទទួលស្គាល់ថាជាកត្តារួមចំណែកដល់ការអភិវឌ្ឍជីវភាព និងសេដ្ឋកិច្ចរបស់ប្រទេសទាំងមូលក៏ដោយ ប៉ុន្តែអន្តរាគមន៍នានានៅមានកម្រិតតិចតួចប៉ុណ្ណោះ ដើម្បីការពារសិទ្ធិរបស់ពលករចំណាកស្រុកដែលត្រូវបានបញ្ជូនត្រឡប់មកវិញ (RMW) រួមទាំងសិទ្ធិទទួលបានព័ត៌មាន និងសេវាទាក់ទងនឹងការថែទាំសុខភាពផងដែរ។

រឿងនេះកើតឡើង បើទោះបីជាពលករចំណាកស្រុកដែលត្រូវបានបញ្ជូនត្រឡប់មកវិញ (RMW) មានការប្រឈមមុខនឹងវិបត្តិសេដ្ឋកិច្ចក្នុងគ្រួសារក៏ដោយ រាប់បញ្ចូលទាំងបំណុល បញ្ហាសុខភាព និងការលំបាកក្នុងការស្វែងរកការងារសមរម្យដែលមានប្រាក់ឈ្នួលផងដែរ ខណៈជំងឺរាតត្បាតបានធ្វើឱ្យបញ្ហាទាំងនេះកាន់តែមានសភាពធ្ងន់ធ្ងរខ្លាំងឡើង សម្រាប់ពលករចំណាកស្រុកទាំងនោះ។

នៅក្នុងការសិក្សាមួយកាលពី ឆ្នាំ២០២២ ដែលពិនិត្យលើស្ថានភាពនៃលទ្ធភាពទទួលបានការថែទាំសុខភាពសម្រាប់ពលករចំណាកស្រុកជនជាតិខ្មែរដែលត្រូវបានបញ្ជូនត្រឡប់មកវិញ (RMW) [៧១] នោះ អង្គការថែទាំសុខភាពគ្រួសារកម្ពុជា (អង្គការ រ៉ាក់) បានរកឃើញថា៖

- ៥៩.៥៤% បានបង្ហាញថា មានចំណេះដឹងអំពី សិទ្ធិ និងសុខភាពបន្តពូជ (SRHR)
- ទោះបីជាអ្នកចូលរួមការសិក្សានោះ មានត្រឹម ២.០៦% បង្ហាញថា ពួកគេមិនដែលលឺពីមេរោគអេដស៍/ជំងឺអេដស៍ក្តី ប៉ុន្តែ ជាងពាក់កណ្តាល (៥២.៣២%) នៃអ្នកទាំងនោះ មានអារម្មណ៍ថាជំងឺនេះអាចព្យាបាលបាន ហើយ ៦.៧% យល់ថា គេអាចកំណត់ពីស្ថានភាពមេរោគអេដស៍របស់មនុស្សណាម្នាក់ ដោយពុំចាំបាច់ធ្វើតេស្តរកមេរោគអេដស៍នោះទេ។
- អ្នកចូលរួមក្នុងការសិក្សាត្រឹមតែ ១៨% ប៉ុណ្ណោះ ដែលរាយការណ៍ថា គេដឹងថា មានវ៉ាក់សាំងសម្រាប់ជំងឺមហារីកមាត់ស្បូន។
- អ្នកឆ្លើយសំណួរត្រឹមតែ ៧.០៦% ប៉ុណ្ណោះ ដែលដឹងថា ការរំលូតកូនជារឿងស្របច្បាប់នៅកម្ពុជា។
- ចំណេះដឹងក្នុងចំណោមអ្នកឆ្លើយសំណួរទាំងនោះនៅមានកម្រិតនៅឡើយ ទាក់ទងនឹងជំងឺកាមរោគ (STIs) ហើយភាគច្រើនបានបង្ហាញថា ពួកគេនឹងមិនគិតរឿងទៅរកសេវាថែទាំសុខភាពឡើយ លុះត្រាតែគេមានរោគសញ្ញាធ្ងន់ធ្ងរ។

នៅពេលស្ថិតក្នុងប្រទេសគោលដៅ អ្នកឆ្លើយសំណួរទាំងនោះ បាននិយាយថា ពួកគេបានជួបប្រទះនឹងបញ្ហាប្រឈមផ្សេងៗក្នុងការស្វែងរកសេវាថែទាំសុខភាព ដោយសារតែហេតុផលជាច្រើន។ ក្នុងនោះរួមមាន ការពុំមានលុយគ្រប់គ្រាន់ដើម្បីអាចចំណាយលើការព្យាបាលសុខភាព ឧបសគ្គក្នុងការប្រាស្រ័យទាក់ទង និងភាសា។

អ្នកដែលបានធ្វើការដោយពុំមានឯកសារ បាននិយាយថា ពួកគេមិនអាចទៅគ្លីនិក ឬកន្លែងផ្តល់សេវាសុខភាពសាធារណៈផ្សេងទៀតបានឡើយ ប្រសិនបើមិនមាននិយោជក/ថៅកែរបស់ពួកគេទៅជាមួយទេនោះ។ អ្នកឆ្លើយសំណួរជាច្រើន ដែលជាពលករចំណាកស្រុកដែលត្រូវបានបញ្ជូនត្រឡប់មកវិញ (RMW) ក៏បាននិយាយផងដែរថា បានជួបការលំបាក នៅពេលព្យាយាមស្វែងរកសេវាថែទាំសុខភាពនៅពេលដែលខ្លួនវិលត្រលប់មកដល់ប្រទេសកម្ពុជាហើយនោះ។

រាជរដ្ឋាភិបាលកម្ពុជា គួរចាត់វិធានការដើម្បីបង្កើនកិច្ចសហប្រតិបត្តិការជាមួយទីភ្នាក់ងារក្នុងស្រុកអន្តរជាតិ និងអង្គការសហប្រជាជាតិនៅក្នុងប្រទេសគោលដៅ (ជាពិសេសប្រទេសថៃ) ដើម្បីផ្តល់ឯកសារគាំទ្រ ក្នុងគោលបំណងឱ្យពលករចំណាកស្រុកបានទទួលសេវាថែទាំសុខភាព រាប់បញ្ចូលទាំងការពិនិត្យសុខភាព និងការព្យាបាលផងដែរ។

## ៧.២. លទ្ធភាពទទួលបានការថែទាំសុខភាពរួមសម្រាប់ជនរងគ្រោះពីអំពើហិង្សាផ្អែកលើយេនឌ័រ

នៅក្នុងការសិក្សាកាលពី ឆ្នាំ២០២១ អង្គការវ៉ាក់ បានរកឃើញថា ចាប់តាំងពីការបើកឱ្យប្រើប្រាស់កាលពីឆ្នាំ២០១៦ នូវ "សៀវភៅណែនាំគ្លីនិក អំពីការគ្រប់គ្រងសេវាថែទាំសុខភាពសម្រាប់ស្ត្រីដែលទទួលរងអំពើហិង្សាពីដៃគូជិតស្និទ្ធ ឬអំពើហិង្សាផ្លូវភេទ" ដោយក្រសួងសុខាភិបាល (MoH) និងក្រសួងកិច្ចការនារី (MoWA) មានមូលដ្ឋានសុខាភិបាលប្រហែល ១០០ កន្លែងប៉ុណ្ណោះ ដែលបានទទួលការបណ្តុះបណ្តាលពាក់ព័ន្ធ។ ចំនួននេះ គឺតិចជាង ១% នៃមូលដ្ឋានសុខាភិបាលសរុបនៅកម្ពុជា។ [៧២]

អង្គការវ៉ាក់ បានរាយការណ៍ថា មានបញ្ហាប្រឈមជាច្រើនសម្រាប់ភាគីពាក់ព័ន្ធក្នុងការផ្តល់សេវាថែទាំសុខភាពសម្រាប់ជនរងគ្រោះដោយអំពើហិង្សាពីដៃគូស្និទ្ធស្នាល (IPV) និងអំពើហិង្សាផ្លូវភេទ ដោយក្នុងនោះ អ្នកផ្តល់សេវាសុខាភិបាលមានការយល់ដឹងនៅមានកម្រិត ទាក់ទងនឹងវិធីកំណត់ប្រភេទផ្សេងៗនៃអំពើហិង្សាមកលើអ្នកស្វែងរកសេវា។ ក្នុងចំណោមអតិថិជនដែលទទួលបានសេវាព្យាបាលទាក់ទងនឹងអំពើហិង្សាផ្អែកលើយេនឌ័រ មានអតិថិជនជាច្រើនមិនព្រមទទួលយកសេវាឡើយ ដោយខ្លាចថា ការធ្វើដូច្នេះ អាចនាំឱ្យមានអំពើហិង្សាកាន់តែខ្លាំងឡើង។ មានអ្នកខ្លះ មិនចង់ប្រាប់ព័ត៌មានឡើយ ដោយសារតែការខ្មាស់អៀន និងការប្រមាថពាក់ព័ន្ធនឹងភាពជាជនរងគ្រោះដោយសារអំពើហិង្សា ហើយបញ្ហានេះ រឹតតែធ្ងន់ធ្ងរថែមទៀត ដោយសារតែប្រជាជនភាគច្រើនមានការយល់ដឹងនៅមានកម្រិតអំពីសិទ្ធិ។ បន្ថែមលើនេះ ការមិនមានទីកន្លែងឯកជន និងបរិយាកាសផាសុខភាពសម្រាប់ការប្រឹក្សាយោបល់ ក៏ជាបញ្ហាឧបសគ្គមួយផងដែរ។

បញ្ហាប្រឈមផ្សេងទៀតរួមមាន៖
- ការផ្លាស់ប្តូរអ្នកផ្តល់សេវា ដែលញឹកញាប់កើតមានដោយសារការផ្ទេរ ឬការចូលនិវត្តន៍ ដែលជាការកាត់បន្ថយចំណេះដឹងរបស់ស្ថាប័ននៅមូលដ្ឋាននោះក្នុងការកំណត់/ឆ្លើយតបនឹងអំពើហិង្សាផ្អែកលើ យេនឌ័រ ។
- ទំនួលខុសត្រូវក្នុងការផ្តល់សេវាដល់ជនរងគ្រោះ មិនមានការកំណត់ ឬបែងចែកឲ្យច្បាស់លាស់ទេ ដែលបណ្តាលឱ្យអ្នកផ្តល់សេវាមិនផ្តល់អាទិភាពលើការងារនេះ ។
- ចំនួនអ្នកផ្តល់សេវានៅទូទាំងប្រទេសនៅមានកម្រិត ក្នុងការដោះស្រាយចំពោះតម្រូវការខ្ពស់នៃសេវាសុខាភិបាល ដែលធ្វើឱ្យងាយនឹងបរាជ័យក្នុងការកំណត់ពីអំពើហិង្សាផ្អែកលើយេនឌ័រ ។
- ជាធម្មតា ព័ត៌មានបានផ្តល់ទៅឱ្យតែអ្នកដែលមានរបួសរាងកាយធ្ងន់ធ្ងរប៉ុណ្ណោះ ។
- ខ្វះការពិនិត្យតាមដាន និងការវាយតម្លៃ (M&E) លើការឆ្លើយតបផ្អែកសុខាភិបាល ទៅឱ្យជនរងគ្រោះពីអំពើហិង្សាផ្អែកលើយេនឌ័រនៅគ្រប់កម្រិតទាំងអស់ ។

**អនុសាសន៍៖**

ក្រសួងពាក់ព័ន្ធ និងភាគីពាក់ព័ន្ធផ្សេងទៀត គួរចាត់វិធានការដើម្បី៖
- លើកកម្ពស់វិធីសាស្ត្របម្លាស់ប្រែយេនឌ័រ ក្នុងចំណោមអ្នកផ្តល់សេវា ។
- ពង្រឹងប្រព័ន្ធពិនិត្យតាមដាន និងការវាយតម្លៃ (M&E) ប្រព័ន្ធគ្រប់គ្រងការងារ និងបង្កើនកម្រិតគាំទ្រផ្នែកហិរញ្ញវត្ថុ ដើម្បីដាក់ចេញនូវប្រព័ន្ធបញ្ជូនបន្ត ។
- ពង្រឹងបណ្តាញសហគមន៍ ដើម្បីធានាថា សេវាបញ្ជូនបន្ត មានបំពាក់ឧបករណ៍ពេញលេញ ។
- ពង្រឹងការអនុវត្ត "សៀវភៅណែនាំគ្លីនិកឆ្នាំ២០១៦ សម្រាប់ការគ្រប់គ្រងសេវាថែទាំសុខភាពសម្រាប់ស្ត្រីដែលទទួលរងអំពើហិង្សាពីដៃគូជិតស្និទ្ធ ឬអំពើហិង្សាផ្លូវភេទ" នៅគ្រប់កម្រិតទាំងអស់ ។

# ឯកសារយោង


[1] Yim, S. Level of domestic violence against women still high, Khmer Times, September 22, 2022, online: <https://www.khmertimeskh.com/501155526/level-of-domestic-violence-against-women-still-high/>.

[2] Cambodia Demographic and Health Survey 2021-2022. https://www.nis.gov.kh/index.php/km/about/organization-chart/17-cdhs/123-cambodia-demographic-and-health-survey-2021-22 Specifically, see Section 14.2 and Tables 14.9, 14.14, and 14.17

[3] Tith, K. Violence against women on the rise, Khmer Times, May 13, 2022, online: <https://www.khmertimeskh.com/501074506/violence-against-women-on-the-rise/>.

[4] Cambodian Health and Education for Community (CHEC) (2022) Research study report on the GBV impacts during the imposed social distancing, its consequences, and the measures taken by the government to tackle the issue, online: <https://drive.google.com/file/d/1bLjghzzdpY9RTFZXAErUir1JqC_DIyvu/view?ts=644f7ec6>.

[5] https://www.ohchr.org/sites/default/files/documents/countries/kh/2022-08-26/SR-Cambodia-End-of-Mission-Statement.pdf

[6] Cambodian police raid alleged cybercrime trafficking compounds, Reuters, September 21, 2022, online : <https://www.reuters.com/world/asia-pacific/cambodian-police-raid-alleged-cybercrime-trafficking-compounds-2022-09-21/>.

[7] Southern, N.P., Kennedy, L. & Huang, Y., Cambodia's modern slavery nightmare: the human trafficking crisis overlooked by authorities, The Guardian, November 2, 2022: https://www.theguardian.com/world/2022/nov/03/cambodias-modern-slavery-nightmare-the-human-trafficking-crisis-overlooked-by-authorities

[8] United States State Department (2022), Trafficking in Persons Report 2022, online: <https://www.state.gov/wp-content/uploads/2022/10/20221020-2022-TIP-Report.pdf>.

[9] Forced to Scam: Cambodia's Cyber Slaves, Al Jazeera, July 14, 2022, online: <https://www.aljazeera.com/program/101-east/2022/7/14/forced-to-scam-cambodias-cyber-slaves>.
https://www.youtube.com/watch?v=n-EtdC4zQso

[10] Turton, S., Cyber slavery: inside Cambodia's online scam gangs, Asia Nikkei, September 1, 2022, online: <https://asia.nikkei.com/Spotlight/The-Big-Story/Cyber-slavery-inside-Cambodia-s-online-scam-gangs>.

[11] ECPAT, INTERPOL & UNICEF Cambodia, (2022) Disrupting Harm in Cambodia: Evidence on Online Child Sexual Exploitation and Abuse, online: <https://www.end-violence.org/sites/default/files/2022-09/DH_Cambodia_ONLINE_final_JS%20%281%29.pdf>.

[12] Haffner, A., I Am Still Afraid to Share': Cambodia's Internet Users Face Pervasive Harassment, VoD, November 21, 2021, online: <https://webcache.googleusercontent.com/search?q=cache:0XhtVBxJ1esJ:https://vodenglish.news/i-am-still-afraid-to-share-cambodias-internet-users-face-pervasive-harassment/&cd=2&hl=en&ct=clnk&gl=kh>.

[13] Nhean, M., (2022) The current situation of online GBV and harassment in Cambodia, Ideas For Peace, online: <https://www.ideasforpeace.org/content/the-current-situation-of-online-gbv-harassment-in-cambodia/>.

[14] Yim, S., Raise punishments for sexual harassment, says expert, The Khmer Times, October 4, 2022, online: <https://www.khmertimeskh.com/501161822/raise-punishments-for-sexual-harassment-says-expert/>.

[15] LICADHO (2022) Daring to Speak Out: Online Loans & Illegal Extortion, online: <https://www.licadho-cambodia.org/video.php?perm=110>.

[16] See Women Peace Makers (2020) "Preserving Harmony or Preventing Justice? A study of local dispute resolution practices in cases of domestic and intimate partner violence in Cambodia," online: <https://bit.ly/37gwsrL>.

[17] Chhun, S., K Chhnang resolves 589 dispute cases via mediation last year, The Khmer Times, January 26, 2022, online: <https://www.khmertimeskh.com/501013262/k-chhnang-resolves-589-dispute-cases-via-mediation-last-year/>.

[18] See Women Peace Makers (2020) "Preserving Harmony or Preventing Justice? A study of local dispute resolution practices in cases of domestic and intimate partner violence in Cambodia," online: <https://bit.ly/37gwsrL>.

[19] https://www.youtube.com/watch?v=Cx-c-u9wS4s

[20] Samban, C., Justice ministry plans launch of expert mediator unit next year, The Phnom Penh Post, October 18, 2022, online: <https://www.phnompenhpost.com/national/justice-ministry-plans-launch-expert-mediator-unit-next-year>.

[21] Ibid. PPP.

[22] LICADHO (2023) No Path to Safety: Failing to Prevent Intimate Partner Killings in Cambodia, online: <https://www.licadho-cambodia.org/reports.php?perm=241>.

[23] The Cambodian League for the Promotion and Defense of Human Rights (LICADHO), "Women United for Labour Rights in Cambodia: Six Stories of Resistance," November 2022, online: <https://www.licadho-cambodia.org/reports/files/239239Women%20United%20for%20Labour%20Rights_EN.pdf>.

[24] Keat S., & Dickison, M., Thousands of Workers Swept Up in a Year of Union Busting, VoD, December 16, 2022, online: <https://webcache.googleusercontent.com/search?q=cache:o8cgd-mhEbYJ:https://vodenglish.news/thousands-of-workers-swept-up-in-a-year-of-union-busting/&cd=2&hl=en&ct=clnk&gl=kh>.

[25] RHAC (2022) Harassment and VAW in the workplace: Situational analysis of sexual harassment among garment factories' workers in 2022.

[26] RoCK et al., (2022) Sexual Orientation, Gender Identity and Expression and Sex Characteristics (SOGIESC) Rights and Sexual Reproductive Health and Rights (SRHR) in Cambodia: Universal Periodic Review (UPR) Mid-term report for the third UPR of the Kingdom of Cambodia, online: <https://rockcambodia.org/wp-content/uploads/2022/03/UPR-Mid-term-Report-SOGIESC-SRHR_Final01March2022.pdf>.

[27] RoCK (2019) Family Violence towards Lesbian, Bisexual and Transgender (LBT) People in Cambodia, online: <https://www.rockcambodia.org/wp-content/uploads/2020/07/Family-Violence-LBT_ENG-19.06.2019.pdf>.

[28] Cambodia Indigenous Peoples Organisation (CIPO), Cambodia Indigenous Women Association (CIWA) & Klahaan (2022), Report on Gender-Based Violence against Indigenous Women in Three Provinces of Cambodia, online: <https://www.klahaan.org/_files/ugd/1165ef_9bc74b743ef44021bf5f908a5dc79dab.pdf>.

[29] Women Peace Makers, (2022) Making the space: Voices from the girls of Cambodian minority communities, online: <https://wpmcambodia.org/project/making-the-space/#:~:text=objective%20of%20achieving%20gender%20equality,%2C%20ignored%2C%20and%20left%20behind.>.

[30] https://wpmcambodia.org/wp-content/uploads/2022/04/makingthespace.pdf

[31] Concluding observations on the 2018 periodic report of Cambodia: CEDAW/C/KHM/CO/6 (2019), para. 32-33. Concluding observations on the 4th and 5th Periodic Report of Cambodia, UN Doc CEDAW/C/KHM/CO/4-5 (2013), paras. 30-31. CCPR concluding observations on the 2nd Periodic Report of Cambodia, CCPR/C/KHM/CO/2 (2015), para. 27.

[32] See CCHR, ACT & KKKHRA (2017) 'Citizenship RightsforKhmerKrominCambodia.'

[33] OHCHR, Cambodia: Stifling new measures against striking workers are 'unjustified' – UN human rights experts, OHCHR, 16 February, 2022, online: <https://www.ohchr.org/en/press-releases/2022/02/cambodia-stifling-new-measures-against-striking-workers-are-unjustified-un>.

[34] Human Rights Watch (2022) Only "Instant Noodle" Unions Survive: Union Busting in Cambodia's Garment and Tourism Sectors, online: <https://www.hrw.org/sites/default/files/media_2022/11/cambodia1122web_1.pdf>.

[35] Ibid. HRW.

[36] Ibid. HRW.

[37] Walker, T., Cambodia Rights Report Reveals Government Crackdown on Trade Unions, VoA, November 21, 2022, online: <https://www.voanews.com/a/cambodia-rights-report-reveals-government-crackdown-on-trade-unions-/6844272.html>.

[38] Flash Info: Chhim Sithar Detained Upon Returning to Cambodia LICADHO, November 26, 2022 online: <https://www.licadho-cambodia.org/flashnews.php?perm=323>.

[39] Joint statement is at: https://teangtnaut.org/joint-statement-immediately-release-imprisoned-union-leader-chhim-sithar/

[40] Price, N., Cambodia's Arrest of Union Leader Chhim Sithar, US State Department, November 29, 2022, online: <https://www.state.gov/cambodias-arrest-of-union-leader-chhim-sithar/>.

[41] Strangio, S., Cambodian Authorities Rearrest Prominent Union Leader, The Diplomat, November 30, 2022, online: <https://thediplomat.com/2022/11/cambodian-authorities-rearrest-prominent-union-leader/>.

[42] FLD (2022) WHRD Chhim Sithar detained upon her return to Cambodia, online: <https://www.frontlinedefenders.org/en/case/woman-human-rights-defender-chhim-sithar-detained-upon-her-return-cambodia>.

[43] Parsons, L.; Lawreniuk, S.; Sok, S.; & Buckley, J. (2022) Hot trends: How the global garment industry shapes climate change vulnerability in Cambodia. Royal Holloway, University of London and University of Nottingham. Online: <https://www.solidaritycenter.org/wp-content/uploads/2022/07/Hot-Trends-Report.pdf>.

[44] Reproductive Association of Cambodia, (2021). "Linking sexual and reproductive health and rights and climate change: A Research on impacts and policy direction in Cambodia". A research assessment. Phnom Penh: Cambodia. Hard copy in Khmer available from RHAC.

[45] Cabus, S., Sok, S., Van Praet, L., & Heang, S. (2021). Impact of Gender-Responsive and Violence-Free School Environments on Primary and Lower Secondary School Children, <https://www.vvob.org/en/downloads/impact-gender-responsive-and-violence-free-school-environments-primary-and-lower-secondary>.

[46] Ibid. Cabus.

[47] Ibid. Cabus.

[48] Concluding observations on the 2018 periodic report of Cambodia: CEDAW/C/KHM/CO/6 (2019), para. 42 CEDAW/C/KHM/CO/6.

[49] Knapp, K, Chimed-Ochir, U., Apsley, H., Eng,S., Fosco, G, Cleveland, H (2022) Profiles of Future Expectations Among Urban Adolescents in Cambodia. https://www.ncbi.nlm.nih.gov/pmc/articles/PMC9583713/

[50] https://blogs.lse.ac.uk/seac/2023/02/17/negotiating-gender-roles-and-expectations-in-the-context-of-female-education-in-cambodia/#_edn1

[51] https://www.khmertimeskh.com/501123640/teenagers-urged-to-continue-education-despite-pregnancy/

[52] Heng, M. "Cambodia's gender policy: An analysis of women and girls' education strategies under the Neary Rattanak IV Strategic Plan (2014-2018)," Cambodian Journal of Educational Research (2022),Vol. 2, No. 1, pp. 37–61. https://drive.google.com/file/d/1F7_n2QsMYAYKZyeDxSo3EOGImf6hU6hs/view?usp=sharing

[53] Klahaan 2022 "Housework Whose work?: An exploration of gender roles, unpaid care work and the mental load in Cambodia". https://www.klahaan.org/researchreports

[54] https://vodenglish.news/filmmaking-students-allege-sexual-harassment-by-bophana-center-trainers/

[55] https://cambojanews.com/boys-more-at-risk-of-dropping-out-of-school-at-secondary-levels/

[56] Ministry of Education, Youth and Sport (2022) Public education statistics and indicators on student enrolments and drop-out rates, online: <https://bit.ly/3oQkujL>.

[57] Gehrke, E., Lenel, F., and Schupp, C., (2022) COVID-19 crisis in Cambodia: A dataset containing linked survey and administrative data of ninth-graders in rural areas. Ann Arbor, MI: Inter-university Consortium for Political and Social Research [distributor], online: <https://www.sciencedirect.com/science/article/pii/S2352340922006709>

[58] www.unicef.org/cambodia/education

[59] CEDAW Committee (2019) Concluding Observations on the 2018 periodic report of Cambodia, para 35(c), CEDAW/C/KHM/CO/6.

[60] Committee for Free and Fair Elections in Cambodia (COMFREL), Gender & Development for Cambodia (GADC), SILAKA, Banteay Srei and Building Community Voices (BCV) (2022), 'Report on Empowerment of Women in Politics and the 5th Mandate Commune/Sangkat Council Elections 2022.'

[61] Pa, S., 10% of New Commune Chiefs Are Women, VoD, July 1, 2022, Konline: <https://webcache.googleusercontent.com/search?q=cache:T7wpuUHE1GMJ:https://vodenglish.news/10-of-new-commune-chiefs-are-women/&cd=2&hl=en&ct=clnk&gl=kh>.

[62] OHCHR, State of Press Freedom in Cambodia 2022, para 75-77. https://www.ohchr.org/sites/default/files/2022-08/press-freedom-cambodia-en.pdf

[63] https://www.phnompenhpost.com/national/female-journos-share-woes-seek-improvements

[64] Beech, H., They Were Surrogates. Now They Must Raise the Children, New York Times, November 26, 2022, online: <https://www.nytimes.com/2022/11/26/world/asia/surrogacy-cambodia.html>.

[65] 'Cambodia anti-trafficking laws continue to target surrogate mothers (video)' Al Jazeera, April 7, 2022, online: <https://english.cambodiadaily.com/news/cambodia-anti-trafficking-laws-continue-to-target-surrogate-mothers-video-177480/>.

[66] Kim, S., Chinese surrogacy father has appeal heard in court, The Phnom Penh Post, January 10, 2022, online: <https://www.phnompenhpost.com/national/chinese-surrogacy-father-has-appeal-heard-court>.

[67] Above n., 48, Al Jazeera.

[68] Above n., 47, New York Times.

[69] Yon, S., & Keeton-Olsen, D., A Surrogate Family and the Law That Criminalized Them, VoD, November 2, 2020, online: <https://webcache.googleusercontent.com/search?q=cache:yw8LE_tqHusJ:https://vodenglish.news/a-surrogate-family-and-the-law-that-criminalized-them/&cd=2&hl=en&ct=clnk&gl=kh>.

[70] Tin, S. Ministry to review draft surrogacy law with legal experts' Khmer Times, April 11, 2022, online: <https://www.khmertimeskh.com/501056334/ministry-to-review-draft-surrogacy-law-with-legal-experts/>

[71] RHAC (2022) Demand and minimum humanitarian settings on sexual and reproductive health rights (SRH) for migrants: A study for better sexual and reproductive health among returning Cambodian migrant workers (RMW).

[72] Reproductive Association of Cambodia, (2021). "Assessment on Effectiveness of using the National protocol and A clinical handbook for managing health care for women subjected to intimate partner violence or sexual violence". A research assessment. Phnom Penh: Cambodia. Hard copy in Khmer available from RHAC.

# ការវិវឌ្ឍនៃការអនុវត្តសេចក្ដីអង្កេតសន្និដ្ឋានអនុសញ្ញាសុី-ដ ឆ្នាំ២០១៩

**សំគាល់**
ពណ៌ក្រហម=មានការវិវឌ្ឍន៍តិចតួច ឬមិនមានសោះ
ពណ៌លឿង=មានការរីកម្រើនខ្លះ
ពណ៌បៃតង=មានការរីកចម្រើនគួរឱ្យកត់សម្គាល់

| លេខរៀងកថាខណ្ឌនៃសេចក្តីសង្កេតសន្និដ្ឋានអនុសញ្ញាសុី-ដ | ប្រធានបទ | សេចក្តីសង្ខេប | ការកម្រិតក្នុងឆ្នាំ ២០២០ | ការកម្រិតក្នុងឆ្នាំ ២០២១ | ការវិវឌ្ឍន៍ក្នុង ឆ្នាំ២០២២ | ការកម្រិតក្នុងឆ្នាំ ២០២២ |
|---|---|---|---|---|---|---|
| ៦ | SDGs | ទទួលស្គាល់ស្ត្រីជាកំលាំងចលករនៃការអភិវឌ្ឍន៍ប្រកបដោយស្ថេរភាព | | | បានអនុវត្តរួចហើយ | |
| ៩ក | ក្របខណ្ឌច្បាប់ | និយមន័យនៃការរើសអើងនៅក្នុងច្បាប់ | | | មិនទាន់បានអនុវត្តនៅឡើយ | |
| ៩ខ | ក្របខណ្ឌច្បាប់ | ការសិក្សាវាយតម្លៃពីច្បាប់ដែលមានឥទ្ធពលលើយេនឌ័រជាលក្ខណៈប្រព័ន្ធ | | | មិនទាន់បានអនុវត្តនៅឡើយ | |
| ១១ក | ការទទួលបានយុត្តិធម៌ | ជំនួយផ្នែកច្បាប់ដោយមានការផ្តល់ថវិកាជំនួយពីរដ្ឋក្នុងរយៈពេលវែងសាលាឧទ្ធរណ៍តាមតំបន់ | | | អនុវត្តមួយផ្នែកក្នុងនោះមានថវិកាជំនួយផ្នែកច្បាប់បន្ថែម ប៉ុន្តែមិនទាន់គ្រប់គ្រាន់ទេ និងមិនមានរយៈពេលយូរ។ ពុំមានសាលាឧទ្ធរណ៍ថ្មីត្រូវបានបង្កើតឡើងទេ ចាប់តាំងពីខេត្តព្រះសីហនុ បាត់ដំបង និងត្បូងឃ្មុំ ក្នុងឆ្នាំ ២០២០។ | |
| ១១ខ | ការទទួលបានយុត្តិធម៌ | បញ្ចប់ការទទួលរងស្លាកស្នាមមិនល្អក្នុងការរាយការណ៍ពីការលោភបំពានសិទ្ធិ | | | រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍បន្តអនុវត្តយុទ្ធនាការដើម្បីលើកទឹកចិត្តឱ្យរាយការណ៍ករណី GBV ប៉ុន្តែមិនមានការគាំទ្រចំពោះការរាយការណ៍អំពីអំពើហឹង្សាដែលឧបត្ថម្ភដោយរដ្ឋនោះទេ។ | |
| ១១គ | ការទទួលបានយុត្តិធម៌ | ផ្សព្វផ្សាយពត៌មានអំពីដំណោះស្រាយ | | | ក្រសួងកិច្ចការនារី បានជួយធ្វើការផ្សព្វផ្សាយពត៌មានមួយចំនួនអំពីកម្រិតនៃសេវាដែលអាចរកបាន ប៉ុន្តែមានការជួយតិចតួចក្នុងការទទួលបានដំណោះស្រាយតាមផ្លូវច្បាប់ប្រកបដោយប្រសិទ្ធភាព។ | |
| ១១ឃ | ការទទួលបានយុត្តិធម៌ | ប្រព័ន្ធយុត្តិធម៌ដែលគិតគូពីយេនឌ័រមានស្ត្រីកាន់តែច្រើនទទួលបានវគ្គបណ្តុះបណ្តាលអំពីអនុសញ្ញាសុីដ | | | ការបណ្តុះបណ្តាលអំពីគោលការណ៍ថ្មីស្តីពីកម្រិតនៃការប្រើប្រាស់ការសម្រុះសម្រួលដើម្បីជាការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី កំពុងត្រូវបានដាក់ឱ្យសាកល្បង និងមានការបណ្តុះបណ្តាលអំពីអនុសញ្ញាសុី-ដរ។ ទោះយ៉ាងនេះក្តី នៅមានកិច្ចការជាច្រើនថែមទៀត ត្រូវការអនុវត្ត ដើម្បីធ្វើឱ្យប្រព័ន្ធយុត្តិធម៌មានលក្ខណៈគិតគូពីយេនឌ័រ។ | |

| លេខរៀង កថាខណ្ឌនៃ សេចក្តីសង្កេត សន្និដ្ឋាន អនុសញ្ញាស៊ី-ដ | ប្រធានបទ | សេចក្តីសង្ខេប | ការកម្រិត ក្នុងឆ្នាំ ២០២០ | ការកម្រិត ក្នុងឆ្នាំ ២០២១ | ការវិវឌ្ឍន៍ក្នុង ឆ្នាំ២០២២ | ការកម្រិត ក្នុងឆ្នាំ ២០២២ |
|---|---|---|---|---|---|---|
| ១១ង | ការទទួល បានយុត្តិធម៌ | ការស៊ើបអង្កេត និងការដាក់ទោសលើករណីនៃអំពើហិង្សាក្នុងគ្រួសារ និងការរំលោភសេពសន្ថវៈ ត្រូវមានលក្ខណៈមិនលំអៀង ឯករាជ្យ និងតាមផ្លូវតុលាការ | | | ពុំមានការរីកចម្រើននៅឡើយ។ ប្រព័ន្ធយុត្តិធម៌ នៅមានលក្ខណៈលំអៀង ឬមិនឯករាជ្យនៅឡើយ។ ករណីនៃអំពើហិង្សាក្នុងគ្រួសារ និងការរំលោភសេពសន្ថវៈ មិនត្រូវបានធ្វើការស៊ើបអង្កេតជាប្រចាំ និងជារឿយៗនៅតែមានទិទ្ធណ្ឌភាព។ | |
| ១១ច | ការទទួល បានយុត្តិធម៌ | ឱ្យមន្ត្រីដែលជាប់ពាក់ព័ន្ធនឹងអំពើពុករលួយទទួលខុសត្រូវលើទង្វើរបស់ខ្លួន | | | មិនទាន់មានការរីកចម្រើននៅឡើយ។ | |
| ១៣ក | វិវាទ | ភាពត្រឹមត្រូវចំពោះជនរងគ្រោះនៃអំពើហិង្សាផ្អែកលើយេនឌ័រក្នុងសម័យខ្មែរក្រហម | | | មិនទាន់មានការរីកចម្រើននៅឡើយ។ | |
| ១៣ខ | វិវាទ | ផែនការសកម្មភាពស្តីពី SCR 1325 | | | មិនទាន់មានការរីកចម្រើននៅឡើយ។ | |
| ១៣គ | វិវាទ | ស្ត្រីត្រូវចូលរួមក្នុងការកសាងសន្តិភាពនៅគ្រប់ដំណាក់កាលទាំងអស់ | | | ពុំទាន់មានការផ្លាស់ប្តូរនៅឡើយ។ កម្ពុជានៅបន្តបញ្ចូលស្ត្រីនៅស្ទើគ្រប់ដំណាក់កាលលើកលែងនៅកម្រិតខ្ពស់បំផុត។ | |
| ១៥ក | យន្តការ ដឹកនាំថ្នាក់ ជាតិ | ស្វ័យភាពសម្រាប់ CNCW | | | ពុំទាន់មានការផ្លាស់ប្តូរនៅឡើយ។ | |
| ១៥ខ | យន្តការ ដឹកនាំថ្នាក់ ជាតិ | ថវិកាជាតិសម្រាប់ការអនុវត្តពេញលេញនូវគោលនយោបាយយេនឌ័រ | | | ជំនួយនៅបន្តមានកម្រិត | |
| ១៥គ | យន្តការ ដឹកនាំថ្នាក់ ជាតិ | ការចូលរួមរបស់អង្គការសង្គមស៊ីវិលនៅក្នុង NPGE | | | មិនមានបច្ចុប្បន្នភាពសម្រាប់ឆ្នាំ២០២២ | |
| ១៥ឃ | យន្តការ ដឹកនាំថ្នាក់ ជាតិ | ការត្រួតពិនិត្យ និងការវាយតម្លៃប្រកបដោយប្រសិទ្ធភាពលើគោលនយោបាយនានា សកម្មភាពយេនឌ័រនៅថ្នាក់ក្រសួង | | | មិនមានព័ត៌មានពីភាពប្រសើរឡើងនៃ M&E ក្នុងឆ្នាំ២០២២ | |
| ១៧ | យន្តការ ដឹកនាំថ្នាក់ ជាតិ ស្ថាប័ន សិទ្ធិមនុស្ស | បង្កើតឱ្យមានស្ថាប័នសិទ្ធិមនុស្សស្របតាមគោលការណ៍ទីក្រុងប៉ារីសនីមួយៗ (per Paris Principles) | | | រដ្ឋាភិបាលកំពុងស្នើឱ្យមាន NGRI មួយ ប៉ុន្តែមិនមានយន្តការដើម្បីធ្វើឱ្យវាស្របតាមគោលការណ៍ទីក្រុងប៉ារីស ។ បរិយាកាសសិទ្ធិមនុស្ស និងនយោបាយនាពេលបច្ចុប្បន្នអាចនឹងរារាំងស្ថាប័ននានាពីឯករាជ្យភាព និងប្រសិទ្ធិភាព។ | |

| លេខរៀងកថាខណ្ឌនៃសេចក្តីសង្កេតសន្និដ្ឋានអនុសញ្ញាស៊ី-ដ | ប្រធានបទ | សេចក្តីសង្ខេប | ការកម្រិតក្នុងឆ្នាំ ២០២០ | ការកម្រិតក្នុងឆ្នាំ ២០២១ | ការវិវឌ្ឍន៍ក្នុង ឆ្នាំ២០២២ | ការកម្រិតក្នុងឆ្នាំ ២០២២ |
|---|---|---|---|---|---|---|
| ១៩ | សង្គមស៊ីវិល | ធានាឱ្យមានននូវសេរីភាពនៃការបញ្ចេញមតិ ការប្រមូលផ្តុំ និងការចូលរួមសមាគម | | | នៅបន្តមានការថយចុះនៅក្នុងចំណុចនេះ | |
| ២១ក | វិធានការពិសេសបណ្តោះអាសន្ន | ការបែងចែកដីធ្លីឡើងវិញសម្រាប់ភាពជាម្ចាស់កម្មសិទ្ធិរបស់ស្ត្រីដោយស្មើភាពគ្នា | | | មិនទាន់មានកិច្ចប្រឹងប្រែងនៅឡើយ។ | |
| ២១ខ | វិធានការពិសេសបណ្តោះអាសន្ន | ការផ្តល់ទីសុវត្ថិភាពសម្រាប់ស្ត្រី | | | របាយការណ៍នៃការបណ្តេញចេញដោយបង្ខំជាក់ស្តែង និងគំរាមកំហែងបានបន្តនៅឆ្នាំ 2022 ដែលប៉ះពាល់ដល់គ្រួសាររាប់រយគ្រួសារ។ | |
| ២១គ | វិធានការពិសេសបណ្តោះអាសន្ន | កែលម្អឱកាសសេដ្ឋកិច្ចដោយមានការកំណត់កូតា | | | មិនទាន់មានវិធានការពិសេសបណ្តោះអាសន្ននៅឡើយ។ | |
| ២៣ក | ផ្នត់គំនិត | យុទ្ធសាស្ត្រមានលក្ខណៈគ្រប់ជ្រុងជ្រោយដើម្បីលុបបំបាត់ឥរិយាបថនៃការប្រកាន់ភាពជាបុរស | | | មិនមានយុទ្ធសាស្ត្រដែលមាន  លក្ខណៈគ្រប់ជ្រុងជ្រោយទេ។ មន្ត្រីជាន់ខ្ពស់ បន្តប្រកាន់ខ្ជាប់នូវឥរិយាបថបែបប្រពៃណីចំពោះក្រមសីលធម៌របស់ស្ត្រី។ | |
| ២៣ខ | ផ្នត់គំនិត | វិធីសាស្ត្រផ្សេងៗក្នុងការអប់រំយ៉េនឌ័រដោយមិនមានច្បាប់ស្រី | | | មិនមានកិច្ចប្រឹងប្រែងទេ។ គ្រូនៅតែបន្តបង្រៀនច្បាប់ស្រីនៅក្នុងថ្នាក់ បើទោះជាបានប្រកាសឲ្យដកចេញពីកម្មវិធីសិក្សាសាលា។ | |
| ២៣គ | ផ្នត់គំនិត | ជំរុញឱ្យមានឥរិយាបថដែលមានលក្ខណៈវិជ្ជមានចំពោះសមភាពយ៉េនដ័រក្នុងចំណោមយុវវ័យ | | | រដ្ឋាភិបាល បន្តចូលរួមក្នុងយុទ្ធនាការប្រព័ន្ធផ្សព្វផ្សាយសង្គម ដែលជំរុញឱ្យមានសមភាពក្នុងបរិបទមួយចំនួន។ | |
| ២៥ក | អំពើហិង្សាផ្អែកលើយ៉េនឌ័រ | ធ្វើការវាយតម្លៃពីផលប៉ះពាល់នៃវិធានការ និងដោះស្រាយឫសគល់នៃបញ្ហា | | | យុទ្ធនាការ ព័ត៌មានសាធារណៈថ្មីដើម្បីដោះស្រាយ GBV ត្រូវបានផ្តួចផ្តើមដោយ MoWA ក្នុងឆ្នាំ 2022 | |
| ២៥ខ | អំពើហិង្សាផ្អែកលើយ៉េនឌ័រ | ធ្វើការពិនិត្យឡើងវិញឱ្យបានគ្រប់ជ្រុងជ្រោយនូវច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារធ្វើវិសោធនកម្មដើម្បីដាក់ទោសទណ្ឌលើរាល់អំពើហិង្សាក្នុងគ្រួសារ សម្របសម្រួលឱ្យមានដីកាការពារដំណោះស្រាយប្រកបដោយប្រសិទ្ធភាព | | | ពុំមានការរីកចម្រើនក្នុងឆ្នាំ ២០២២ លើការធ្វើវិសោធនកម្មនៃច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារទេ។ មានផែនការមួយ ដែលគ្រោងនឹងបង្កើតផែនទីបង្ហាញផ្លូវ ដើម្បីពិនិត្យមើលច្បាប់នេះ តែនៅមិនទាន់បានបញ្ចប់នៅឡើយ។ | |

| លេខរៀងកថាខណ្ឌនៃសេចក្តីសង្កេតសន្និដ្ឋានអនុសញ្ញាស៊ី-ដ | ប្រធានបទ | សេចក្តីសង្ខេប | ការកម្រិតក្នុងឆ្នាំ ២០២០ | ការកម្រិតក្នុងឆ្នាំ ២០២១ | ការវិវឌ្ឍន៍ក្នុង ឆ្នាំ២០២២ | ការកម្រិតក្នុងឆ្នាំ ២០២២ |
|---|---|---|---|---|---|---|
| 25c | អំពើហិង្សាផ្អែកលើយេនឌ័រ | កែលម្អសេវាសំខាន់នានា | | | ការអនុវត្តNAPVAW3 បានជួយបង្កើនសមត្ថភាពមួយចំនួនក្នុងការផ្តល់សេវានានា ប៉ុន្តែកង្វះខាតនៃការផ្តល់ថវិកាជំនួយ បានធ្វើឱ្យមនុស្សជាច្រើនមិនអាចទទួលបានសេវាផ្សេងៗនោះទេ។ | |
| ២៥ឃ | អំពើហិង្សាផ្អែកលើយេនឌ័រ | ធ្វើការប្រមូលទិន្នន័យដោយប្រព័ន្ធគ្រប់គ្រងអំពីអំពើហិង្សាផ្អែកលើយេនឌ័រ | | | មិនមានការរីកចម្រើននៅឆ្នាំ 2022 ប៉ុន្តែការស្ទង់មតិប្រជាសាស្ត្រ និងសុខភាពកម្ពុជាឆ្នាំ 2021-22 នឹងបោះពុម្ពនៅដើមឆ្នាំ 2023 ។ | |
| ២៧ក | ការជួញដូរមនុស្ស | ធ្វើការដោះស្រាយបញ្ហាជាឫសគល់នៃកង្វះខាតនូវឱកាសសេដ្ឋកិច្ច | | | ពុំទាន់មានការរីកចម្រើននៅឡើយ។ | |
| ២៧ខ | ការជួញដូរមនុស្ស | ធ្វើការកែលម្អនៃការកំណត់អត្តសញ្ញាណ និងការណែនាំឱ្យទៅរកស្ថាប័នដែលផ្តល់ជំនួយសម្រាប់ជនរងគ្រោះ | | | ការរីចម្រើននៅមានកម្រិតនៅឡើយ។ ភ្នាក់ងាររដ្ឋាភិបាលបន្តចូលរួមក្នុងសេវាកម្មពហុវិស័យសម្រាប់អ្នករស់រានមានជីវិត ប៉ុន្តែពឹងផ្អែកខ្លាំងពេកលើអង្គការក្រៅរដ្ឋាភិបាល និងម្ចាស់ជំនួយពីខាងក្រៅ ហើយចាំបាច់ត្រូវការរីកចម្រើនបន្ថែមទៀត។ | |
| ២៧គ | ការជួញដូរមនុស្ស | ការដាក់បញ្ចូលជនរងគ្រោះឱ្យរួមរស់នៅក្នុងសង្គមឡើងវិញ | | | រដ្ឋាភិបាលពឹងផ្អែកខ្លាំងពេកលើអង្គការក្រៅរដ្ឋាភិបាល និងម្ចាស់ជំនួយពីខាងក្រៅ ហើយចាំបាច់ត្រូវមានការីកចម្រើនបន្ថែមទៀត។ អ្នករស់រានមានជីវិតនៅតែទទួលរងការរើសអើងយ៉ាងខ្លាំង។ | |
| ២៧ឃ | ការជួញដូរមនុស្ស | ការពារស្ត្រីពីការខាតបង់ ការការពារសាក្សី | | | ពុំមានការវិវឌ្ឍន៍ថ្មីទេ។ គោលនយោបាយមួយចំនួនបានចូលជាធរមាន ប៉ុន្តែមិនទាន់ត្រូវបានអនុវត្តឱ្យបានពេញលេញ។ | |
| ២៧ង | ការជួញដូរមនុស្ស | ការដាក់ទោសទណ្ឌលើអ្នកប្រព្រឹត្តអំពើជួញដូរមនុស្ស | | | រដ្ឋាភិបាលបានបណ្តុះបណ្តាលមន្ត្រី ប៉ុន្តែគម្លាតសមត្ថភាព នៅតែមានខ្លាំងគួរឲ្យកត់សំគាល់ ជាពិសេសនៅតំបន់ជនបទ។ ការកាត់ទោសកើតឡើង ប៉ុន្តែមិនទាន់មានការតាមដានកាកើនឡើងនៃការជួញដូរមនុស្ស។ | |
| ២៧ច | ការជួញដូរមនុស្ស | កុំប្រើប្រាស់មិនត្រឹមត្រូវនូវច្បាប់ប្រឆាំងនឹងការជួញដូរមនុស្សលើអ្នកមិនមែនជាអ្នកប្រព្រឹត្តអំពើជួញដូរ | | | មិនទាន់បានអនុវត្តនៅឡើយ | |

| លេខរៀង កថាខណ្ឌនៃ សេចក្តីសង្កេត សន្និដ្ឋាន អនុសញ្ញាស៊ីដ | ប្រធានបទ | សេចក្តីសង្ខេប | ការកម្រិត ក្នុងឆ្នាំ ២០២០ | ការកម្រិត ក្នុងឆ្នាំ ២០២១ | ការវិវឌ្ឍន៍ក្នុង ឆ្នាំ២០២២ | ការកម្រិត ក្នុងឆ្នាំ ២០២២ |
|---|---|---|---|---|---|---|
| ២៩ក | អំពើ ពេស្យាចារ | ធ្វើការពិនិត្យឡើងវិញនូវច្បាប់ដើម្បី មិនធ្វើឱ្យការប្រកបរបរផ្លូវភេទត្រូវ ជាប់ទោសទណ្ឌ | | | ពុំទាន់មានកិច្ចប្រឹងប្រែងនៅឡើយទេ។ | |
| ២៩ខ | អំពើ ពេស្យាចារ | ដាក់ទោសអ្នកកេងប្រវ័ញ្ចលើអំពើ នេះ | | | មានកិច្ចប្រឹងប្រែងមួយចំនួន។ មានករណី មួយចំនួនត្រូវបានយកមកផ្តន្ទាទោស ប៉ុន្តែ នៅមានអ្នកកេងប្រវ័ញ្ចជាច្រើនទៀត នៅ មិនទាន់ទទួលការដាក់ទោស។ | |
| ២៩គ | អំពើ ពេស្យាចារ | ដោះស្រាយបញ្ហាជាឬស គល់ ដូចជា ភាពក្រីក្រ តម្រូវការ វិសមភាព | | | ពុំទាន់មានកិច្ចប្រឹងប្រែងថ្មីនៅឡើយ។ | |
| ២៩ឃ | អំពើ ពេស្យាចារ | ផ្តល់នីតិសម្បទា | | | ពុំទាន់មានកិច្ចប្រឹងប្រែងថ្មីនៅឡើយ។ | |
| ៣១ក | ជីវិតសា សាធារណៈ | អនុម័តវិធានការពិសេស បណ្តោះអាសន្ន ដូចជាការ ផ្តល់ កូតា | | | ពុំទាន់មានកិច្ចប្រឹងប្រែងនៅឡើយ។ | |
| ៣១ខ | ជីវិត សាធារណៈ | បង្កើតបរិយាកាសដែលជួយដល់ ស្ត្រី | | | ពុំទាន់មានកិច្ចប្រឹងប្រែងនៅឡើយ។ | |
| ៣៣ក | សញ្ជាតិ | ការទទួលបានសញ្ជាតិ ការអប់រំ ការងារ ការថែទាំសុខភាព ផ្តល់ ជម្រកដល់ស្ត្រីដែលមានសញ្ជាតិជា ជនជាតិវៀតណាម និងមាន ដើមកំណើតខ្មែរ | | | របាយការណ៍នៃការបណ្តេញចេញ ដោយបង្ខំលើគ្រួសារជនជាតិវៀតណាម និងការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់ ពួកគេបានបន្តនៅឆ្នាំ 2022។ | |
| ៣៣ខ | សញ្ជាតិ | សម្របសម្រួលដល់ការធ្វើឯកសារ កំណត់អត្តសញ្ញាណ និងសំបុត្រ កំណើត ដោយគ្មានការដកហូត ឯកសារ | | | ពុំទាន់មានកិច្ចប្រឹងប្រែងថ្មីនៅឡើយ។ របាយការណ៍ស្តីពីស្ត្រី និងកុមារី ជនជាតិភាគតិចមិនអាចទទួលបាន អត្តសញ្ញាណប័ណ្ណបានបន្តពេញមួយឆ្នាំ 2022 ដូចរបាយការណ៍នៃការដកហូត អត្តសញ្ញាណប័ណ្ណ។ | |
| ៣៣គ | សញ្ជាតិ | ផ្តល់សច្ចាប័នលើអនុសញ្ញាចំនួនពីរ ស្តីពីភាពមិនមែនជាពលរដ្ឋនៃ ប្រទេសណាមួយ (Statelessness) | | | ពុំទាន់មានការរីកចម្រើននៅឡើយ។ | |
| ៣៥ក | ការអប់រំ | បង្កើនការទទួលបានការអប់រំនៅ កម្រិតអនុវិទ្យាល័យ លុបបំបាត់ កត្តារារាំងសម្រាប់កុមារី | | | មានកិច្ចប្រឹងប្រែងខ្លះៗជាបន្តបន្ទាប់។ | |

| លេខរៀងកថាខណ្ឌនៃសេចក្ដីសង្កេតសន្និដ្ឋានអនុសញ្ញាស៊ី-ដ | ប្រធានបទ | សេចក្ដីសង្ខេប | ការកម្រិតក្នុងឆ្នាំ ២០២០ | ការកម្រិតក្នុងឆ្នាំ ២០២១ | ការវិវឌ្ឍន៍ក្នុង ឆ្នាំ២០២២ | ការកម្រិតក្នុងឆ្នាំ ២០២២ |
|---|---|---|---|---|---|---|
| ៣៥ ខ | ការអប់រំ | ជំរុញលើកទឹកចិត្តដល់កុមារីឱ្យចូលក្នុងវិធីសាស្រ្តអប់រំ STEAM(មុខវិជ្ជា វិទ្យាសាស្រ្ត បច្ចេកវិទ្យា វិស្វកម្ម សិល្បៈ និងគណិតវិទ្យា) | | | កម្មវិធីមួយចំនួន ត្រូវបានអនុម័តដើម្បីជំរុញលើកទឹកចិត្តកុមារីឱ្យសិក្សាមុខវិជ្ជា STEAM។ តែទោះយ៉ាងណាក៏ដោយសកម្មភាពគោលដៅគឺចាំបាច់នៅក្នុងតំបន់ជនបទ។ | |
| ៣៥ គ | ការអប់រំ | ផ្ដល់វគ្គបណ្ដុះបណ្ដាលអំពីយ៉េនឌ័រដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយដល់គ្រូបង្រៀន | | | ផែនការយុទ្ធសាស្រ្តស្ដីពីការបញ្ជ្រាបយេនឌ័រនៅក្នុងការអប់រំ ឆ្នាំ២០២១-២០២៥ បានដាក់បញ្ចូលអនុសាសន៍របស់គណៈកម្មាធិការស៊ី-ដ និងដាក់បញ្ចូលវគ្គបណ្ដុះបណ្ដាលសម្រាប់គ្រូបង្រៀន នៅក្នុងសកម្មភាព។ | |
| ៣៧ ក | ការងារ | បុគ្គលិកកម្មករស្ថិតក្នុងកិច្ចសន្យាមានថេរវេលាកំណត់ ទទួលបានសេរីភាពបង្កើតសហជីព និងអត្ថប្រយោជន៍នៃការឈប់លំហែមាតុភាព<br>restore AC 2-year cap on FDCs | | | ពុំទាន់មានកិច្ចប្រឹងប្រែងនៅឡើយ។ ការបង្ក្រាបដោយអាជ្ញាធរប្រឆាំងនឹងកម្មករស្រ្តីដែលធ្វើកូដកម្មរួមបញ្ចូលទាំងអ្នកធ្វើការមានកិច្ចសន្យាមានថេរវេលាកំណត់ FDCs ។ | |
| ៣៧ ខ | ការងារ | ការពារវិស័យក្រៅប្រព័ន្ធ មានដូចជា អ្នកបម្រើការងារតាមផ្ទះ នៅក្នុងច្បាប់ស្ដីពីការងារ | | | គម្រោងសាកល្បងរបស់ NSSF ក្នុងឆ្នាំ 2022 បានកំណត់គោលដៅលើអ្នកបើកបរម៉ូតូកង់បី និងអ្នកធ្វើការតាមផ្ទះចំនួន 2050 នាក់ ដើម្បីទទួលបានអត្ថប្រយោជន៍ពី NSSF រួមទាំងការថែទាំសុខភាពដោយឥតគិតថ្លៃ និង 70% នៃប្រាក់ឈ្នួលពេលឈប់សម្រាកពេលសម្រាកលំហែមាតុភាពរហូតដល់ 90 ថ្ងៃ។ | |
| ៣៧ គ | ការងារ | ជំរុញលើកទឹកចិត្តឱ្យមានការចែករំលែកតួនាទីជាឪពុកម្ដាយដោយមានការឈប់លំហែបិតុភាព | | | ពុំទាន់មានកិច្ចប្រឹងប្រែងថ្មីនៅឡើយ។ | |
| ៣៧ ឃ | ការងារ | ការតាក់តែងច្បាប់ដោយមានលក្ខណៈគ្រប់ជ្រុងជ្រោយស្ដីពីការបៀតបៀនផ្លូវភេទ ដោយមានដំណោះស្រាយ | | | ពុំទាន់មានកិច្ចប្រឹងប្រែងថ្មីនៅឡើយ។ | |
| ៣៧ ង | ការងារ | ធានាឱ្យមានប្រាក់ឈ្នួលស្មើគ្នាសម្រាប់ការងារមានតម្លៃស្មើគ្នា យោងតាមអនុសញ្ញាលេខ ១០០ នៃអង្គការអន្តរជាតិខាងផ្នែកការងារ (ILO C100) | | | ពុំមានកិច្ចប្រឹងប្រែងក្នុងការប្រៀបធៀបប្រភេទការងារខុសៗគ្នាដោយមានតម្លៃស្មើគ្នានោះឡើយ។ មិនមានការអនុវត្តជាប្រចាំនូវច្បាប់ដែលមានស្រាប់ស្ដីពីប្រាក់ឈ្នួលស្មើគ្នាសម្រាប់ការងារដូចគ្នា។ | |
| ៣៧ ច | ការងារ | ការពារកម្មករចំណាកស្រុកទៅក្រៅប្រទេស | | | ពុំទាន់មានកិច្ចប្រឹងប្រែងនៅឡើយទេ។ | |
| ៣៧ ឆ | ការងារ | ផ្ដល់សច្ចាប័នលើអនុសញ្ញានៃអង្គការអន្តរជាតិខាងផ្នែកការងារ លេខ ១៨៣ លេខ ១៨៩ លេខ ១៩០ | | | C183, C189 និង C190 បន្តមិនផ្ដល់សច្ចាបន្ន | |

| លេខរៀងកថាខណ្ឌនៃសេចក្ដីសង្កេតសន្និដ្ឋានអនុសញ្ញាស៊ី-ដ | ប្រធានបទ | សេចក្ដីសង្ខេប | ការកម្រិតក្នុងឆ្នាំ ២០២០ | ការកម្រិតក្នុងឆ្នាំ ២០២១ | ការវិវឌ្ឍន៍ក្នុង ឆ្នាំ២០២២ | ការកម្រិតក្នុងឆ្នាំ ២០២២ |
|---|---|---|---|---|---|---|
| ៣៩ ក | សុខភាព | ការទទួលបានជាសកលនូវសេវាថែទាំសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ | | | នៅឆ្នាំ 2022 NMCH បានធ្វើបច្ចុប្បន្នភាព និងពង្រីកយុទ្ធសាស្ត្រជាតិសម្រាប់ SRHR នៅកម្ពុជា 2017-2023។ ទោះជាយ៉ាងណាក៏ដោយ សកម្មភាពបន្ទាន់ដើម្បីកែលម្អលទ្ធភាពទទួលបានការអប់រំ និងសេវាសុខភាពបន្តពូជផ្លូវភេទ និងសុខភាពបន្តពូជនៅតែមាន ជាពិសេសនៅតំបន់ជនបទ និងក្នុងចំណោមស្ត្រី/ក្មេងស្រីជនជាតិភាគតិច។ | |
| ៣៩ ខ | សុខភាព | ការប្រយុទ្ធប្រឆាំងនឹងការទទួលរងស្លាកស្នាមមិនល្អនៃការយកកូនចេញ និងការប្រើប្រាស់វិធីពន្យារកំណើត | | | យុទ្ធសាស្ត្រជាតិ របស់ SRHR មានសូចនាករថ្មីៗដូចជា តម្រូវឱ្យមានការរួមបញ្ចូលនៃការបញ្ជាក់តម្លៃ និងការផ្លាស់ប្ដូរអាកប្បកិរិយា (VCAT) ទៅក្នុងគោលការណ៍ណែនាំបណ្ដុះបណ្ដាល ដើម្បីគាំទ្រដល់ការផ្ដល់សេវាដែលមិនមានការរើសអើង។ | |
| ៣៩ គ | សុខភាព | ដោះស្រាយតម្រូវការអាហាររូបត្ថម្ភរបស់ស្ត្រី នៅក្នុងយុទ្ធសាស្ត្រនានា | | | ពុំទាន់មានការប្រែប្រួលនៅឡើយទេ។ | |
| ៣៩ ឃ | សុខភាព | ការទប់ស្កាត់មហារីកសុដន់ | | | យុទ្ធសាស្ត្រជាតិ របស់ SRHR មានសូចនាករ ស្ដីពីការបង្កើនការគ្របដណ្ដប់ និងគុណភាពនៃការការពារ ការពិនិត្យ និងសេវាព្យាបាលជំងឺមហារីកមាត់ស្បូន រួមទាំងកម្មវិធីវ៉ាក់សាំង HPV ផងដែរ។ ការចេញផ្សាយនេះនឹងតម្រូវឱ្យមានធនធាន និងការសម្របសម្រួលដ៏សំខាន់។ | |
| ៤១ | ស្ត្រីជនបទ | ធ្វើនិយតកម្មលើគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងកែលម្អការទទួលបានប្រាក់កម្ចីដែលមានអត្រាការប្រាក់ទាបជួយគាំទ្រដល់អាជីពខ្នាតធំដែលមានស្ត្រីជាម្ចាស់ | | | បញ្ហាធ្ងន់ធ្ងរជាមួយវិស័យ MFI បានបន្តប៉ះពាល់ដល់ស្ត្រីនៅឆ្នាំ 2022។ | |
| ៤៣ ក | ការប្រែប្រួលអាកាសធាតុ | បញ្ចូលស្ត្រីក្នុងការបង្កើតគោលនយោបាយ | | | ការដាក់បញ្ចូលសម្លេងរបស់ស្ត្រីនៅមានកម្រិតក្នុងការបង្កើតគោនយោបាយ ប៉ុន្តែពុំមានការវិភាគលើយេនឌ័រដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ត្រូវបានយកមកអនុវត្តនៅឡើយ។ | |
| ៤៣ ខ | ការប្រែប្រួលអាកាសធាតុ | បញ្ចូលទស្សនៈវិស័យយេនឌ័រដែលមានលក្ខណៈច្បាស់លាស់ទៅក្នុងគោលនយោបាយ | | | កិច្ចខិតខំប្រឹងប្រែងកំពុងបន្ត រួមទាំងផែនការយុទ្ធសាស្ត្រការបញ្ជ្រាបយេនឌ័រ ក្នុងវិស័យបរិស្ថាន។ ទោះជាយ៉ាងណាក៏ដោយ ការកំណត់គោលដៅរដ្ឋនៃ EHRDs បានបន្តនៅឆ្នាំ 2022។ | |

| លេខរៀងកថាខណ្ឌនៃសេចក្តីសង្កេតសន្និដ្ឋានអនុសញ្ញាស៊ី-ដ | ប្រធានបទ | សេចក្តីសង្ខេប | ការកម្រិតក្នុងឆ្នាំ ២០២០ | ការកម្រិតក្នុងឆ្នាំ ២០២១ | ការវិវឌ្ឍន៍ក្នុង ឆ្នាំ២០២២ | ការកម្រិតក្នុងឆ្នាំ ២០២២ |
|---|---|---|---|---|---|---|
| ៤៥ ក | ស្ត្រីស្ថិតក្នុងការឃុំខ្លួន | ប្រើវិធីសាស្ត្រផ្សេងទៀតជំនួសដោយការឃុំខ្លួន | | | មិនទាន់មានការរីកចម្រើននៅឡើយ។ វិធានការផ្សេងទៀតជំនួសដោយការឃុំខ្លួន ដូចជាការដោះលែងមុនការជំនុំជំរះក្តី និងការប្រើប្រាស់ការព្យួរទោស មិនត្រូវបានពិចារណា និងអនុវត្តឱ្យបានសមស្រប ដូចជា ចំពោះស្ត្រីមានផ្ទៃពោះ និងស្ត្រីដែលមានកូនតូចនៅជាមួយនោះទេ។ | |
| ៤៥ ខ | ស្ត្រីស្ថិតក្នុងការឃុំខ្លួន | ដោះស្រាយបញ្ហាជាឫសគល និងផលប៉ះពាល់លើកុមារពីការកាត់ឱ្យជាប់ពន្ធនាគារ | | | មិនទាន់មានការរីកចម្រើនទេ។ | |
| ៤៥ គ | ស្ត្រីស្ថិតក្នុងការឃុំខ្លួន | កាត់បន្ថយចំនួនមនុស្សលើសចំណុះ សេវា តាមវិធានទីក្រុងបាំងកក និងវិធានណេលសាន់ម៉ានដេឡា (per Bangkok rules and Nelson Mandela rules) | | | ទោះបីជាមានការបង្កើតតុលាការឧទ្ធរណ៍ក្នុងតំបន់ដើម្បីកាត់បន្ថយការឃើតយ៉ាវនៃសំណុំរឿងក្តី ពន្ធនាគារនៅតែបន្តដាក់ចំនួនមនុស្សលើសឆ្ងាយពីអត្រាចំណុះផ្លូវការរបស់ខ្លួន ហើយមិនធានានូវការទទួលបានសេវាចាំបាច់នានាដែរ។ | |
| ៤៧ ក | ស្ត្រីពរពោះជំនួស | លុបចោលសេចក្តីសម្រេចក្នុងខែធ្នូ ឆ្នាំ២០១៦ ដើម្បីអនុញ្ញាតឱ្យស្ត្រីពរពោះជំនួសមានសិទ្ធិចិញ្ចឹមក្មេងក្នុងនាមជាកូនបង្កើតរបស់ខ្លួន | | | មិនមានផែនការកែប្រែសេចក្តីសម្រេចនេះនៅឡើយទេ។ | |
| ៤៧ ខ | ស្ត្រីពរពោះជំនួស | ដោះស្រាយបញ្ហាជាឫសគល់ដោយកែលម្អឱកាសនៃការរកប្រាក់ចំណូល | | | មិនទាន់មានសកម្មភាពទេ។ | |
| ៤៧ គ | ស្ត្រីពរពោះជំនួស | ធានាថា ច្បាប់ និងគោលនយោបាយ នឹងជួយដោះស្រាយអតុល្យភាពអំណាចនៃស្ត្រីពរពោះជំនួស | | | មិនទាន់មានកិច្ចប្រឹងប្រែងនៅឡើយសម្រាប់ឆ្នាំ២០២២។ | |
| ៤៧ ឃ | ស្ត្រីពរពោះជំនួស | ច្បាប់មិនគួរដាក់ទោសទណ្ឌលើស្ត្រីពរពោះជំនួស | | | មិនទាន់មានកិច្ចប្រឹងប្រែងនៅឡើយ។ខណៈដែលសេចក្តីព្រាងច្បាប់នេះមិនអាចកាត់ទោសអ្នកពពោះជំនួសបានដោយចេតនា វាមិនរារាំងការប្រើប្រាស់ច្បាប់ផ្សេងទៀតប្រឆាំងនឹងពួកគេឡើយ។ | |
| ៤៩ ក | អាពាហ៍ពិពាហ៍ | វិធានការនានា ផ្តោលើការបន្ថយអត្រានៃការរៀបអាពាហ៍ពិពាហ៍កុមារ | | | សកម្មភាពដែលបានធ្វើ ប៉ុន្តែមានកម្រិតសម្រាប់ខេត្តជាក់លាក់មួយចំនួន។ ផែនការដែលបានប្រកាសនៅក្នុងខែធ្នូ ឆ្នាំ 2022 ដើម្បីអភិវឌ្ឍន៍ផែនការជាតិ។ | |
| ៤៩ ខ | អាពាហ៍ពិពាហ៍ | លុបចោលមាត្រា ៩៥០ នៃក្រមរដ្ឋប្បវេណី | | | មិនមានកិច្ចប្រឹងប្រែងធ្វើឡើងក្នុងការលុបចោលមាត្រានេះទេ។ | |

NGO-CEDAW ជាសម្ព័ន្ធអង្គការឈានមុខគេ ដែលធ្វើការតាមដាន និងលើកកម្ពស់ឲ្យមានការអនុវត្តអនុញ្ញារបស់អង្គការ សហប្រជាជាតិ ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើង លើស្ត្រី (ស៊ី-ដ)។ អង្គការនេះ បានបង្កើតឡើងនៅក្នុងឆ្នាំ ១៩៩៥ ដោយសកម្មជនស្ត្រីកម្ពុជាមួយចំនួន នៅក្រោយការ វិលត្រឡប់មកវិញរបស់ពួកគាត់ ពីការចូលរួមសន្និសីទពិភពលោកស្តីពីស្ត្រីនៅទីក្រុងប៉េកាំង។ NGO-CEDAW បានពង្រីកសមាជិកភាពរបស់ខ្លួនពី ៩ អង្គការ ដែលជាអ្នកបង្កើត NGO-CEDAW នេះឡើង រហូតមកដល់ ៣៥ អង្គការក្នុងស្រុកជាសមាជិក។ NGO-CEDAW ធ្វើការជាមួយបណ្តាញដៃគូជាង ៣០ បន្ថែមទៀត ដើម្បីផ្តល់សម្លេងគាំទ្រដល់ក្រុមស្ត្រី និងសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា (LGBTIQ) ដែលងាយរងគ្រោះ ។

ការងាររបស់ NGO-CEDAW រួមមាន៖
ការស្រាវជ្រាវ ការស្វែងរកមតិគាំទ្រ ការលើកកម្ពស់ការយល់ដឹង កសាងសមត្ថភាព និងការផ្លាស់ប្តូរព័ត៌មានក្នុងចំណោមសមាជិក របស់ខ្លួន។ សកម្មភាពជាក់លាក់របស់ NGO-CEDAW រួមមាន ការរៀបចំវេទិកាជជែកដេញដោលថ្នាក់សកលវិទ្យាល័យប្រចាំឆ្នាំ កម្មវិធីតាំងពិព័រណ៍ការបង្កើតស្នាដៃសិល្បៈ ការតស៊ូមតិដោយផ្ទាល់នៅអង្គការសហប្រជាជាតិ ផ្តល់វគ្គបណ្តុះបណ្តាលសម្រាប់អាជ្ញា ធរមូលដ្ឋាន និងក្រុមសហគមន៍នានា ។

**អាស័យដ្ឋាន ការិយាល័យ NGO-CEDAW:**
**ផ្ទះលេខ ១៦ ផ្លូវ ៩៩ សង្កាត់ បឹងត្របែក ខណ្ឌចំការមន**
**រាជធានីភ្នំពេញ**

www.ngocedaw.org
ngocedaw.pnh@gmail.com
@TheCambodianNgoCommitteeOnCedaw